**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Science Economiques

Royal University of Law and Economics


**សារណាបញ្ចប់ការសិក្សា**

# នីតិវិធីស៊ើបសួរនៅដំណាក់កាលសាលាដំបូង

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ: លោក **ម៉ិច គីមសេង**

កញ្ញា **តា លីណា**

ណែនាំដោយ

លោក **តា សុទ្ធា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Science Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# នីតិវិធីស៊ើបសួរនៅដំណាក់កាល
# សាលាដំបូង

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ម៉ិច គីមសេង**

កញ្ញា **តា លីណា**

ណែនាំដោយ

លោក **តា សុទ្ធា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ម៉ិច គីមសេង** និងនាងខ្ញុំឈ្មោះ **តាលីណា** ជានិស្សិតផ្នែកនីតិសាស្ត្រនៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ឆ្នាំសិក្សា២០២២-២០២៣ ជំនាន់ទី២៣។

ជាដំបូងខ្ញុំទាំងពីរនាក់ សូមថ្លែងអំណរគុណលំអោនកាយវាចាចិត្ត និងសម្តែងនូវមហាកតញ្ញូតាធម៌ដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ

**លោកឪពុក ប៉ាក់ យូលាង** **លោកឪពុក អ៊ុង ប៊ុនធឿន**

**អ្នកម្តាយ វ៉ាត វឌ្ឍនា** **អ្នកម្តាយ គង់ វណ្ណារី**

ដែលបានបង្កើតរូបកាយកូន និងចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មាន ឧបត្ថម្ភរូបកូនគ្រប់បែបយ៉ាងតាំងពីតូចដល់ធំ ទាំងកម្លាំងកាយ ទាំងកម្លាំងចិត្តមិនគិតពីការនឿយហត់របស់លោកទាំងពីរនោះឡើយ និងបានឱ្យកូនរៀនសូត្រមានចំណេះដឹងរហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រដោយជោគជ័យ។ គុណូបការៈ យ៉ាងធំអនេក និងវិសេសវិសាលថ្លៃថ្លាបំផុតដែលមិនអាចកាត់ថ្លៃបានរបស់លោកអ្នកមានគុណទាំងពីរ ដែលជាម្លប់ដ៏ប្រពៃត្រជាក់ត្រជុំសម្រាប់កូនគ្រប់ៗរូបមានទំហំធំធេងរកអ្វីប្រៀបផ្ទឹមពុំបានឡើយ។ ទង្វើរបស់លោកទាំងពីរធ្វើឱ្យកូនៗចងចាំជានិច្ចគ្មានថ្ងៃបំភ្លេចបាន ហើយនឹងស្ថិតក្នុងដួងព្រលឹងរបស់កូនៗជារៀងដរាបគ្មានថ្ងៃសូន្យនោះឡើយ។

យើងទាំងពីរនាក់ក៏សូមថ្លែងអំណរគុណចំពោះ **សាកលវិទ្យាធិការ សាកលវិទ្យាធិការរង និងលោក លោកស្រីសាស្ត្រាចារ្យទាំងអស់ នៃសាលកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានខិតខំយកចិត្តទុកដាក់ក្នុងការផ្តល់នូវពុទ្ធិល្អៗយ៉ាងពិតប្រាកដ សម្រាប់ជាយានបំភ្លឺជីវិតយើងខ្ញុំនៅក្នុងថ្នាក់បរិញ្ញាបត្រនេះ។

ជាពិសេស យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ លោកសាស្ត្រាចារ្យ **តា សុន្ធា** ដែលជាសាស្ត្រាចារ្យណែនាំ ដើម្បីធ្វើឱ្យមាននូវដំណើរការនៃការតាក់តែងសារណានេះឡើងប្រកបដោយភាពជោគជ័យ។ ជាពិសេសលោកបានចំណាយនូវកម្លាំងកាយ កម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃក្នុងការណែនាំ តម្រង់ទិសផ្តល់ឯកសារពាក់ព័ន្ធ និងអានុសាសន៍ល្អៗ ក៏ដូចជាជួយកែលម្អចំណុចខ្វះខាតទាំងឡាយដើម្បីធ្វើយ៉ាងណាឱ្យសារណាយើងខ្ញុំបានទទួលនូវលទ្ធផលល្អ និងត្រឹមត្រូវ។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរនាក់សូមប្រសិទ្ធិពរជ័យសិរីបវរជូនដល់ លោកអ្នកមានគុណទាំងពីរ ឯកឧត្តម លោកជំទាវ លោក លោកស្រីសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ មិត្តរួមថ្នាក់ និងរួមជំនាន់ទាំងអស់ សូមប្រកបតែព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

យើងខ្ញុំឈ្មោះ **ម៉ិច គីមសេខ** និងឈ្មោះ **តា លីណា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ តាមរយៈការសិក្សារយៈពេល ៤ឆ្នាំនេះ ការសិក្សាបរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ពិតជាផ្តល់នូវសារៈសំខាន់យ៉ាងខ្លាំងសម្រាប់យើងខ្ញុំជាយុវជនជំនាន់ក្រោយ ទោះបីកាលៈទេសៈខ្លះយើងខ្ញុំបានជួបប្រទះនូវឧបសគ្គ និងការលំបាកយ៉ាងណាក៏ដោយក៏នៅតែព្យាយាមតស៊ូក្រេបយកចំណេះវិជ្ជាដោយមិនព្រមបោះបង់នូវការសិក្សានេះឡើយក្នុង គោលបំណងដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រនេះដោយជោគជ័យជាស្ថាពរ។ ទន្ទឹមនឹងនេះ ការបញ្ចប់បរិញ្ញាបត្រឱ្យបានជោគជ័យ យើងខ្ញុំក៏មានគោលបំណងក្នុងការបញ្ចប់ការសិក្សាដោយការសរសេរសារណាផងដែរ ដើម្បីជាស្នាដៃសម្រាប់យើងខ្ញុំផ្ទាល់ បន្ទាប់ពីបានខិតខំសិក្សាអស់រយៈពេល៤ឆ្នាំកន្លងមកនេះ។

ដោយសារតែមានការឆ្លងកាត់ការសិក្សាកន្លងមកនូវមុខវិជ្ជាសំខាន់ៗជាច្រើនក្នុងបរិញ្ញាបត្រនីតិសាស្ត្រនេះ ទើបយើងខ្ញុំមានចំណាប់អារម្មណ៍ និងចង់ស្វែងយល់លម្អិតបន្ថែមលើមុខវិជ្ជានីតិវិធីព្រហ្មទណ្ឌ ព្រោះថាមុខវិជ្ជានេះ គឺជាមុខវិជ្ជាដែលសិក្សាទាក់ទងនឹងនីតិវិធីព្រហ្មទណ្ឌ និងជាវិធានច្បាប់មួយដ៏សំខាន់ក្នុងចំណោមវិធានច្បាប់ផ្សេងៗទៀតសម្រាប់គ្រប់គ្រងសង្គមជាតិឱ្យមានសណ្តាប់ធ្នាប់ឱ្យបានល្អប្រសើរ ពិសេសជាងនេះទៅទៀត ដោយសារតែយើងខ្ញុំបានសិក្សាអំពីនីតិវិធី និងដំណាក់កាលនីមួយៗក្នុងរឿងព្រហ្មទណ្ឌ ដើម្បីសិក្សាឱ្យបានលម្អិតបន្ថែមអំពីចំណាត់ការ និងនីតិវិធីនីមួយៗនៅក្នុងដំណើរការរឿងព្រហ្មទណ្ឌ ទើបយើងខ្ញុំសម្រេចចិត្តធ្វើការស្រាវជ្រាវ ទៅលើប្រធានបទមួយមានចំណងជើងថា "**នីតិវិធីស៊ើបសួរនៅដំណាក់កាលសាលាដំបូង**" ។

គោលបំណងដែលយើងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទមួយនេះមកធ្វើការស្រាវជ្រាវ និងចងក្រងឡើង គឺដើម្បីស្វែងយល់បន្ថែម ទទួលយកបទពិសោធន៍ និងពុទ្ធិកាន់តែស៊ីជម្រៅអំពីនីតិវិធីនៃការបើកកិច្ចស៊ើបសួរ និងនីតិវិធីនៃការបិទកិច្ចស៊ើបសួរ បើទោះបីជាប្រធានមួយនេះមានសិស្សច្បងជំនាន់មុនៗបានលើកយកមកសរសេរច្រើនរួចក៏ដោយ ប៉ុន្តែក្រុមយើងខ្ញុំសង្ឃឹមថាការស្រាវជ្រាវថ្មីនេះនឹងមានអ្វីល្អៗប្លែកថ្មីខុសពីការស្រាវជ្រាវមុនៗ។

ជាក់ស្តែង ដោយប្រធានបទ "**នីតិវិធីស៊ើបសួរនៅដំណាក់កាលសាលាដំបូង**" នេះមានភាពធំទូលាយដូច្នេះ យើងខ្ញុំសូមអភ័យទោសជាមុនប្រសិនបើមានការបកស្រាយមិនគ្រប់ជ្រុងជ្រោយ ឬខ្វះខាតត្រង់ចំណុចណាមួយដោយហេតុថាយើងជានិស្សិត ដែលពុំទាន់ឆ្លងកាត់ការអនុវត្តជាក់ស្តែងនូវឡើយទេ ទើបនាំឱ្យមានការស្រាវជ្រាវរបស់យើងខ្ញុំនៅមានកម្រិត។ ប៉ុន្តែ បើទោះបីជាយ៉ាងណាក៏ដោយ ក៏យើងខ្ញុំនៅសង្ឃឹមយ៉ាងមុតមាំថាការស្រាវជ្រាវរបស់យើងខ្ញុំមួយនេះនឹងអាចផ្តល់នូវចំណេះដឹងបន្ថែមដល់អ្នកដែលមានបំណងចង់សិក្សា និងស្វែងយល់បន្ថែមពីនិតិវិធីស៊ើបសួរនៅដំណាក់កាលសាលាដំបូងនេះ ជាពិសេសនិស្សិតដែលកំពុងសិក្សាផ្នែកនីតិសាស្ត្រផងដែរ។

# មាតិកា

**ទំព័រ**

## សេចក្តីផ្តើម

១.លំនាំបញ្ហានៃការស្រាវជ្រាវ ...................................................... ១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ...................................................... ១
៣. គោលបំណងនៃការស្រាវជ្រាវ...................................................... ២
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ...................................................... ២
៥. សារៈសំខាន់នៃការស្រាវជ្រាវ ...................................................... ៣
៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ...................................................... ៣
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ...................................................... ៤

## ជំពូកទី១
## សញ្ញាណទូទៅនៃការស៊ើបសួរ

១. គោលការណ៍ទូទៅពាក់ព័ន្ធនឹងការស៊ើបសួរ ...................................................... ៥
 ១.១. គោលការណ៍ទូទៅនៃក្រមព្រហ្មទណ្ឌ ...................................................... ៥
 ១.២. គោលការណ៍ទូទៅនៃក្រមនីតិវិធីព្រហ្មទណ្ឌ...................................................... ៧
២. ចៅក្រមស៊ើបសួរ ...................................................... ៨
 ២.១. តួនាទី និងសិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរ...................................................... ៩
 ២.២. សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ...................................................... ១១

## ជំពូកទី២
## ចំណាត់ការរបស់ចៅក្រមស៊ើបសួរក្នុងការបើកការស៊ើបសួរ

១. មូលហេតុដែលនាំឱ្យមានការបើកការស៊ើបសួរ...................................................... ១៣
 ១.១. ការបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (RI) ...................................................... ១៣
 ១.២. ការបើកការស៊ើបសួរតាមរយៈបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ...................................................... ១៤
២. ដំណើរការក្នុងកិច្ចស៊ើបសួរនៅដំណាក់កាលសាលាដំបូងរាជធានី/ខេត្ត...................................................... ១៤
 ២.១. វិធានការនិរន្តរាយ ...................................................... ១៤
 ២.២. កិច្ចរបស់ចៅក្រមស៊ើបសួរនៅដំណាក់កាលសាលាដំបូងរាជធានី/ខេត្ត ...................................................... ៣០

## ជំពូកទី៣

## ចំណាត់ការរបស់ចៅក្រមស៊ើបសួរក្នុងការបិទការស៊ើបសួរ


១. មូលហេតុដែលនាំឱ្យបិទការស៊ើបសួរ ............................................................ ៣៣

១.១. ការបិទការស៊ើបសួរដោយចៅក្រមស៊ើបសួរ ............................................ ៣៣

១.២. ការបិទការស៊ើបសួរតាមរយៈការប្តឹងសុំរបស់ភាគី ........................................ ៣៤

២. នីតិវិធីនៃការបិទកិច្ចស៊ើបសួរនៅជំណាក់កាលសាលាដំបូងរាជធានី/ខេត្ត ............................ ៣៤

២.១. ការត្រៀមរៀបចំនីតិវិធីនៃការបិទការស៊ើបសួរ ........................................ ៣៥

២.២. សេចក្តីសម្រេចបិទកិច្ចស៊ើបសួរនៅជំណាក់កាលសាលាដំបូងរាជធានី/ខេត្ត.................. ៤៥

៣. អានុភាពនការបិទកិច្ចស៊ើបសួរនៅជំណាក់កាលសាលាដំបូងរាជធានី/ខេត្ត ........................ ៤៨

៣.១. ការបញ្ចប់អានុភាពនៃការឃុំខ្លួនបណ្តោះអាសន្ន........................................ ៤៨

៣.២.ការបញ្ចប់អានុភាពនៃការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ.................. ៤៩

៣.៣. ការបញ្ចប់អានុភាពនៃមោឃភាព........................................................ ៥០

៣.៤. ការផ្លាស់ប្តូរឋានៈរបស់ជនត្រូវចោទ ................................................ ៥០

**សេចក្តីសន្និដ្ឋាន** ............................................................................ ៥១

**អនុសាសន៍** .................................................................................. ៥៣

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងប្រព័ន្ធច្បាប់ព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា ចៅក្រមស៊ើបសួរ គឺបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការស្វែងរកការពិត ដោយក្នុងនោះចៅក្រមស៊ើបសួរ ជាអ្នកស្វែងរកនូវភស្តុតាងទាំងដាក់បន្ទុក និងដោះបន្ទុក។ ចៅក្រមស៊ើបសួរចាប់ផ្តើមអនុវត្តតួនាទីរបស់ខ្លួនបន្ទាប់ពីកិច្ចស៊ើបសួរត្រូវបានបើក ហើយកិច្ចស៊ើបសួរនេះផងដែរ ត្រូវបើកជាកាតព្វកិច្ចចំពោះបទឧក្រិដ្ឋ និងបទមជ្ឈិម ការស៊ើបសួរអាចបើកឡើងក្នុងករណីដែលរឿងក្តីមានលក្ខណៈស្មុគស្មាញ ក៏ដូចជាភស្តុតាងមិនគ្រប់គ្រាន់ ជាអាទិ៍។ ចៅក្រមស៊ើបសួរអាចដំណើរការនីតិវិធីរបស់ខ្លួននៅក្នុងការបើកការស៊ើបសួរនេះទៅបាន លុះត្រាតែមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីតំណាងអយ្យការ ឬក្នុងករណីចៅក្រមស៊ើបសួរទទួលពាក្យបណ្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយនេះគឺជាការផ្តល់មូលដ្ឋាន និងសិទ្ធិអំណាចស្របច្បាប់ឱ្យចៅក្រមស៊ើបសួរប្រើប្រាស់អំណាចរបស់ខ្លួន ដើម្បីស្វែងរកការពិតដោយស្របទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌ។ បន្ទាប់ពីក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់ សិទ្ធិអំណាចទៅឱ្យចៅក្រមស៊ើបសួរ នៅក្នុងការបើកកិច្ចស៊ើបសួរហើយនោះចៅក្រមស៊ើបសួរត្រូវមានកាតព្វកិច្ចក្នុងការបិទកិច្ចស៊ើបសួរនេះវិញផងដែរ។

ចំពោះចំណាត់ការនីតិវិធីនៃការបិទកិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរ ជាវិធានការមួយដែលតម្រូវឱ្យចៅក្រមស៊ើបសួរបញ្ចប់កាតព្វកិច្ចរបស់ខ្លួននៅក្នុងការស្វែងរកនូវការពិតនៅក្នុងនីតិវិធីរឿងក្តីព្រហ្មទណ្ឌ ហើយគ្រប់ចំណាត់ការរបស់ចៅក្រមស៊ើបសួរទាំងអស់ ប៉ុន្តែការបិទកិច្ចស៊ើបសួរក៏អាចធ្វើបានតាមរយៈការប្តឹងសុំរបស់ភាគី ដែលក្នុងនោះរួមមាន ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

យើងដឹងហើយថា ចៅក្រមស៊ើបសួរ គឺបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការស្វែងរកការពិតនៅក្នុងវិស័យព្រហ្មទណ្ឌ ព្រោះដើម្បីធ្វើឱ្យមានភាពយុត្តិធម៌ទៅដល់គូភាគីនៃរឿងក្តីព្រហ្មទណ្ឌនិយាយដោយឡែក និងនៅក្នុងវិស័យព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជានិយាយជារួម។ ដើម្បីយល់ដឹងឱ្យកាន់តែច្បាស់អំពីកិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរនេះ យើងគួរគប្បីតែសិក្សាស្វែងយល់ដឹងអំពី៖

- តើនរណាជាចៅក្រមស៊ើបសួរ ហើយចៅក្រមស៊ើបសួរនេះមានសិទ្ធិអំណាចអ្វីខ្លះ?
- តើចៅក្រមស៊ើបសួរមានចំណាត់ការអ្វីខ្លះ នៅក្នុងនិតិវិធីនៃការបើកការស៊ើបសួរនេះ?
- តើចៅក្រមស៊ើបសួរមានចំណាត់ការអ្វីខ្លះ នៅក្នុងនិតិវិធីនៃការបិទការស៊ើបសួរនេះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងសំខាន់ៗនៃការស្រាវជ្រាវទាក់ទងទៅនឹង នីតិវិធីស៊ើបសួរនៅដំណាក់កាលសាលាដំបូងនេះ គឺផ្តោតសំខាន់ទៅលើចំណុចមួយចំនួនដូចជាៈ

- សិក្សាឱ្យដឹងថាតើនរណាទៅជាចៅក្រមស៊ើបសួរនៅក្នុងរឿងក្តីព្រហ្មទណ្ឌ។
- សិក្សាអំពីសិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរ នៅក្នុងដំណាក់កាលសាលាដំបូងរាជធានី/ខេត្ត។
- សិក្សាអំពីចំណាត់ការរបស់ចៅក្រមស៊ើបសួរនៅក្នុងនីតិវិធីបើកការស៊ើបសួរ នៅដំណាក់កាលសាលាដំបូងរាជធានី/ខេត្ត។
- សិក្សាអំពីចំណាត់ការរបស់ចៅក្រមស៊ើបសួរនៅក្នុងនីតិវិធីបិទការស៊ើបសួរ នៅដំណាក់កាលសាលាដំបូងរាជធានី/ខេត្ត។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

### ៤.១. ទំហំ

ក្រុមយើងខ្ញុំបានធ្វើការកំណត់ឯកសារមួយចំនួនដែលមានភាពសំខាន់ពាក់ព័ន្ធនឹងប្រធានបទ ដើម្បីធ្វើការសិក្សាស្រាវជ្រាវទៅលើនីតិវិធីរបស់ចៅក្រមស៊ើបសួរនៅសាលាដំបូងរាជធានី/ខេត្ត។ អាស្រ័យហេតុនេះ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទ នីតិវិធីស៊ើបសួរនៅដំណាក់កាលសាលាដំបូងមកធ្វើការបកស្រាយនៅក្នុងប្រធានបទមួយនេះ ដើម្បីធ្វើការឈ្វេងយល់ឱ្យបានច្បាស់អំពីកិច្ចរបស់ចៅក្រមស៊ើបសួរតែប៉ុណ្ណោះ។

### ៤.២. ដែនកំណត់

ចំពោះការលើកយកប្រធានបទអំពីនីតិវិធីស៊ើបសួរនៅដំណាក់កាលសាលាដំបូង មិនមែនមានន័យថាក្នុងប្រធានបទនេះសិក្សាតែទៅលើសិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរឡើយ ពោលគឺធ្វើការសិក្សាទៅលើភាគីពាក់ព័ន្ធនៅក្នុងកិច្ចនេះផងដែរ ប៉ុន្តែគ្រាន់តែមិនធ្វើការសិក្សាឱ្យបានស៊ីជម្រៅដូចកិច្ចដែលចៅក្រមស៊ើបសួរធ្វើការបំពេញ។ ដូច្នេះ គប្បីត្រូវធ្វើការកំណត់យកត្រឹមតែចំណាត់ការរបស់ចៅក្រមស៊ើបសួរក្នុងការបើកការស៊ើបសួរ និងចំណាត់ការរបស់ចៅក្រមស៊ើបសួរក្នុងការបិទកិច្ចស៊ើបសួរតែប៉ុណ្ណោះ ដើម្បីលើកយកមកបកស្រាយនៅក្នុងប្រធានបទនេះឱ្យកាន់តែស៊ីជម្រៅ ក៏ដូចជាមិនមានលក្ខណៈធំទូលាយពេក។

ដោយឡែក ចំពោះដែនកំណត់ក្នុងការស្រាវជ្រាវវិញ គឺផ្តោតសំខាន់ទៅលើ នីតិវិធី និងអានុភាពនៃការបើក និងបិទកិច្ចស៊ើបសួរ ហើយនិងចំពោះអានុភាពនៃការបញ្ចប់កិច្ចស៊ើបសួរនេះផងដែរ មិនធ្វើការសិក្សាឱ្យបានលម្អិតពាក់ព័ន្ធជាមួយនឹងការប្តឹងជំទាស់របស់ភាគី (ព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ ឬជនត្រូវចោទ ជាអាទិ៍) ទៅសភាស៊ើបសួរឡើយ ដោយធ្វើការសិក្សាត្រឹមការបញ្ចប់កិច្ចរបស់ចៅក្រមស៊ើបសួរតែប៉ុណ្ណោះ មិនធ្វើការពន្លាតវិសាលភាពរហូតទៅដល់ការប្តឹងទៅសភាស៊ើបសួរនោះទេ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទនីតិវិធីស៊ើបសួរនៅដំណាក់កាលសាលាដំបូង ផ្តល់សារៈសំខាន់មួយចំនួនដូចជា៖

- ទទួលបានចំណេះដឹងថ្មីៗទាក់ទងទៅនឹងការស្រាវជ្រាវ និងយល់ដឹងកាន់តែលម្អិតទាក់ទងនឹងប្រធានបទ
- អាចស្គាល់បានថានរណាជាចៅក្រមស៊ើបសួរសួរនៅក្នុងរឿងក្តីព្រហ្មទណ្ឌ
- យល់ដឹងអំពីនីតិវិធីស៊ើបសួរនៅសាលាដំបូងរាជធានី/ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា
- យល់ដឹងអំពីកិច្ចនីតិវិធីនៃការបើកការស៊ើបសួររបស់ចៅក្រមស៊ើបសួរ
- យល់ដឹងអំពីកិច្ចនីតិវិធីនៃការបិទការស៊ើបសួររបស់ចៅក្រមស៊ើបសួរ
- ផ្តល់ឯកសារទុកសម្រាប់សិស្សនិស្សិត អ្នកសិក្សា និងអ្នកស្រាវជ្រាវ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវនេះ ក្រុមយើងខ្ញុំបានប្រមូលព័ត៌មាន និងទិន្នន័យមកសំអាងពីទិន្នន័យចម្បង និងទិន្នន័យបន្ទាប់បន្សំ។ ដើម្បីឱ្យដំណើរការនៃការស្រាវជ្រាវនេះប្រកបដោយភាពជោគជ័យយើងទាមទារនូវតម្រូវការទិន្នន័យជាច្រើន ដែលទទួលបានពីប្រភពចម្បងពីរដែលសម្រួលក្នុងការប្រមូលទិន្នន័យ និងវិភាគឱ្យគ្រប់គ្រាន់គឺទិន្នន័យចម្បង និងទិន្នន័យបន្ទាប់បន្សំ។

### ៦.១. វិធីសាស្ត្រមូលទិន្នន័យ

#### ក. ទិន្នន័យចម្បង

ទិន្នន័យច្បង ជាទិន្នន័យដែលទទួលបានតាមរយៈមធ្យោបាយមួយចំនួនដូចខាងក្រោម ៖

–ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

–ច្បាប់ស្តីពីវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៣។

–បទពិសោធន៍ការងារដែលបានជួបជាក់ស្តែង នូវចំណាត់ក្នុងការអនុវត្តរបស់ចៅក្រមស៊ើបសួរ ក្នុងការបើកកិច្ចស៊ើបសួរ និងការបិទកិច្ចស៊ើបសួរ។

#### ខ. ទិន្នន័យបន្ទាប់បន្សំ

ទិន្នន័យបន្ទាប់បន្សំ ជាទិន្នន័យដែលទទួលបានតាមរយៈមធ្យោបាយមួយចំនួនដូចខាងក្រោម ៖

- ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤។
- ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤។
- សៀវភៅ ឯកសារ មេរៀនដទៃទៀតដែលនិយាយ និងសិក្សាពាក់ព័ន្ធនឹងចៅក្រមស៊ើបសួរ។

### ៦.២. វិធីសាស្ត្រវិភាគទិន្នន័យ

ចំពោះវិធីសាស្ត្រវិភាគទិន្នន័យ ដែលប្រើប្រាស់ក្នុងការវិភាគសារណា ដែលទាក់ទងទៅនឹងនីតិវិធីស៊ើបសួរនៅដំណាក់កាលសាលាដំបូងនេះ គឺត្រូវបានកំណត់ និងអនុវត្តន៍នូវវិធីសាស្ត្រតាមបែបគុណភាព និងមិនធ្វើតាមបែបបរិមាណនោះទេ។ សម្រាប់ការវិភាគទិន្នន័យ គឺក្រុមយើងខ្ញុំយកទិន្នន័យចម្បង និងទិន្នន័យបន្ទាប់បន្សំដែលប្រមូលបានមកវិភាគ ដើម្បីឈានទៅដល់ការទាញចេញជាសេចក្តីសន្និដ្ឋាន និងការផ្តល់អានុសាសន៍។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីជាការស្រាវជ្រាវ និងជាការចងក្រងនូវប្រធានបទនេះឱ្យបានស៊ីជម្រៅ គប្បីត្រូវធ្វើការសិក្សាផ្តោតសំខាន់ទៅលើ ០៣ (បី) ជំពូក ដូចខាងក្រោម៖

ជំពូកទី១៖ គោលការណ៍ទូទៅ និង សញ្ញាណនៃចៅក្រមស៊ើបសួរ

ជំពូកទី២៖ ចំណាត់ការរបស់ចៅក្រមស៊ើបសួរក្នុងការបើកការស៊ើបសួរ

ជំពូកទី៣ ៖ ចំណាត់ការរបស់ចៅក្រមស៊ើបសួរក្នុងការបិទការស៊ើបសួរ។

# ជំពូកទី១
# សញ្ញាណទូទៅនៃការសើបសួរ

# ជំពូកទី១
# សញ្ញាណទូទៅនៃការស៊ើបសួរ

## ១. គោលការណ៍ទូទៅពាក់ព័ន្ធនឹងការស៊ើបសួរ

### ១.១. គោលការណ៍ទូទៅនៃក្រមព្រហ្មទណ្ឌ

#### ១.១.១. គោលការណ៍នីត្យានុកូលភាព

មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទបញ្ញត្តិព្រហ្មទណ្ឌជាធរមាន តែប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន។

មានតែទោសដែលមានចែងក្នុងបទបញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើស ត្រូវបានប្រព្រឹត្ត ប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន។[1]

#### ១.១.២. គោលការណ៍ដែនដីនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសទាំងឡាយ ដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

ដែនដីនៃព្រះរាជាណាចក្រកម្ពុជា រួមបញ្ចូលទាំងលំហអាកាស និងសមុទ្រដែលមានចំណងចងភ្ជាប់នឹងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។[2]

#### ១.១.៣. គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

បុគ្គលម្នាក់ៗ ទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ។[3]

#### ១.១.៤. គោលការណ៍ឯកត្តកម្មនៃទោស

តុលាការប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើសទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាន និងបន្ទុកទៅលើមូលហេតុ ព្រមទាំងទៅលើកិរិយាមាយាទរបស់ជនល្មើសក្រោយពេលប្រព្រឹត្តបទល្មើស និងចំពោះជនរងគ្រោះ ជាអាទិ៍។[4]

#### ១.១.៥. គោលការណ៍មិនប្រតិសកម្ម

គោលការណ៍នេះ គឺជាគោលការណ៍ដែលមិនអនុវត្តច្បាប់ព្រហ្មទណ្ឌទៅលើអំពើណាដែលបានប្រព្រឹត្តមុនច្បាប់ព្រហ្មទណ្ឌចូលជាធរមាន៖

---

[1] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា ៣។

[2] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា ១២។

[3] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា ២៤។

[4] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា ៩៦។

- នៅភ្នំពេញ ១០ថ្ងៃ
- នៅទូទាំងប្រទេស ២០ថ្ងៃ
- ប្រញាប់នៅម៉ោង សូន្យ។

**១.១.៦. គោលការណ៍ប្រតិសកម្ម**

គោលការណ៍ប្រតិសកម្ម គឺជាគោលការណ៍ដែលយកច្បាប់ព្រហ្មទណ្ឌមកអនុវត្តចំពោះ អំពើណាដែលបានប្រព្រឹត្តមុនពេលក្រមព្រហ្មទណ្ឌចូលជាធរមាន ហើយការអនុវត្តនេះចំពោះបទបញ្ញត្តិថ្មីដែលចែងអំពីទោសដែលស្រាលជាងត្រូវអនុវត្តភ្លាម។[5] លក្ខខណ្ឌ៖

- អំពើដែលប្រព្រឹត្តមុនពេលច្បាប់ថ្មីចូលជាធរមាននោះផ្តន្ទាទោសដោយច្បាប់ថ្មីស្រាលជាងច្បាប់ចាស់
- អំពើដែលប្រព្រឹត្តមុនពេលច្បាប់ថ្មីចូលជាធរមាននោះ ត្រូវបានច្បាប់ថ្មីកំណត់ថាពុំមែនជាបទល្មើស
- អំពើដែលប្រព្រឹត្តនោះមិនទាន់ត្រូវផ្តន្ទាទោសដោយតុលាការនៅឡើយ។

**១.១.៧. គោលការណ៍ត្រួតទោស**

មានបទល្មើសត្រួតគ្នាកើតឡើង កាលបើបទល្មើសមួយត្រូវបានប្រព្រឹត្តដោយបុគ្គលម្នាក់ៗ មុនពេលដែលបុគ្គលនេះត្រូវផ្តន្ទាទោសជាស្ថាពរចំពោះបទល្មើសមួយផ្សេងទៀត។[6]

**១.១.៨. គោលការណ៍ស្រូបទោស**

សំដៅទៅលើប្រជុំទណ្ឌកម្មច្រើន បានប្រកាសផ្សេងៗគ្នា ទៅជាទណ្ឌកម្មតែមួយដែលយកទណ្ឌកម្មមួយណាដែលធ្ងន់ជាងគេ។[7]

**១.១.៩. គោលការណ៍បូកទោស**

ជាបដិបញ្ញត្តិទៅលើបទបញ្ញត្តិមុន ការពិន័យដែលបានប្រកាសឡើង ចំពោះបទលហុច្រើននោះ ត្រូវបូកបញ្ចូលគ្នា ហើយត្រូវបូកផងដែរជាមួយទោសពិន័យ ដែលប្រកាសឡើង ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម។[8]

**១.១.១០. គោលការណ៍មិនជំនុំជម្រះពីរដងក្នុងរឿងតែមួយ**

ពុំមានការចោទប្រកាន់ណាមួយអាចប្រព្រឹត្តប្រឆាំងនឹងបុគ្គលណាម្នាក់ ដែលត្រូវបានជំនុំជម្រះជាស្ថាពរនៅឯបរទេសចំពោះអំពើល្មើសដដែល ហើយក្នុងករណីដែលមានការផ្តន្ទាទោស បុគ្គលនោះបានបង្ហាញថាខ្លួនបានអនុវត្តទោសរបស់ខ្លួនរួចហើយ ឬក៏ទោសត្រូវបានរលត់ដោយការផុតអាជ្ញាយុកាល។[9]

---

[5] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា ១០ កថាខណ្ឌទី១។

[6] មាត្រា ១៣៦ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា ១៣៦។

[7] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា ១៣៩ កថាខណ្ឌទី១។

[8] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា ១៤០។

[9] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា ២៣។

## ១.២. គោលការណ៍ទូទៅនៃក្រមនីតិវិធីព្រហ្មទណ្ឌ

### ១.២.១. គោលបំណងនៃក្រមនីតិវិធីព្រហ្មទណ្ឌ

ក្រមនីតិវិធីព្រហ្មទណ្ឌ មានគោលបំណងកំណត់អំពីវិធានទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្តតាមដោយហ្មត់ចត់ ដើម្បីកំណត់ឱ្យច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌ កាលណាពុំមានវិធានដោយឡែកចែងដោយច្បាប់ពិសេស។[10]

### ១.២.២. បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី

បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណីគឺជាបណ្តឹងពីរផ្សេងគ្នា។

បណ្តឹងអាជ្ញា មានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឱ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននេះតាមច្បាប់កំណត់ ។

បណ្តឹងរដ្ឋប្បវេណី មានគោលបំណងធ្វើឱ្យ បានជួសជុលការខូចខាត ដែលបណ្តាលមកពី អំពើល្មើសដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះ ឱ្យអ្នករងគ្រោះបានទទួលសំណងជម្ងឺ ចិត្តធូនល្មមនឹងព្យសនកម្មដែលខ្លួនបានទទួល។[11]

### ១.២.៣. ដើមបណ្តឹងរដ្ឋប្បវេណី

បណ្តឹងរដ្ឋប្បវេណី អាចត្រូវធ្វើឡើងក្នុងនាមជនរងគ្រោះបាន ដោយតំណាងស្របច្បាប់របស់ខ្លួន កាលណាជនរងគ្រោះជាអនីតិជន ឬ ជានីតិជនស្ថិតនៅក្រោមរបបច្បាប់ការពារ។[12]

### ១.២.៤. បណ្តឹងរដ្ឋប្បវេណីរបស់សិទ្ធិវ័ន្ត

ក្នុងករណីមរណៈភាព នៃជនរងគ្រោះ បណ្តឹងរដ្ឋប្បវេណីអាចត្រូវបានផ្តើមធ្វើ ឬ បន្តបានដោយសិទ្ធិវ័ន្ត។[13]

### ១.២.៥. ចុងចម្លើយនៃបណ្តឹងរដ្ឋប្បវេណី

បណ្តឹងរដ្ឋប្បវេណី អាចធ្វើឡើងប្រឆាំងនឹងជនទាំងអស់ដែលត្រូវជួសជុលព្យសនកម្មបណ្តាលមកពីបទល្មើសរួមមាន៖

- ចារី សហចារីនៃបទល្មើស
- អ្នកផ្តើមគំនិត អ្នកសមគំនិត
- អ្នកទទួលខុសត្រូវរដ្ឋប្បវេណី។[14]

---

[10] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១។

[11] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ២។

[12] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៥។

[13] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៦។

[14] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ២១។

### ១.២.៦. មរណភាពរបស់ជនជាប់ចោទ

ដើមបណ្ដឹងរដ្ឋប្បវេណី អាចសុំឱ្យមានការជួសជុលព្យសនកម្មពីសិទ្ធិវន្តនៃជនជាប់ចោទបាន ប្រសិនបើជនជាប់ចោទនេះ ទទួលមរណភាពនៅក្នុងពេលដំណើរការរឿងក្ដីព្រហ្មទណ្ឌ។ ថ្វីត្បិតតែបណ្ដឹងអាជ្ញាត្រូវរលត់ តុលាការព្រហ្មទណ្ឌនៅតែមានសមត្ថកិច្ច ដើម្បីសម្រេចលើបណ្ដឹង រដ្ឋប្បវេណីដែលធ្វើឡើងប្រឆាំងនឹងសិទ្ធិវន្តទាំងនោះ។[15]

### ១.២.៧. ការចាត់តាំងដោយប្រធានតុលាការ

កាលណាចៅក្រមស៊ើបសួរណាម្នាក់ ពុំអាចបំពេញមុខងាររបស់ខ្លួនបានទេ ដោយសារការឈប់សម្រាកដោយមានជម្ងឺ ឬដោយមានមូលហេតុដទៃផ្សេងទៀត ចៅក្រមស៊ើបសួរផ្សេងទៀតនៃតុលាការដដែលត្រូវបានចាត់តាំងជាបណ្ដោះអាសន្ន ដោយប្រធានតុលាការ ដើម្បីបំពេញមុខងារស៊ើបសួរ។

ក្នុងករណីពុំមានចៅក្រមស៊ើបសួរទេ ចៅក្រមផ្សេងទៀតនៃតុលាការដដែល អាចត្រូវបានចាត់តាំងជាបណ្ដោះអាសន្ន ដោយប្រធានតុលាការដើម្បីបំពេញមុខងារស៊ើបសួរ។[16]

### ១.២.៨. ការដកហូតសំណុំរឿងពីចៅក្រមស៊ើបសួរ

ការដកហូតសំណុំរឿងពីចៅក្រមស៊ើបសួរ ដើម្បីប្រគល់ជូនចៅក្រមស៊ើបសួរម្នាក់ទៀត អាចស្នើទៅពីប្រធានតុលាការ ដើម្បីជាប្រយោជន៍នៃរដ្ឋបាលដ៏ល្អនៃយុត្តិធម៌។ ការស្នើសុំនេះ អាចធ្វើឡើងដោយពាក្យសុំដែលមានសំអាងហេតុរបស់ព្រះរាជអាជ្ញា ដែលធ្វើឡើងដោយការផ្ដើមគំនិតផ្ទាល់ខ្លួន ឬ តាមរយៈពាក្យបណ្ដឹងរបស់ភាគី។[17]

### ១.២.៩. ករណីមិនព្រមទៀរចាកដែលនាំឱ្យមោឃភាព

ចៅក្រមស៊ើបសួរមិនអាចចូលរួមក្នុងការជំនុំជម្រះរឿងព្រហ្មទណ្ឌ ដែលខ្លួនបានចាត់ការ ក្នុងឋានៈជាចៅក្រមស៊ើបសួរបានទេ បើពុំដូច្នេះទេ ការជំនុំជម្រះត្រូវចាត់ទុកជាមោឃៈ ។

ចៅក្រមស៊ើបសួរប្រើអំណាចដែលមានចែងនៅក្នុងក្រមនេះ។[18]

## ២. ចៅក្រមស៊ើបសួរ

យោងតាមមាត្រា ៣ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការបានបញ្ញតិថា សាលាជម្រះក្ដីនៃព្រះរាជាណាចក្រកម្ពុជាមានជាអាទិ៍សាលាដំបូងរាជធានី/ខេត្ត ហើយសាលាដំបូងរាជធានី/ខេត្តនេះគឺជាសាលាជម្រះក្ដី

[15] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ២៤។

[16] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៥១។

[17] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៥៣ កថាខណ្ឌទី១ ។

[18] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៥៤។

ជាន់ទាប។ ហើយបើយោងតាមមាត្រា ៣ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា បានបញ្ញត្តិដូចគ្នានឹងមាត្រា ៣ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាដែរថា ចៅក្រម សំដៅដល់ចៅក្រមអនាៈ រួមមានជាអាទិ៍ ចៅក្រមជំនុំជម្រះក្តី និងចៅក្រមស៊ើបសួរ។

ចៅក្រមស៊ើបសួរ គឺជាចៅក្រមដែលស្ថិតក្នុងសាលាដំបូងរាជធានី-ខេត្ត ណាមួយដែលទទួលមុខនាទីស៊ើបសួរលើសំណុំរឿងព្រហ្មទណ្ឌណាមួយ តាមការចាត់តាំងរបស់ប្រធានតុលាការណាមួយនោះ។ មិនតែប៉ុណ្ណោះប្រធានតុលាការក៏ចាត់តាំងខ្លួនឯង ជាចៅក្រមស៊ើបសួរបានផងដែរ។

## ២.១. តួនាទី និងសិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរ

### ២.១.១. តួនាទីរបស់ចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរនៃសាលាដំបូង មានតួនាទីបើកការស៊ើបសួរទៅលើអង្គហេតុដែលមានចែង នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរតែប៉ុណ្ណោះ។ ចៅក្រមស៊ើបសួរ បំពេញកិច្ចស៊ើបសួរទាំងអស់ដែលខ្លួនយល់ឃើញថា មានប្រយោជន៍សម្រាប់បង្ហាញឱ្យឃើញការពិតដោយអនុលោមតាមច្បាប់។ ចៅក្រមស៊ើបសួរមានករណីកិច្ចស៊ើបសួរទាំងដាក់បន្ទុក និងដោះបន្ទុក។[19]

ក្នុងករណីដែលចៅក្រមស៊ើបសួរ កំពុងតែបំពេញកិច្ចស៊ើបសួរ ប្រសិនបើមានលិចនូវអង្គហេតុថ្មី ដែលអាចជាបទល្មើសព្រហ្មទណ្ឌ នៅក្នុងពេលស៊ើបសួរចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានអំពីអង្គហេតុនេះទៅព្រះរាជអាជ្ញា។[20] ដើម្បីអោយព្រះរាជអាជ្ញា អាចធ្វើការប្តឹងសុំបើកកិច្ចស៊ើបសួរលើអង្គហេតុថ្មីនោះ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។

នៅពេលការស៊ើបសួរបានបញ្ចប់សព្វគ្រប់ហើយ គឺចៅក្រមស៊ើបសួរត្រូវបិទការស៊ើបសួរតាមរយៈដីកាដំណោះស្រាយចំនួនពីរប្រភេទរួមមាន ដីកាបញ្ជូនទៅជំនុំជម្រះ និងដីកាលើកលែងការចោទប្រកាន់។ បន្ទាប់មកចៅក្រមស៊ើបសួរត្រូវរៀបចំរបាយការណ៍មួយហៅថា "របាយការណ៍ជូនរឿងទៅជំនុំជម្រះ" កាលបើក្នុងដីកានោះត្រូវបញ្ជូនទៅជំនុំជម្រះមិនថាតែមួយផ្នែក ឬទាំងអស់នោះទេ។ ចំពោះការលើកលែងការចោទប្រកាន់ក៏ដោយមិនថាមួយតែមួយផ្នែក ឬទាំងអស់ត្រូវមានសំអាងហេតុដែរ។ របាយការណ៍ព្រមទាំងសំណុំរឿងទាំងអស់ត្រូវដាក់ជូនទៅប្រធានតុលាការដើម្បីចាត់ការបន្តតាមនីតិវិធីច្បាប់។ ប្រសិនបើតុលាការយល់ឃើញថា សំណុំរឿងមូលសព្វគ្រប់ហើយប្រធាននោះនឹងចាត់តាំង ចៅក្រមម្នាក់ទទួលបន្ទុកធ្វើការជំនុំជម្រះលើរឿងក្តីនោះ។

[19] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា១២៧។

[20] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា១២៥ កថាខណ្ឌទី២ ។

### ២.១.២. សិទ្ធិអំណាចរបស់របស់ចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរនៃសាលាដំបូង មានសិទ្ធិអំណាចក្នុងការបើកកិច្ចស៊ើបសួរឡើង ដោយកិច្ចស៊ើបសួរនោះធ្វើឡើងតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលចេញដោយព្រះរាជអាជ្ញា។ ម្យ៉ាងវិញទៀត ចៅក្រមស៊ើបសួរ ក៏អាចធ្វើការបើកកិច្ចស៊ើបសួរតាមរយៈពាក្យបណ្ដឹងដែលមានការតាំងខ្លួនជា ដើមបណ្ដឹងរដ្ឋប្បវេណីបានផងដែរ តែចៅក្រមស៊ើបសួរត្រូវបំពេញតាមនីតិវិធីដែលមានចែងក្នុងមាត្រា ១៣៩ (ការបញ្ជូនបណ្ដឹងទៅព្រះរាជអាជ្ញា) និងមាត្រា ១៤០ (ការបង់ប្រាក់តម្កល់ទុក) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ព្រះរាជាណាចក្រកម្ពុជា។[21]

ចៅក្រមស៊ើបសួរនៃសាលាដំបូង អាចសុំឱ្យចៅក្រមផ្សេង ឬ មន្ត្រីនគរបាលយុត្តិធម៌ ឬ អង្គភាពនគរបាលយុត្តិធម៌ បំពេញកិច្ចខ្លះតាមដីកាចាត់ឱ្យស៊ើបសួរជំនួស នៅក្នុងលក្ខខណ្ឌដែលមានចែងនៅមាត្រា១៧៣ (ដីកាចាត់ឱ្យស៊ើបសួរជំនួស) ដល់មាត្រា ១៨៤ (កំណត់ហេតុកសាងដោយមន្ត្រីនគរបាលយុត្តិធម៌) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។[22]

ចៅក្រមស៊ើបសួរនៃសាលាដំបូង អាចធ្វើការសម្រេចប៉ះពាល់ដល់សេរីភាពបុគ្គលបាន តាមរយៈការចេញសេចក្ដីសម្រេចមានអំណាចបង្ខំក្រោមទម្រង់ជាដីកា។ ដែលដីការទាំងនោះរួមមាន៖

- ដីកាបង្គាប់ឱ្យចូលខ្លួន
- ដីកាបង្គាប់ឱ្យនាំខ្លួន
- ដីកាបង្គាប់ឱ្យចាប់ខ្លួន
- ដីកាបង្គាប់ឱ្យឃុំខ្លួន
- ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ
- ការចេញដីកា៖ សិទ្ធិរបស់ចៅក្រមស៊ើបសួរ (តែត្រូវគោរពទម្រង់ និងលក្ខខណ្ឌនៃការចេញ)។

ចៅក្រមស៊ើបសួរនៃសាលាដំបូង មានអំណាចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យនូវបុគ្គលគ្រប់រូប ដែលមានតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់គ្នាយ៉ាងខ្លាំងថា បានចូលរួមប្រព្រឹត្តបទល្មើស ទោះបីជាគ្មានការចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ។[23] ចំណុចនេះបានន័យថា ចៅក្រមស៊ើបសួរ អាចបើកការស៊ើបសួរលើបុគ្គលផ្សេងដែលមិនមានអត្តសញ្ញាណ ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើប

[21] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា១២៤ កថាខណ្ឌទី៤។

[22] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៣១។

[23] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១២៦ កថាខណ្ឌទី២។

សួរបានដោយមិនចាំបាច់មាន ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ឬ មិនចាំបាច់សុំយោបល់ពីព្រះរាជអាជ្ញានោះទេ។ ហើយចៅក្រមស៊ើបសួរ អាចដាក់បុគ្គលនោះឱ្យស្ថិតនៅក្រោមការពិនិត្យក្នុងឋានៈជាចារី ជាអ្នកផ្ដើមគំនិត ឬ ជាអ្នកសមគំនិត។

ចៅក្រមស៊ើបសួរនៃសាលាដំបូង មានសិទ្ធិអំណាចក្នុងការស្រាវជ្រាវ ដូចជា៖

- ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ
- ការសួរចម្លើយជនត្រូវចោទ
- ការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី
- ការស្ដាប់ចម្លើយសាក្សី
- ការឆែកឆេរ និងការចាប់យកវត្ថុតាង
- ការធ្វើកោសលវិច្ច័យ
- ការស្ដាប់ទូរស័ព្ទ។

## ២.២. សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ

នៅក្នុងសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរនៃសាលាដំបូង ត្រូវបានបែងចែកជាពីរប្រភេទ គឺសមត្ថកិច្ចដែនដី និងសមត្ថកិច្ចតាមរឿងក្ដី។

### ២.២.១. សមត្ថកិច្ចដែនដី

ចៅក្រមស៊ើបសួរនៃសាលាដំបូង ដែលមានសមត្ថកិច្ចគឺ៖

- ចៅក្រមស៊ើបសួរនាទីកន្លែងបទល្មើស
- ចៅក្រមស៊ើបសួរនាទីលំនៅឋាន ឬទីសំណាក់របស់បុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស
- ចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួនបុគ្គលដែលសង្ស័យថា បានប្រព្រឹត្តបទល្មើស។

ក្នុងករណីដែលមានទំនាស់រវាងចៅក្រមស៊ើបសួរច្រើនរូប នៅសាលាដំបូងខុសគ្នា ហើយទទួលបណ្ដឹងទាំងអស់គ្នា អំពីរឿងព្រហ្មទណ្ឌតែមួយដូចគ្នា ទំនាស់នេះត្រូវបញ្ជូនទៅប្រធានសភាស៊ើបសួរដើម្បីសម្រេច។ ប្រសិនបើវិវាទសមត្ថកិច្ចដែនដី រវាងសភាស៊ើបសួរច្រើន ត្រូវសម្រេចដោយប្រធានតុលាការកំពូល។ ការសម្រេចនេះបិទផ្លូវតវ៉ា។[24] បទបញ្ញត្តិនេះចែងអំពីសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ ហើយនឹងកំណត់អំពីបញ្ហាក្នុងការដោះស្រាយនៅពេលដែលមានទំនាស់រវាងចៅក្រមស៊ើបសួរច្រើនទៅលើបណ្ដឹងតែមួយ ក៏ដូចជាវិវាទចំពោះសមត្ថកិច្ចសាលាដំបូងជាន់គ្នាផងដែរ។ បញ្ហាត្រង់ថាតើចៅក្រមស៊ើបសួរអាចប្រើប្រាស់អំណាចស្រាវជ្រាវបទល្មើសបានដែរឬទេ ប្រសិនបើជនត្រូវចោទមិនមានវត្តមានក្នុងដែនដីរបស់ខ្លួន។

[24] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា១២៣។

ជាងនេះទៅទៀត ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាក៏បានផ្តល់នូវសិទ្ធិពន្លាតសមត្ថកិច្ចជូនទៅចៅក្រមស៊ើបសួរបន្ថែមទៀត។ ចំពោះសមត្ថកិច្ចនេះដែរចៅក្រមស៊ើបសួរក៏អាចប្រើប្រាស់អំណាចទៅលើសមត្ថកិច្ចដែនដីដទៃទៀតបានប្រសិនបើជនត្រូវចោទមិនមានវត្តមាននៅលើដែនដីរបស់ខ្លួន។ ចៅក្រមស៊ើបសួរក៏អាចត្រូវបានប្រើប្រាស់អំណាចនេះដោយចេញដីកាចាត់ឱ្យស៊ើបសួរជំនួស ចំពោះដីកាចាត់ឱ្យស៊ើបសួរជំនួសនេះគឺត្រូវបានបែងចែកជាពីរ គឺការចាត់ឱ្យស៊ើបសួរសួរជំនួសចាត់ឱ្យចៅក្រមស៊ើបសួរផ្សេង និងដីកាចាត់ឱ្យស៊ើបសួរដែលចាត់ឱ្យមន្ត្រីនគរបាលយុត្តិធម៌។

**២.២.២ សមត្ថកិច្ចតាមរឿងក្តី**

ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់សមត្ថកិច្ចរបស់ស្ថាប័នអយ្យការ និងតុលាការតាមដំណាក់កាលនីមួយៗដោយឈរលើស្មារតីនៃគោលការណ៍បែងចែកមុខងាររបស់ស្ថាប័នតុលាអយ្យការ និងតុលាការដែលជាផលវិបាកចេញពីគោលការណ៍បែងចែកអំណាច។ ស្ថាប័នតុលាការពុំអាចប្តឹងមកដោយខ្លួនឯងផ្ទាល់ដើម្បីស៊ើបសួរ ឬវិនិច្ឆ័យបទល្មើសព្រហ្មទណ្ឌឡើយទោះបីជាតុលាការនោះបានដឹងដោយខ្លួនឯងផ្ទាល់នូវបទល្មើសនោះក៏ដោយ។ ដូច្នេះចៅក្រមស៊ើបសួរអាចស៊ើបសួរបានលុះត្រាតែត្រូវបានប្តឹងពីរឿងព្រហ្មទណ្ឌដោយព្រះរាជអាជ្ញា ឬ ជនរងគ្រោះដែលអាចបើកការស៊ើបសួរដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទៅចៅក្រមស៊ើបសួរ *(មានចង្អុល បង្ហាញក្នុងផ្នែកទី១ កថាខណ្ឌទី៣ ការបើកការស៊ើបសួរ)*។ ប៉ុន្តែការបើកស៊ើបសួរមិនមានលក្ខណៈចាំបាច់ ចំពោះការវិនិច្ឆ័យបទល្មើសនោះទេ។ ហេតុដូច្នេះការស៊ើបសួររបស់ចៅក្រមស៊ើបសួរចំពោះបទល្មើសទាំងបី ប្រភេទអាស្រ័យលើការប្តឹងពីព្រះរាជអាជ្ញាតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ អន្តរាគមន៍របស់គាត់ត្រូវធ្វើ ដោយខានមិនបានចំពោះបទឧក្រិដ្ឋ រីឯចំពោះបទមជ្ឈិម ការស៊ើបសួរអាចធ្វើក៏បាន ឬមិនធ្វើក៏បាន។[25] ចៅក្រម ស៊ើបសួរមានសមត្ថកិច្ចទៅលើគ្រប់បុគ្គលទាំងអស់លើកលែងតែរឿងព្រហ្មទណ្ឌជាសមត្ថកិច្ចរបស់តុលាការ។

[25] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១២២។

# ជំពូកទី២

# ចំណាត់ការរបស់ចៅក្រមស៊ើបសួរក្នុងការបើកការស៊ើបសួរ

# ជំពូកទី២
# ចំណាត់ការរបស់ចៅក្រមស៊ើបសួរក្នុងការបើកការស៊ើបសួរ

## ១. មូលហេតុដែលនាំឱ្យមានការបើកការស៊ើបសួរ

ការបើកការស៊ើបសួរ គឺជាដំណាក់កាលរបស់ចៅក្រមស៊ើបសួរ។ មុននឹងឈានដល់ការបើកការស៊ើបសួររបស់ចៅក្រមនោះ ជំហ៊ានដំបូងបង្អស់ដើម្បីចាប់ផ្ដើមបើកការស៊ើបសួរបាន គឺត្រូវមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលចេញដោយព្រះរាជអាជ្ញា។ ម៉្យាងវិញទៀត ការបើកការស៊ើបសួរ ក៏អាចប្រព្រឹត្តទៅបានតាមរយៈការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី បានផងដែរ។ ការដែលធ្វើការបើកកិច្ចស៊ើបសួរនេះឡើងមក គឺដើម្បីឱ្យចៅក្រមស៊ើបសួរ ត្រូវបំពេញកិច្ចធ្វើការស្រាវជ្រាវស្វែងរកឱ្យឃើញការពិត ដោយត្រូវស្វែងរកភស្តុតាង កំណត់បទល្មើសដាក់បន្ទុក ឬដោះបន្ទុកជនត្រូវចោទ និងសម្រេចឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្ន ឬសម្រេចឱ្យជនត្រូវចោទស្ថិតនៅក្រៅឃុំ ដែលអាចធានាបាននូវយុត្តិធម៌។ ដោយហេតុថា សំណុំរឿងមានភាពចាំបាច់ក្នុងការស្រាវជ្រាវបន្ថែម ដែលមានន័យថាសំណុំរឿងនោះមិនទាន់ មានធាតុផ្សំគ្រប់គ្រាន់ក្នុងការចោទប្រកាន់ ដែលមិនទាន់អាចធ្វើការបញ្ជូនទៅជំនុំជម្រះបាន។ ការបើកការស៊ើបសួរនេះ មានគោលបំណងឱ្យចៅក្រមស៊ើបសួរបំពេញកិច្ចស្រាវជ្រាវ ដើម្បីស្វែងរកភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុកទៅលើជនត្រូវចោទ។

ជារួមមក ការបើកការស៊ើបសួរ អាចធ្វើប្រព្រឹត្តទៅតាមរយៈការចេញដីការសន្និដ្ឋានឱ្យស៊ើបសួរ ដែលចេញដោយព្រះរាជអាជ្ញា ឬការដាក់ឱ្យមានចលនានៃបណ្ដឹងអាជ្ញាដោយជនរងគ្រោះ។ ការស៊ើបសួរ អាចបើកប្រឆាំងលើបុគ្គលម្នាក់ ឬច្រើននាក់ ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន។

ការបើកការស៊ើបសួរ ត្រូវតែធ្វើដោយខានមិនបានចំពោះបទឧក្រិដ្ឋ។ ចំពោះបទមជ្ឈិម ការស៊ើបសួរអាចធ្វើក៏បាន ឬ មិនធ្វើក៏បាន។[26] ជារួមមកមានន័យថា ចំពោះបទឧក្រិដ្ឋចាំបាច់ត្រូវតែធ្វើការបើកការស៊ើបសួររីឯបទមជ្ឈិមវិញ ធ្វើការបើកការស៊ើបសួរតែក្នុងករណីសំណុំរឿងមានភាពស្មុគស្មាញតែប៉ុណ្ណោះ។

### ១.១. ការបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (RI)

ក្រោយពីព្រះរាជអាជ្ញា បានពិនិត្យឃើញថាអង្គហេតុណាមួយនោះជាបទល្មើស ហើយបានបំពេញនៅលក្ខខណ្ឌដែលនាំឱ្យមានការបើកការស៊ើបសួរបាន នោះព្រះរាជអាជ្ញានឹងធ្វើការសម្រេចចិត្តចេញដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ទៅកាន់ចៅក្រមស៊ើបសួរ។ កាលដែលព្រះរាជអាជ្ញា ចេញដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះឡើងមក គឺដើម្បីធ្វើការស្នើសុំបើកការស៊ើបសួរទៅកាន់ចៅក្រមស៊ើបសួរ ដើម្បីឱ្យចៅក្រមស៊ើបសួរអាច

[26] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា១២២។

បើកកិច្ចស៊ើបសួរ ឡើងមកបាន។ ក្នុងការចេញដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ព្រះរាជអាជ្ញាត្រូវធ្វើតាមទម្រង់ដូចមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

ដីកាបញ្ជូនរឿងឱ្យស៊ើបសួរនេះមានចុះនិទ្ទេសដូចខាងក្រោម៖

- សេចក្តីសង្ខេបអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស
- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន។

ដីកាបញ្ជូនរឿងឱ្យស៊ើបសួរត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា។

ទម្រង់ការនេះមានលក្ខណៈដាច់ខាតត្រូវតែគោរព បើពុំដូច្នេះទេ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរនេះត្រូវទុកជាមោឃៈ។[27]

### ១.២. ការបើកការស៊ើបសួរតាមរយៈបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី

នៅពេលជនរងគ្រោះទាំងអស់ ដែលទទួលរងព្យសនកម្មអំពីបទល្មើសព្រហ្មទណ្ឌ ហើយបានដាក់បណ្តឹងរួចរាល់ តែត្រូវបានព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ នោះជនរងគ្រោះនឹងត្រូវបានបាត់បង់សិទ្ធិក្នុងការទាមទារសំណងជំងឺចិត្ត ឬធ្វើអោយបណ្តឹងរបស់ជនរងគ្រោះនោះមិនមានចលនា។ ដោយហេតុថា នៅពេលដែលព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ នាំឱ្យជនរងគ្រោះបានបាត់បង់នៅសិទ្ធិក្នុងការទាមទារសំណង បែបនេះ ទើបក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានដាក់បញ្ចូលនូវមាត្រាដែលបានកំណត់អំពី ការដាក់បណ្តឹងអាជ្ញាឱ្យមានចលនាដោយជនរងគ្រោះ។ ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចដាក់ពាក្យប្តឹងដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរ។[28] ពាក្យបណ្តឹងដែលមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ មានអានុភាពប្តឹងដល់ចៅក្រមស៊ើបសួរ អំពីបណ្តឹងអាជ្ញាដែលគេហៅថា **ការដាក់បណ្តឹងអាជ្ញាឱ្យមានចលនាដោយជនរងគ្រោះ**។

## ២. ដំណើរការក្នុងកិច្ចស៊ើបសួរនៅដំណាក់កាលសាលាដំបូងរាជធានី/ខេត្ត

### ២.១. វិធានការនិរន្តរាយ

វិធានការនិរន្តរាយមានន័យថា វិធី ឬមធ្យោបាយសម្រាប់ការពារប្រុងប្រយ័ត្នជាការមិនមានអន្តរាយដំណើរដែលគ្មានគ្រោះថ្នាក់។[29] ជាវិធានការដែលសំដៅដល់ ការចេញដីកាដែលអាចបណ្តាលឱ្យមាន ការចោទប្រកាន់

[27] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៤៤។

[28] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៥។

[29] វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត។

ការចាប់ខ្លួន ការឃាត់ខ្លួន និងការឃុំខ្លួន[30] ឬការដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដោយចៅក្រមស៊ើបសួរបង្គាប់ឱ្យជនសង្ស័យ ចូលមកតុលាការនៃសាលាដំបូងដើម្បីសាកសួរយកចម្លើយ តាមរយៈដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យចាប់ខ្លួន។ ចំណែកជនរងគ្រោះ ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវខាងរដ្ឋប្បវេណី ភាគីដែលពាក់ព័ន្ធនៅក្នុងរឿងក្ដី និងសាក្សី ត្រូវហៅមកសាកសួរដើម្បីយកព័ត៌មានតាមរយៈដីកាកោះ។ ក្នុងដំណាក់កាលនេះចៅក្រមស៊ើបសួរអាចចេញដីកាកោះ ដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន និងដីកាបង្គាប់ឱ្យចាប់ខ្លួន ទៅតាមករណីសមស្របនៃប្រភេទរឿងក្ដីនីមួយៗ។ នៅក្នុងករណីប្រសិនបើជនដែលចៅក្រមស៊ើបសួនកោះហៅ បានចូលខ្លួនមកហើយ ចៅក្រមស៊ើបសួរបើកកិច្ចស៊ើបសួរឃើញថា ចម្លើយជននោះមានភាពស៊ីសង្វាក់ទៅនឹងបទល្មើស ព្រមទាំងមានភស្តុតាងគ្រប់គ្រាន់ដើម្បីដាក់បន្ទុកជននោះចៅក្រមស៊ើបសួរក៏អាចចេញដីកាសម្រេចឃុំខ្លួនជននោះបានដែរ ដោយមានការស្នើសុំឱ្យចោទប្រកាន់ ឱ្យឃុំខ្លួនពីសំណាក់ព្រះរាជអាជ្ញាផងតាមនីតិវិធីដូចរៀបរាប់ក្នុងចំណុច(ការឃុំខ្លួនបណ្ដោះអាសន្ន)។ ក្នុងសេចក្ដីនៃដីកាត្រូវបញ្ជាក់ប្រាប់ឈ្មោះ ចៅក្រមស៊ើបសួរ គុណសម្បត្តិ និងហត្ថលេខារបស់ចៅក្រមនាម និងគោត្តនាម អត្រានុកូលដ្ឋានរបស់ជនជាប់ចោទ ភិនភាគរបស់ជនជាប់ចោទ និងឈ្មោះឪពុកម្ដាយរបស់ជនជាប់ចោទ ដើម្បីចៀសវាងការពិបាករកជននោះ ឬការយល់ច្រឡំទៅលើបុគ្គលផ្សេង។ (ដីកាមួយប្រើបានសម្រាប់តែបុគ្គលម្នាក់តែប៉ុណ្ណោះ)។

**២.១.១. ចំពោះជនត្រូវចោទ**

សំដៅទៅលើបុគ្គលណាម្នាក់ ដែលត្រូវបានព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ចំពោះរឿងក្ដីណាមួយក្នុងចន្លោះពេលមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅចៅក្រមស៊ើបសួរ រហូតដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬ ដីកាលើកលែងបោទប្រកាន់។[31] ជាបុគ្គលដែលត្រូវបានព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅចៅក្រមស៊ើបសួរ។ នៅដំណាក់កាលចៅក្រមស៊ើបសួរនៃសាលាដំបូង ជនដែលត្រូវបានចង្អុលបង្ហាញថាមានតម្រុយពិរុទ្ធភាពនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាត្រូវហៅថា ជនត្រូវចោទ ។

**២.១.១.១. ដីកាបង្គាប់ឱ្យចូលខ្លួន**

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យចូលខ្លួន។[32] ដីកាបង្គាប់ឱ្យចូលខ្លួន គឺជាបញ្ជាដល់បុគ្គលណាម្នាក់ឱ្យចូលទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។

[30] រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា, ប្រកាសឱ្យប្រើថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣, មាត្រា៣៨។

[31] សន្ទានុក្រមនៃវិជានផ្ទៃក្នុងអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា (វិសោធនកម្មលើកទី៩) នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥។

[32] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៨៦។

ដីកាបង្គាប់ឱ្យចូលខ្លួនអាចចេញទៅលើជនត្រូវចោទ ឬបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព។ ដីកាបង្គាប់ឱ្យចូលខ្លួនត្រូវមានចុះនិទ្ទេសដូចតទៅៈ[33]

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ
- ថ្ងៃ ខែ ឆ្នាំ ម៉ោង និងទីកន្លែងដែលត្រូវចូលបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា។

ដីកាបង្គាប់ឱ្យចូលខ្លួនត្រូវមានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។

ដីកាបង្គាប់ឱ្យចូលខ្លួនត្រូវឱ្យដំណឹងដល់បុគ្គលដែលពាក់ព័ន្ធដោយមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តធម៌ ឬដោយអាជ្ញាសាលា។ បុគ្គលដែលពាក់ព័ន្ធទទួលចុងដីកា ហើយត្រូវចុះហត្ថលេខានៅលើដើមដីកាដែលត្រូវបង្វិលជូនចៅក្រមស៊ើបសួរវិញ។ មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬដោយអាជ្ញាសាលាត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរអំពីគ្រប់ការលំបាកក្នុងការអនុវត្តបេសកកម្មរបស់ខ្លួន។[34] ចំពោះជនត្រូវចោទដែលត្រូវបានឃុំខ្លួន ត្រូវកោះហៅតាមរយៈប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន។[35]

ដីកានេះ ប្រើសម្រាប់កោះហៅជនជាប់សង្ស័យដែលព្រះរាជអាជ្ញាបានផ្ដើមចោទប្រកាន់។ ដីកាបង្គាប់ឱ្យចូលខ្លួនដាក់លក្ខខណ្ឌព្រមានដល់ជនជាប់ចោទថា បើមិនចូលខ្លួនតុលាការនឹងចាត់ការប្រើកម្លាំងសាធារណៈបង្ខំឱ្យចូលខ្លួន។ ជួនកាលដីកាបង្គាប់ឱ្យចូលខ្លួនអាចចេញបានម្ដងទៀតបើជនសង្ស័យមិនបានចូលខ្លួនតាមការបង្គាប់។

### ២.១.១.២. ដីកាបង្គាប់ឱ្យនាំខ្លួន

ប្រសិនបើដីកាបង្គាប់ឱ្យចូលខ្លួនត្រូវបានទទួលដោយត្រឹមត្រូវពីសំណាក់ជនត្រូវចោទ ហើយជននេះនៅតែរឹងទទឹងមិនព្រមចូលមកតុលាការតាមថ្ងៃ និងពេលកំណត់ទេនោះចៅក្រមស៊ើបសួរនៃសាលាដំបូង អាចចេញដីកាមួយទៀតហៅថា "ដីកាបង្គាប់ឱ្យនាំខ្លួន"។[36]

ចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឱ្យនាំខ្លួន។ ដីកាបង្គាប់ឱ្យនាំខ្លួន គឺជាបញ្ជាដល់កងកម្លាំងសាធារណៈឱ្យចាប់ខ្លួន និងនាំខ្លួនបុគ្គលណាម្នាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ។ ដីកាបង្គាប់ឱ្យចូលខ្លួនអាចត្រូវចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព។[37]

---

[33] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៨៧។

[34] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៨៤។

[35] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ២៣៣។

[36] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៨៩។

[37] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៩០។

ដីកាបង្គាប់ឱ្យនាំខ្លួនត្រូវមានចុះនិទ្ទេសដូចតទៅ៖[38]

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា។

ដីកាបង្គាប់ឱ្យនាំខ្លួនត្រូវមានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។

ការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួនត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌។ ក្នុងករណីបន្ទាន់ ដីកាបង្គាប់ឱ្យនាំខ្លួនត្រូវផ្សព្វផ្សាយដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ។ ដើមដីកានេះត្រូវប្រគល់ជូនជាបន្ទាន់ដល់មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបន្ទុកអនុវត្តដីកានេះ។ មន្ត្រីនគរបាលយុត្តិធម៌មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) បានទេ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹង ដល់ចៅក្រមស៊ើបសួរអំពីការលំបាកក្នុងការអនុវត្តបេសកកម្មរបស់ខ្លួន។[39]

ប្រសិនបើដោយមូលហេតុនៃកាលៈទេសៈ បុគ្គលដែលពាក់ព័ន្ធមិនអាចត្រូវនាំទៅបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរក្រោយពេលចាប់ខ្លួនបានទេ បុគ្គលនេះត្រូវតែនាំខ្លួនទៅក្នុងអង្គភាព នគរបាល ឬ កងរាជអាវុធហត្ថក្នុងមណ្ឌលឃុំខ្លួន ឬទៅក្នុងពន្ធនាគារ។ បុគ្គលនេះត្រូវតែ នាំខ្លួនទៅបង្ហាញខ្លួនយ៉ាងយូរផុតថ្ងៃបន្ទាប់ដល់ចៅក្រមស៊ើបសួរ ឬដល់អ្នកជំនួស។ ប្រសិនបើ ការបង្ហាញខ្លួនមិនបានប្រព្រឹត្តទៅនៅថ្ងៃបន្ទាប់ទេបុគ្គលពាក់ព័ន្ធត្រូវបានដោះលែងឱ្យមានសេរីភាពវិញ។[40]

ដីកានេះត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌។ នៅក្នុងករណីបន្ទាន់ត្រូវផ្សព្វផ្សាយដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ។ មន្ត្រីនគរបាលយុត្តិធម៌ មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលពាក់ព័ន្ធមុនម៉ោង ៦ ( ប្រាំមួយ និងក្រោយម៉ោង ១៨ (ដប់ប្រាំបី)បានទេ ហើយត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរអំពីការលំបាកក្នុងការអនុវត្តបេសកកម្មរបស់ខ្លួន ។ ក្រោយពេលចាប់ខ្លួនបាន ប្រសិនបើមិនអាចនាំទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរបានទេ ដោយមូលហេតុនៃកាលៈទេសៈ ត្រូវនាំបុគ្គលនោះទៅក្នុងអង្គភាពនគរបាលឬ កងរាជអាវុធហត្ថក្នុងមណ្ឌលឃុំខ្លួន ឬទៅក្នុងពន្ធនាគារ។ បុគ្គលនេះត្រូវតែនាំខ្លួនទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬអ្នកជំនួសយ៉ាងយូរថ្ងៃបន្ទាប់បើមិនដូច្នេះទេ ត្រូវដោះលែងឱ្យមានសេរីភាពវិញ។ ចិរវេលានៃការឃុំខ្លួននេះត្រូវគិតបញ្ចូលក្នុងចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន (ប្រសិនបើមាន)។

[38] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៩១។
[39] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៩២។
[40] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៩៣។

**២.១.១.៣. ដីកាបង្គាប់ឱ្យចាប់ខ្លួន**

ប្រសិនបើជនជាប់សង្ស័យមិនត្រូវបាននាំខ្លួនឱ្យចូលមកកាន់តុលាការនៃសាលាដំបូងទេ ដោយគេចខ្លួនបាត់ពីលំនៅឋាន ហើយច្បាប់ដើមនៃដីកាបង្គាប់ឱ្យនាំខ្លួនត្រូវបានផ្ញើត្រឡប់មកកាន់ចៅក្រមស៊ើបសួរវិញ ដោយភ្ជាប់ជាមួយក្រដាសសាវតារជាតិដែលមានចុះអត្តសញ្ញាណជនជាប់ចោទពេញលេញ នោះចៅក្រមស៊ើបសួរអាចចេញដីកាមួយទៀត គឺដីកាបង្គាប់ឱ្យចាប់ខ្លួនក្រោយពីមានសេចក្តីសន្និដ្ឋាន ឱ្យចាប់ខ្លួនពីព្រះរាជអាជ្ញា។[41]

តាមធម្មតា និងតាមបច្ចេកទេសសំណុំរឿងដែលមានជនជាប់ចោទបានគេចខ្លួនបាត់ មិនបានចូលមកបង្ហាញខ្លួនចំពោះមុខចៅក្រមស៊ើបសួរនៃសាលាដំបូងទេ និងពុំមានតម្រុយថាជននោះស្ថិតនៅទីណាទេ ចៅក្រមស៊ើបសួរមិនត្រូវទុកសំណុំរឿងរង់ចាំឱ្យយឺតយូរឡើយ ប្រសិនបើយល់ថាកិច្ចស៊ើបសួរ មូលគ្រប់គ្រាន់ហើយចៅក្រមស៊ើបសួរត្រូវធ្វើដីកាបញ្ជូនរឿងទៅពិនិត្យមូល (ដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យ) ដាក់ជូនទៅព្រះរាជអាជ្ញាពិនិត្យ ដើម្បីឱ្យព្រះរាជអាជ្ញាមានលទ្ធភាពសន្និដ្ឋានអំពីការចាប់ខ្លួនជនត្រូវចោទនោះ។ ដីកាបង្គាប់ឱ្យចាប់ខ្លួនអាចត្រូវចេញទៅលើជនត្រូវចោទ ឬបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព។ ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួនបានលុះត្រាតែ៖

១-បទល្មើសដែលចោទប្រកាន់ ជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។

២-បុគ្គលដែលពាក់ព័ន្ធបានគេចខ្លួនមិនដឹងជាស្ថិតនៅទីកន្លែងណា ឬស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

ដីកាបង្គាប់ឱ្យចាប់ខ្លួន គឺជាបញ្ជា៖

- ដល់កងកម្លាំងសាធារណៈឱ្យស្រាវជ្រាវរកចាប់ និងនាំខ្លួនបុគ្គលនោះទៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។
- ដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល និងឃុំខ្លួនបុគ្គលនោះ។[42]

មុននឹងចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ចៅក្រមស៊ើបសួរត្រូវតែទទួលយោបល់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរត្រូវចេញដីកានេះ (ដីកាបញ្ជូនឱ្យឆ្លើយ) ដោយមានចែងមូលហេតុក្រោយពីទទួលយោបល់ពីព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាធានារ៉ាប់រងផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន។ ដីកាបង្គាប់ឱ្យចាប់ខ្លួនមាននិទ្ទេសដូចតទៅ៖[43]

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់និងបង្ក្រាបបទល្មើសនេះ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា។

---

[41] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៩៥។

[42] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៩៦។

[43] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៩៧។

ដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវមានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។ ការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌។ ក្នុងករណីបន្ទាន់ដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវផ្សព្វផ្សាយដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ តាមគ្រប់មធ្យោបាយ។ ដើមដីកាត្រូវប្រគល់ក្នុងរយៈពេលខ្លីបំផុតឱ្យដល់មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបន្ទុកអនុវត្តដីកានោះ។

មន្ត្រីនគរបាលយុត្តិធម៌មិនអាចចូលទៅក្នុងលំនៅស្ថានរបស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) បានទេ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹង ដល់ចៅក្រមស៊ើបសួរ អំពីការលំបាកក្នុងការអនុវត្តបេសកកម្មរបស់ខ្លួន។ ក្នុងករណីចាំបាច់ដីកាបង្គាប់ឱ្យចាប់ខ្លួនអាចផ្សព្វផ្សាយជាអន្តរជាតិតាមរយៈក្រសួងយុត្តិធម៌ ដោយប្រើយន្តការនានាដែលមានប្រសិទ្ធភាព។[44]

ការបង្ហាញខ្លួនតាមដីកាបង្គាប់ឱ្យចាប់ខ្លួន ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវតែទទួល និងឃុំខ្លួនជនត្រូវចោទដែលជាកម្មវត្ថុនៃដីកាបង្គាប់ឱ្យចាប់ខ្លួន។ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនរក្សាទុកដើមដីកា ឬចុងដីកាដែលមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម។[45]

បុគ្គលដែលពាក់ព័ន្ធត្រូវតែបានគេនាំទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬអ្នកជំនួសចៅក្រមស៊ើបសួរក្នុងរយៈពេលយ៉ាងខ្លីបំផុតប្រសិនបើស្ថិតនៅក្នុងដំណាក់កាលស៊ើបសួរនៅឡើយ។

ប្រសិនបើការនាំខ្លួនទៅបង្ហាញនេះតម្រូវឱ្យមានការផ្ទេរបុគ្គលពាក់ព័ន្ធទៅពន្ធនាគារ ឬទៅមណ្ឌលឃុំខ្លួនមួយផ្សេងទៀត ការផ្ទេរនេះត្រូវចាត់ចែងដោយអយ្យការ។

ប្រសិនបើបុគ្គលដែលពាក់ព័ន្ធមិនត្រូវបានគេនាំខ្លួនទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬអ្នកជំនួសចៅក្រមស៊ើបនៅថ្ងៃបន្ទាប់ពីការចាប់ខ្លួនបុគ្គលនេះត្រូវតែបានព្រះរាជអាជ្ញានាទីកន្លែងឃុំខ្លួន ស្តាប់ចម្លើយ។ ព្រះរាជអាជ្ញានេះធ្វើកំណត់ហេតុស្តាប់ចម្លើយដែលត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរនៃសាលាដំបូង។

### ❖ ការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន

ដីកាបង្គាប់ឱ្យចាប់ខ្លួន ត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌។ នៅក្នុងករណីបន្ទាន់ដីកានេះត្រូវផ្សព្វផ្សាយទៅតាមអង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ ។ មន្ត្រីនគរបាលមិនអាចចូល ក្នុងលំនៅឋានរបស់បុគ្គលពាក់ព័ន្ធមុនម៉ោង ៦ (ប្រាំមួយ) និងក្រោយ 12 ម៉ោង ១៨ ( ដប់ប្រាំបី )បានទេ ហើយត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរ អំពីការលំបាកក្នុងការអនុវត្តបេសកកម្មរបស់ខ្លួន។ក្នុងករណីចាំបាច់ ដីកានេះអាចផ្សព្វផ្សាយជាអន្តរជាតិ តាមរយៈក្រសួងយុត្តិធម៌ដោយបើយន្តការនានាដែលមានប្រសិទ្ធភាព។

[44] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៩៨។
[45] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៩៩។

ក្រោយពេលចាប់ខ្លួនបាន ត្រូវនាំបុគ្គលនោះទៅបង្ហាញចៅក្រម ស៊ើបសួរ ឬអ្នកជំនួសក្នុងរយៈពេលយ៉ាងខ្លីបំផុត ប្រសិនបើស្ថិតនៅក្នុង ដំណាក់កាលស៊ើបសួរនៅឡើយ ។

ប្រសិនបើមិនបាននាំខ្លួនទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬអ្នកជំនួសនៅថ្ងៃបន្ទាប់ពីការចាប់ខ្លួនទេ បុគ្គលនោះត្រូវតែបានព្រះរាជអាជ្ញានាទីកន្លែងឃុំខ្លួនស្តាប់ចម្លើយ ដោយធ្វើកំណត់ហេតុបញ្ជូនទៅចៅក្រមស៊ើបសួរ។ ចិរវេលានៃការឃុំខ្លួននេះ ត្រូវគិតបញ្ចូលក្នុងចិរវេលានៃការ ឃុំខ្លួនបណ្តោះអាសន្ន( ប្រសិនបើមាន )។ នៅពេលដែលជនត្រូវចោទបានជួបចៅក្រមស៊ើបសួរហើយ ដីកាចាប់ខ្លួនលែងមានអានុភាព ហើយបើចង់ឃុំខ្លួនបុគ្គលនេះទៀតគឺត្រូវប្រើវិធានផ្សេង ( ដីកាឃុំខ្លួនបណ្តោះអាសន្ន និងដីកាបង្គាប់ឱ្យឃុំខ្លួន)។

**២.១.១.៤. ការឃុំខ្លួនបណ្តោះអាសន្ន**

ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានមួយដែលផ្តល់អំណាចធំបំផុតដល់ចៅក្រមស៊ើបសួរ។ ប៉ុន្តែវិធានការនេះវាបានធ្វើឱ្យប៉ះពាល់ដល់សេរីភាពរបស់ជនត្រូវចោទ ជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព ក្នុងករណីពិសេស ជនត្រូវចោទអាចត្រូវឃុំខ្លួនបណ្តោះអាសន្ន[46] ដើម្បីឱ្យការស៊ើបសួរប្រព្រឹត្តទៅបានល្អ ហើយការឃុំខ្លួនបុគ្គលណាមួយអាចធ្វើទៅបានលុះត្រាតែមានសេចក្តីសម្រេចជាស្ថាពររបស់តុលាការ។

ជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព លើកលែងតែក្នុងតែករណីពិសេស ជនត្រូវចោទអាចត្រូវឃុំខ្លួនបណ្តោះអាសន្ន នៅក្នុងលក្ខខណ្ឌដែលបានចែងនៅក្នុងផ្នែកទី ៥ ជំពូកទី៣ មាតិកាទី១ គន្ថីទី៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចាប់ពីមាត្រា២០៣ ដល់ មាត្រា២១៨។

ដើម្បីអនុវត្តនូវវិធានការនៃការឃុំខ្លួនបណ្តោះអាសន្នបាន ត្រូវតែគោរពនូវលក្ខខណ្ឌដាច់ខាតមួយចំនួន។ ជានិច្ចកាល ការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើបាន លុះត្រាតែជនត្រូវចោទដែលជាកម្មវត្ថុនៃការឃុំខ្លួនបណ្តោះអាសន្ននោះ ត្រូវបានទទួលរងនូវការចោទប្រកាន់ពីបទឧក្រិដ្ឋ។ ចំពោះបទមជ្ឈិមវិញ ការឃុំខ្លួនបណ្តោះអាសន្ននោះអាចធ្វើបាន លុះតែជនត្រូវចោទដែលជាកម្មវត្ថុនៃការឃុំខ្លួនបណ្តោះអាសន្ននោះ ត្រូវបានទទួលរងនូវការចោទប្រកាន់ពីបទមជ្ឈិមដែលច្បាប់កំណត់ចិរវេលានៃការផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១ (មួយ) ឆ្នាំ។ រយៈពេលស្មើ ឬលើសពី ១ (មួយ) ឆ្នាំនេះ សំដៅដល់អតិបរិមានៃទោសនីមួយៗ ដែលមានបញ្ញត្តិក្នុងច្បាប់។

យោងតាមការវិភាគលើផ្នែកទី៥ ស្តីពីការឃុំខ្លួនបណ្តោះអាសន្ននេះឃើញថា ការអនុវត្តវិធាននៃការឃុំខ្លួនបណ្តោះអាសន្ននេះ មិនអាចអនុវត្តបានឡើយ ចំពោះករណីដូចខាងក្រោម ៖

- បទល្មើសលហុ
- បទល្មើសមជ្ឈិម ដែលមានទណ្ឌកម្មពិន័យជាប្រាក់ ឬមានទណ្ឌកម្មដាក់ពន្ធនាគារតិចជាង ១ (មួយ) ឆ្នាំ

[46] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ២០៣។

- បុគ្គលដែលរងការចោទប្រកាន់ជាអនីតិជនអាយុក្រោមជាង ១៤ (ដប់បួន) ឆ្នាំ មិនត្រូវបានឃុំខ្លួនបណ្ដោះអាសន្នឡើយ [47] ប៉ុន្តែចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននោះឱ្យឪពុកម្ដាយអ្នកអាណាព្យាបាល ឬក្នុងករណីគ្មានអាណាព្យាបាល ត្រូវប្រគល់មជ្ឈមណ្ឌលអប់រំថែរក្សាបណ្ដោះអាសន្ន រងចាំសេចក្ដីសម្រេចរបស់តុលាការ។

❖ **មូលហេតុនៃការឃុំខ្លួន**

សេរីភាពជនត្រូវចោទជាគោលការណ៍ ហេតុនេះការឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្ន ត្រូវតែជាករណីលើកលែង។ ហេតុនេះ ការឃុំខ្លួនបណ្ដោះអាសន្នអាចធ្វើទៅបានលុះត្រាតែគោរពទៅតាមមូលហេតុដូចកំណត់ក្នុងក្រម ពោលគឺ ការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវតែមានសំអាងហេតុ យោងតាមបទប្បញ្ញត្តិមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌស្តីអំពីមូលហេតុនៃការឃុំខ្លួននេះ ដែលជាករណីពិសេស និងជាភាពចាំបាច់ ដើម្បី ៖

១-បញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី ។

២-រារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ។

៣-រារាំងកុំឱ្យមានការត្រូវរ៉ូវគ្នា រវាងជនត្រូវចោទ និងអ្នកសមគំនិត។

៤-រក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ។

៥-ធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី។

៦-ការពារសន្តិសុខឱ្យជនត្រូវចោទ។

៧-ធានារក្សាសណ្ដាប់ធ្នាប់សាធារណៈ កុំឱ្យមានការច្របូកច្របល់ ដែលបណ្ដាលមកពីបទល្មើស។

តាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា អាចផ្ដើមដោយគំនិតផ្ទាល់ខ្លួនរបស់ចៅក្រមស៊ើសួរ ឬតាមសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា (យោងតាមក្រមនេះ ដើមបណ្ដឹងរដ្ឋប្បវេណីមិនអាចប្ដឹងសុំវិធាននេះដោយផ្ទាល់ទៅក្រមស៊ើបសួរ ប៉ុន្តែអាចឡើងតាមរយៈព្រះរាជអាជ្ញា) ហើយត្រូវឱ្យដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជននេះ និងឱ្យមេធាវីបង្ហាញមធ្យោបាយការពារខ្លួន បើសិនជាមាន។ ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ត្រូវតែមានសំអាងហេតុ ដោយយោងតាមបញ្ញត្តិមាត្រា ២០៥ ស្ដីពីមូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន ។ យោងតាមដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ននេះ ចៅក្រមស៊ើបសួរ ត្រូវចេញដីកាបង្គាប់ឱ្យឃុំខ្លួន ដែលជាបញ្ជាដល់ប្រធានពន្ធនាគារឱ្យទទួល និងឃុំខ្លួនជនត្រូវចោទ។ ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្ននេះ ត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ។

[47] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, លេខ នស/រកម/០៧១៦/០០៩, ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦, មាត្រា ៣៩។

### ❖ ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន

ប្រសិនបើចៅក្រមស៊ើបសួរសម្រេចថាឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្ន ការឃុំខ្លួនជាបណ្ដោះអាសន្ននេះត្រូវស្ថិតក្នុងថិរវេលាដែលកំណត់ដោយច្បាប់។ ថិរវេលានេះប្រែប្រួលទៅតាមប្រភេទនៃបទល្មើសចោទប្រកាន់ និងអាយុរបស់ជនត្រូវចោទឃុំខ្លួន ។

ក្នុងករណីមានការជាប់ចោទពីបទល្មើសឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋប្រល័យពូជសាសន៍ ឬបទឧក្រិដ្ឋសង្គ្រាម ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ១ (មួយ) ឆ្នាំបានទេ ចំពោះបទល្មើសនីមួយៗ។ ប៉ុន្តែនៅពេលផុតថេរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្ដោះអាសន្នម្ដងបាន ១ (មួយ)ឆ្នាំ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។ ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យពន្យារការឃុំខ្លួនបណ្ដោះអាសន្ននេះបានតែ ២ (ពីរ) ដងគត់។[48]

ជាប់ចោទពីបទឧក្រិដ្ឋ៖

- ចំពោះជនត្រូវចោទជានីតិជនដែលត្រូវជាប់ចោទពីបទឧក្រិដ្ឋ រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៦ (ប្រាំមួយ) ខែបានទេ។ ហើយអាចពន្យារពេលបាន ៦ (ប្រាំមួយ) ខែទៀត ចំនួនពីរដង។[49]

- ចំពោះជនត្រូវចោទជាអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន មិនអាចលើសពី ៤ (បួន) ខែ បានទេ កាលណាអនីតិជននេះ មានអាយុតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ។[50]

- ជនត្រូវចោទជាអនីតិជនអាយុចាប់ពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ៖ រយៈពេលការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៦ (ប្រាំមួយ) ខែ បានទេ កាលណាអនីតិជននេះ មានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ។[51]

ជាប់ចោទពីបទមជ្ឈិម ៖

- ជនត្រូវចោទជានីតិជន ៖ រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្នគឺ ៤ (បួន)ខែ ហើយអាចពន្យារពេលបាន ២ (ពីរ) ខែ ទៀត តែម្ដងគត់ ហើយទោះជាយ៉ាងណារយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ននេះ ពុំអាចលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ (មាត្រា ២០៩)។

ឧ. ជនត្រូវចោទជាប់ចោទពី បទអំពើលួច ដែលតាមច្បាប់ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ)ខែ ដល់ ៣(បី)ឆ្នាំ (មាត្រា ៣៥៦នៃក្រមព្រហ្មទណ្ឌ)។ អប្បបរមានៃទោសគឺ ៦(ប្រាំមួយ)ខែ។ ពាក់កណ្ដាលនៃអប្បរមា

[48] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ២១០។

[49] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ២០៨។

[50] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ២១៣។

[51] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ២១៣។

គឺ ៣(បី)ខែ ។ ហេតុនេះមានន័យថាការឃុំខ្លួនជាបណ្តោះអាសន្ន មិនត្រូវឱ្យលើសពី ៣(បី)ខែឡើយ។ ចំណែកឯបទល្មើស ទទួលផលចោរកម្ម វិញត្រូវបានច្បាប់ កំណត់ទោសដាក់ពន្ធនាគារពី ២(ពីរ)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ (មាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ) ហេតុនេះពាក់កណ្តាលនៃអប្បបរមានៃទោសគឺ ១(មួយ)ឆ្នាំ។ ដូច្នេះមានន័យថាការឃុំខ្លួនជាបណ្តោះអាសន្នគឺ ៤(បួន)ខែ ហើយចៅក្រមស៊ើបសួរអាចពន្យារពេលបានបន្ថែម ២(ពីរ)ខែទៀតតែម្តងគត់ ជាសរុបគឺមិនឱ្យលើសពី ៦(ប្រាំមួយ)ខែឡើយ ក្នុងករណីនេះ ៦(ប្រាំមួយ)ខែ គឺតិចជាង ១ឆ្នាំ ដែលជាចំនួនពាក់កណ្តាលនៃអប្បបរមានៃទោសដែលកំណត់ដោយ ច្បាប់សម្រាប់បទទទួលផលចោរកម្ម)។

- ជនត្រូវចោទជាអនីតិជនអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ ៖ រយៈពេល នៃការឃុំខ្លួនបណ្តោះអាសន្ន មិនអាចលើសពី ពីរខែ បានទេ (មាត្រា ២១៤) ហើយ ទោះជាយ៉ាងណារយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ននេះ ពុំអាចលើសពីពាក់កណ្តាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ។

- ជនត្រូវចោទជាអនីតិជនអាយុចាប់ពី ១៦ឆ្នាំ ដល់ ១៨ឆ្នាំ ៖ រយៈពេលនៃការ ឃុំខ្លួនបណ្តោះអាសន្ន មិនអាចលើសពី ៤ខែ បានទេ (មាត្រា ២១៤) ហើយទោះជា យ៉ាងណារយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ននេះ ពុំអាចលើសពីពាក់កណ្តាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ។

❖ **ការស្នើសុំឱ្យនៅក្រៅឃុំ**

ជនត្រូវចោទអាចដាក់ពាក្យសុំឱ្យដោះលែងនៅក្រៅឃុំគ្រប់ពេលវេលា។ បន្ទាប់ពីទទួល បានពាក្យស្នើសុំនៅក្រៅឃុំនេះហើយ ចៅក្រមស៊ើបសួរត្រូវបញ្ជូនពាក្យសុំនោះភ្លាមទៅព្រះរាជអាជ្ញា ដើម្បីផ្តល់យោបល់ និងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ។ ក្រោយពីបានទទួលរួចហើយ ព្រះរាជអាជ្ញាត្រូវផ្តល់យោបល់ក្នុងរយៈពេលខ្លីបំផុត ប៉ុន្តែក្រមនីតិវិធីព្រហ្មទណ្ឌពុំបានកំណត់នូវរយៈពេលនេះទេ គ្រាន់តែកំណត់រយៈពេលនៃការសម្រេចដោយចៅក្រមស៊ើបសួរ។ ចៅក្រមស៊ើបសួរសម្រេចឃុំឃាំងយូរបំផុតក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃបន្ទាប់ពីបញ្ជូនរឿងទៅព្រះរាជអាជ្ញា។

ប្រសិនបើចៅក្រមស៊ើបសួរបដិសេធពាក្យសុំនៅក្រៅឃុំរបស់ខ្លួន ជនត្រូវចោទអាចដាក់ពាក្យសុំនៅក្រៅឃុំជាថ្មីម្តងទៀតទៅចៅក្រមស៊ើបសួរដដែល ឬទៅសភាស៊ើបសួរក្នុងរយៈពេល ១(មួយ)ខែ បន្ទាប់ពីសេចក្តីសម្រេចបដិសេធពាក្យសុំលើកមុន។ ក្រោយពីបានទទួលពាក្យសុំជាថ្មីម្តងទៀត ចៅក្រមស៊ើបសួរត្រូវសម្រេចលើពាក្យសុំនេះក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ បន្ទាប់ពីទទួល។ រីឯសភាស៊ើបសួរ ក្រោយពីបានទទួលពាក្យស្នើសុំនៅក្រៅឃុំរបស់ជនត្រូវចោទហើយត្រូវសម្រេចក្នុងរយៈពេល ៥(ប្រាំ) ថ្ងៃ ដូចចៅក្រមស៊ើបសួរដែរ។

ប៉ុន្តែបើសិនជា ចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃទេ ជនត្រូវចោទ អាចដាក់ពាក្យប្តឹងដោយផ្ទាល់ទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។

ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំអាចធ្វើឡើងដោយចៅក្រមស៊ើបសួរតាមសំណើរបស់ព្រះរាជអាជ្ញា និងតាមការស្នើសុំរបស់ជនជាប់ចោទ។

កាលណាចៅក្រមស៊ើបសួរយល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្នលែងមានភាពចាំបាច់ មានន័យថា បញ្ញត្តិនៃមាត្រា ២០៥ (ហេតុផលសម្រាប់ការឃុំខ្លួនបណ្តោះអាសន្ន) លែងមានភាពចាំបាច់ ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំវិញបានគ្រប់ពេលវេលា ដោយផ្តល់ជូនព័ត៌មានដល់ព្រះរាជអាជ្ញា ដើម្បីសុំយោបល់ ហើយបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ។ ព្រះរាជអាជ្ញាត្រូវតែផ្តល់យោបល់របស់ខ្លួនឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ ចៅក្រមស៊ើបសួរត្រូវសម្រេចមិនលើសពី ៥(ប្រាំ)ថ្ងៃ បន្ទាប់ពីសំណុំរឿងបញ្ជូនទៅព្រះរាជអាជ្ញា។

ក្នុងករណីបន្ទាន់ចៅក្រមស៊ើបសួរ អាចបង្គាប់ឱ្យដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំភ្លាមៗ ដោយមិនបាច់ពិគ្រោះជាមួយព្រះរាជអាជ្ញា ដូចជាជនត្រូវចោទមានជម្ងឺធ្ងន់ធ្ងរត្រូវព្យាបាលនៅខាងក្រៅ។ ប៉ុន្តែត្រូវចុះមូលហេតុនៃការបន្ទាន់នេះក្នុងដីការបស់ខ្លួន។

### ❖ ក្នុងករណីបណ្តឹងសុំនៅក្រៅឃុំដោយព្រះរាជអាជ្ញា

ទោះបីជាក្នុងដំណាក់កាលស៊ើបសួរក៏ដោយ ក៏ព្រះរាជអាជ្ញាអាចមានវត្តមាននៅក្នុងការសួរចម្លើយជនត្រូវចោទ ក្នុងការសួរតទល់ និងក្នុងការស្តាប់ចម្លើយបានដែរ។ មិនត្រឹមតែប៉ុណ្ណោះព្រះរាជអាជ្ញាអាចសុំឱ្យជនត្រូវចោទនៅក្រៅឃុំបានគ្រប់ពេលវេលា ទៅចៅក្រមស៊ើបសួរ ដែលត្រូវសម្រេចក្នុងរយៈពេល៥(ប្រាំ)ថ្ងៃ។

ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្តឹងទៅសភាស៊ើបសួរដែលត្រូវសម្រេចជំនួសចៅក្រមស៊ើបសួរក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ។ ដីកាសម្រេចមិនព្រមដោះលែងត្រូវមានសម្អាងហេតុ។

### ❖ ក្នុងករណីបណ្តឹងសុំនៅក្រៅឃុំរបស់ជនត្រូវចោទ

ជនត្រូវចោទអាចដាក់ពាក្យសុំទៅចៅក្រមស៊ើបសួរ ឱ្យដោះលែងនៅក្រៅឃុំបានគ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរបញ្ជូនពាក្យនោះ និងសំណុំរឿងភ្លាមទៅព្រះរាជអាជ្ញាពិនិត្យដើម្បីផ្តល់យោបល់ក្នុងរយៈពេលខ្លីបំផុត។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុត ៥(ប្រាំ)ថ្ងៃ បន្ទាប់ពីពេលបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។

ប្រសិនបើចៅក្រមបដិសេធ ជនត្រូវចោទអាចដាក់ពាក្យសុំនៅក្រៅឃុំសាជាថ្មីម្តងទៀតទៅចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរក្នុងរយៈ ពេល ១( មួយ )ខែ បន្ទាប់ពីមានសេចក្តីសម្រេចបដិសេធពាក្យសុំលើកមុន។ ចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំ។ ដីកាសម្រេចមិនព្រមដោះលែងត្រូវមានសម្អាងហេតុ ។

ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេជនត្រូវចោទអាចធ្វើពាក្យប្តឹងផ្ទាល់ទៅសភាស៊ើបសួរ ដែលត្រូវសម្រេចក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃជំនួសចៅក្រមស៊ើបសួរ។ ប្រសិនបើចៅក្រមស៊ើបសួរយល់ព្រម ចៅក្រមស៊ើបសួរអាចដោះលែង ឬដាក់ជននោះឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបាន។ ជាគោលការណ៍សេចក្តីសម្រេចឱ្យនៅក្រៅឃុំ មិនអាចយកទៅអនុវត្តបានភ្លាមទេ គឺត្រូវទុកឱ្យផុតរយៈពេលប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាសិន។ លើកលែងតែព្រះរាជអាជ្ញា យល់ព្រមជាលាយលក្ខណ៍អក្សរ និង ករណីបន្ទាន់ប៉ុណ្ណោះទើបអាចដោះលែងភ្លាមបាន។

ក្នុងករណីព្រះរាជអាជ្ញាប្តឹងឧទ្ធរណ៍ ជនត្រូវចោទត្រូវរក្សាទុកនៅក្នុងឃុំដើម្បីរង់ចាំសេចក្តីសម្រេចរបស់សភាស៊ើបសួរ។ ជាគោលការណ៍ច្បាប់មិនបានចែងអំពីការធានាឱ្យនៅក្រៅឃុំទេ។ប៉ុន្តែមានមូលហេតុដែលចែងក្នុងមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន)។

ជនត្រូវចោទអាចដាក់ពាក្យសុំឱ្យដោះលែងនៅក្រៅឃុំគ្រប់ពេលវេលា។ បន្ទាប់ពីទទួល បានពាក្យស្នើសុំនៅក្រៅឃុំនេះហើយ ចៅក្រមស៊ើបសួរត្រូវបញ្ជូនពាក្យសុំនោះភ្លាមទៅព្រះរាជអាជ្ញា ដើម្បីផ្តល់យោបល់ និងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ។ ក្រោយពីបានទទួលរួចហើយ ព្រះរាជអាជ្ញាត្រូវផ្តល់យោបល់ក្នុងរយៈពេលខ្លីបំផុត ប៉ុន្តែក្រមនីតិវិធីព្រហ្មទណ្ឌពុំបានកំណត់នូវរយៈពេលនេះទេ គ្រាន់តែកំណត់រយៈពេលនៃការសម្រេចដោយចៅក្រមស៊ើបសួរ។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃបន្ទាប់ពីបញ្ជូនរឿងទៅព្រះរាជអាជ្ញា។

ប្រសិនបើចៅក្រមស៊ើបសួរបដិសេធពាក្យសុំនៅក្រៅឃុំរបស់ខ្លួន ជនត្រូវចោទអាចដាក់ពាក្យសុំនៅក្រៅឃុំជាថ្មីម្តងទៀតទៅចៅក្រមស៊ើបសួរដដែល ឬទៅសភាស៊ើបសួរក្នុងរយៈពេល ១(មួយ)ខែ បន្ទាប់ពីសេចក្តីសម្រេចបដិសេធពាក្យសុំលើកមុន។ ក្រោយពីបានទទួលពាក្យសុំជាថ្មីម្តងទៀត ចៅក្រមស៊ើបសួរត្រូវសម្រេចលើពាក្យសុំនេះក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ បន្ទាប់ពីទទួល។ រីឯសភាស៊ើបសួរ ក្រោយពីបានទទួលពាក្យស្នើសុំនៅក្រៅឃុំរបស់ជនត្រូវចោទហើយត្រូវសម្រេចក្នុងរយៈពេល ៥(ប្រាំ) ថ្ងៃ ដូចចៅក្រមស៊ើបសួរដែរ។

ប៉ុន្តែបើសិនជា ចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃទេ ជនត្រូវចោទ អាចដាក់ពាក្យប្តឹងដោយផ្ទាល់ទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។

❖ **ការសម្រេចអំពីពាក្យស្នើសុំ (យល់ព្រម/មិនយល់ព្រម)**

ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំវិញបានគ្រប់ពេលវេលា។ កាលណាចៅក្រមស៊ើបសួរ មានបំណងដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំនោះ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញាដើម្បីសុំយោបល់ ហើយបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ បន្ទាប់មកព្រះរាជអាជ្ញាត្រូវផ្តល់យោបល់របស់ខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុត។ ចៅក្រមស៊ើបសួរ សម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ

បន្ទាប់ពីការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ក្នុងករណីបន្ទាន់ចៅក្រមស៊ើបសួរ អាចបង្គាប់ឱ្យដោះលែងជនត្រូវចោទភ្លាមដោយមិនរង់ចាំយោបល់របស់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរត្រូវចង្អុលប្រាប់មូលហេតុនៃការដោះលែងបន្ទាន់នេះ នៅក្នុងដីកាម្រេចរបស់ខ្លួន[52]។

កាលណាចៅក្រមស៊ើបសួរសម្រេចឱ្យដោះលែងជនត្រូវចោទ ដែលជាប់ឃុំខ្លួនបណ្ដោះអាសន្ន ជនត្រូវចោទនោះ ត្រូវបានរក្សាទុកនៅក្នុងពន្ធនាគារ រហូតដល់ផុតរយៈពេលសម្រាប់បណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា លើកលែងតែព្រះរាជអាជ្ញាយល់ព្រមឱ្យដោះលែងជនត្រូវចោទនោះភ្លាម។ សេចក្ដីសម្រេចជាលាយលក្ខណ៍អក្សររបស់ព្រះរាជអាជ្ញា ត្រូវដាក់បញ្ចូលក្នុងសំណុំរឿងនៃនីតិវិធី។[53] ដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំត្រូវតែជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។

ដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំត្រូវតែជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន បទប្បញ្ញត្តិនៃមាត្រា ២៧៦ (ការដោះលែងជនត្រូវចោទដែលជាប់ឃុំឱ្យមានសេរីភាព) នៃក្រមនេះត្រូវយកមកអនុវត្ត។ ដីកាមិនព្រមដោះលែងឱ្យនៅក្រៅឃុំ ត្រូវតែជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ កាលណាចៅក្រមស៊ើបសួរ សម្រេចឱ្យដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ ចៅក្រមនេះអាចដាក់ជននោះឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ២២៣ (កាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ) ដល់មាត្រា ២៣០ (ការគេចវេះរបស់ជន ត្រូវចោទពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ) នៃក្រមនេះ។[54]

### ២.១.១.៥. ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ជាវិធានការនិរន្តរាយមួយ ដូចករណីនៃការឃុំខ្លួនបណ្ដោះអាសន្នដែរ គ្រាន់តែវាជាវិធានមួយដែលមានស្ថានភាពស្រាលជាង។ ដោយចៅក្រមស៊ើបសួរ ត្រូវតែដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ នូវបុគ្គលដែលមានចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ចៅក្រមស៊ើបសួរមានអំណាចដាក់ឱ្យស្ថិតក្រោមការពិនិត្យនូវបុគ្គលគ្រប់រូបដែលមានតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់គ្នាខ្លាំងថា បានចូលរួមប្រព្រឹត្តបទល្មើស ទោះបីជាគ្មានការចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ។ ចៅក្រមស៊ើបសួរ អាចដាក់បុគ្គលនោះឱ្យស្ថិតក្រោមការពិនិត្យក្នុងឋានៈជា ចារី ជាអ្នកផ្ដើមគំនិត ឬ ជាអ្នកសមគំនិត។[55] ចៅក្រមស៊ើបសួរបង្គាប់ជនត្រូវចោទដែលនៅក្រៅឃុំឱ្យគោរពនូវកាតព្វកិច្ចមួយ ឬច្រើនដូចបានកំណត់ក្នុងបទប្បញ្ញត្តិមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

[52] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ២១៥។
[53] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ២៧៦។
[54] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ២១៦។
[55] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១២៦។

យោងតាមការពិនិត្យលើខ្លឹមសារនៃមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ក៏អាចកំណត់បានថាការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ គឺជាវិធានមួយដែលមានកម្មវត្ថុដាក់ជនត្រូវចោទឱ្យស្ថិតក្រោមការរឹតបន្តឹងខាងសេរីភាពមួយចំនួនតាមរយៈកាតព្វកិច្ច ឬការហាមឃាត់ដែល កំណត់ដោយច្បាប់ ដែលវិធាននេះត្រូវបានចងក្រងក្រោមគោលដៅ ៤ ផ្សេងគ្នា ៖

-ធានានូវការបង្ហាញខ្លួនរបស់ជនត្រូវចោទ

-គោរពនូវវិធានផ្សេងៗដែលសំដៅលប់បំបាត់ពីជីវិតរបស់ជនត្រូវចោទនូវធាតុមួយចំនួន

-ដាក់កំហិតនូវការព្យាបាលខាងផ្នែកសង្គម និងផ្នែកវេជ្ជសាស្ត្រ

-ត្រូវចេញបញ្ញត្តិផ្សេងៗ ដើម្បីធានាឱ្យបាននូវសិទ្ធជនរងគ្រោះ

អាចមានការភ័ន្តច្រឡំខ្លះទាក់ទងទៅនឹងវិធានខាងលើនេះ ជាពិសេសត្រង់ចំណុចទី៩ នៃមាត្រា ២២៣ ដែលបញ្ញត្តិអំពីកាតព្វកិច្ចមួយ ដែលតម្រូវឱ្យជនត្រូវចោទដាក់ប្រាក់ធានា។ ត្រង់ចំណុចនេះ មានមតិខ្លះថាការបង្គាប់ឱ្យជនត្រូវចោទដាក់ប្រាក់ធានា គួរទាមទារឱ្យមានស្ថាប័នជំនាញធ្វើការវាយតម្លៃទៅលើកាលៈទេសៈមួយចំនួនដែលពាក់ព័ន្ធទៅនឹងបទល្មើសដែលបានកើតឡើង ដើម្បីកំណត់អំពីចំនួនទឹកប្រាក់ដែលត្រូវដាក់ធានានោះ។ ឧទាហរណ៍ ពាក់ព័ន្ធនឹងបទបង្ករបួសដោយចេតនា គឺតម្រូវឱ្យគ្រូពេទ្យវាយតម្លៃអំពីស្ថានភាពរបួសជាមុនសិន ដើម្បីឱ្យដឹងអំពីទំហំព្យសនកម្ម (ទំហំនៃសំណងការព្យាបាលរបួស) ក្នុងគោលបំណងឱ្យជនត្រូវចោទដាក់ប្រាក់ធានាឱ្យធួនល្មមនឹងសំណងផ្នែករដ្ឋប្បវេណីនៃព្យសនកម្មដែលកើតឡើងនោះ។

### ២.១.២. ចំពោះដើមបណ្តឹងរដ្ឋប្បវេណី/ជនរងគ្រោះ

បណ្តឹងរដ្ឋប្បវេណី អាចធ្វើឡើងក្នុងនាមជាជនរងគ្រោះបាន ដោយអ្នកតំណាងស្របច្បាប់របស់ខ្លួនកាលណាជនរងគ្រោះនេះជាអនីតិជន ឬជានីតិជនស្ថិតនៅក្រោមច្បាប់ការពារ។[56]

#### ២.១.២.១. ដីកាកោះហៅ

គេប្រើសម្រាប់កោះហៅជនរងគ្រោះអ្នកទទួលខុសត្រូវខាងរដ្ឋប្បវេណី ដើមបណ្តឹងរដ្ឋប្បវេណីអ្នកជំនាញអ្នកបកប្រែ និងសាក្សី ឱ្យចូលខ្លួនដោយស្ម័គ្រចិត្តចំពោះមុខតុលាការ។

ដីកាកោះទាំងនេះត្រូវមានចុះនិទ្ទេសដូចតទៅ៖

-អត្តសញ្ញាណនៃជនដែលពាក់ព័ន្ធ

-លំនៅឋាននៃជនដែលពាក់ព័ន្ធ

-ឈ្មោះជនជាប់ចោទ និងបទល្មើសដែលត្រូវចោទប្រកាន់

-តុលាការដែលត្រូវជំនុំជម្រះ

[56] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៨។

-ទីកន្លែង កាលបរិច្ឆេទ និងម៉ោងនៃសវនាការ

-កាលបរិច្ឆេទ និងហត្ថលេខារបស់ព្រះរាជអាជ្ញា

ដីកាកោះទាំងនេះត្រូវបញ្ជាក់ថា បុគ្គលដែលពាក់ព័ន្ធត្រូវបានកោះហៅក្នុងឋានៈជាជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវខាងរដ្ឋប្បវេណីអ្នកជំនាញ អ្នកបកប្រែ ឬសាក្សី។[57]

បុគ្គលគ្រប់រូបដែលត្រូវបានចៅក្រមស៊ើបសួរកោះហៅក្នុងឋានៈជាសាក្សីត្រូវតែមកបង្ហាញខ្លួន។ ក្នុងករណីរឹងទទឹង ចៅក្រមស៊ើបសួរអាចសុំឱ្យកងកម្លាំងសាធារណៈបង្ខំសាក្សីនេះឱ្យចូលមកបង្ហាញខ្លួនបាន។ ចៅក្រមស៊ើបសួរចេញបញ្ជាឱ្យចូលមកបង្ហាញខ្លួន។

បញ្ជានេះត្រូវមានអត្តសញ្ញាណរបស់សាក្សី ហើយត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។

**២.១.២.៣. ការទាមទារសំណង**

គ្រប់បទល្មើសព្រហ្មទណ្ឌទាំងអស់សុទ្ធសឹងតែបង្កឱ្យមានព្យសនកម្មដល់ជនរងគ្រោះទាំងអស់ ទោះបីជាព្យសនកម្មនោះតូច ឬធំក្តី ក៏ជនរងគ្រោះអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដើម្បីទាមទារសំណងជំងឺចិត្តពីជនល្មើសបានដែរ។ ព្យសនកម្មអាចត្រូវបានជួសជុល ដោយការបង់ជំងឺចិត្ត ដោយការសងទៅជនរងគ្រោះវិញនូវទ្រព្យសម្បត្តិដែលបានបាត់បង់ ឬដោយការធ្វើឱ្យដូចសភាពដើមវិញនូវទ្រព្យដែលគេបានបំផ្លិចបំផ្លាញ ឬធ្វើឱ្យចូចខាត។ សំណងជំងឺចិត្ត ត្រូវតែមានលក្ខណៈធួនល្មមជាមួយនឹងព្យសនកម្មដែលទទួលរង។[58]

**២.១.២.៤. ការដកពាក្យបណ្តឹង (បណ្តឹងអាជ្ញារលត់ករណីមួយចំនួន ករណីមួយចំនួនមិនរលត់)**

បណ្តឹងអាជ្ញាអនុវត្តទៅលើបុគ្គលគ្រប់រូប ទាំងរូបវន្តបុគ្គល ទាំងនីតិបុគ្គល ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ[59]។

មូលហេតុនៃការរលត់បណ្តឹងអាជ្ញាមានដូចតទៅគឺ :

១-មរណភាពនៃជនល្មើស ។

២-ការផុតអាជ្ញាយុកាល ។

៣-ការលើកលែងទោសជាទូទៅ ។

---

[57] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៤៧៥ ដល់មាត្រា ៤៨០។

[58] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៣, មាត្រា ១៤ និងមាត្រា ១៥។

[59] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៣។

៤-និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ ។

៥ -អាជ្ញាអស់ជំនុំ[60]។

កាលណាបណ្តឹងអាជ្ញាត្រូវផុតរលត់ហើយ ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌមិនអាចចាប់ផ្តើមបានទៀតទេ ឬត្រូវតែបញ្ឈប់។

មូលហេតុផ្សេងទៀតនៃការរលត់បណ្តឹងអាជ្ញា កាលណាច្បាប់ដោយឡែកបានចែងដោយជាក់លាក់ នោះបណ្តឹងអាជ្ញាក៏អាចផុតរលត់ បានដែរ :

១-ដោយការសម្របសម្រួលជាមួយរដ្ឋ ។

២-ដោយការដកពាក្យប្តឹង នៅក្នុងករណីដែលពាក្យប្តឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ ។

៣-ដោយការបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្របសម្រួល។[61]

**២.១.៣. ចំពោះសាក្សី**

សាក្សី ជាបុគ្គលដែលត្រូវតុលាការកោះហៅមកសាកសួរនូវហេតុការណ៍ ដែលមានប្រយោជន៍ដល់ការវិនិច្ឆ័យរឿងក្តី។

ក្នុងនីតិវិធីនៃការស៊ើបសួរ ចៅក្រមស៊ើបសួរអាចកោះហៅសាក្សី ដើម្បីស្តាប់ចម្លើយ ដោយដីកោះហៅ។ ក្នុងករណីដែលសាក្សីមិនចូលតាមដីកាកោះហៅ ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យនាំខ្លួន។

**២.១.៣.១. ដីកាកោះហៅ**

ចៅក្រមស៊ើបសួរនៃសាលាដំបូង អាចស្តាប់ចម្លើយបុគ្គលគ្រប់រូប ដែលចម្លើយនោះអាចមានប្រយោជន៍នៅ ក្នុងការសំដែងឱ្យឃើញការពិត។ ចៅក្រមស៊ើបសួរស្តាប់ចម្លើយសាក្សីដាច់ពីគ្នា ដោយគ្មានវត្តមានជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។ ចៅក្រមស៊ើបសួរក៏អាចសួរតទល់គ្នារវាងជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីផងបានដែរ។ បុគ្គលគ្រប់រូបដែលត្រូវបានចៅក្រមស៊ើបសួរកោះហៅក្នុងឋានៈជាសាក្សី ត្រូវតែមកបង្ហាញខ្លួន។[62]

មុននឹងឆ្លើយទៅនឹងសំណួរ សាក្សីម្នាក់ៗត្រូវស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថានិយាយតែការពិត។ ទម្រង់នៃសម្បថត្រូវធ្វើដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ចៅក្រមស៊ើបសួរអាចហៅរកអ្នកបកប្រែ ដើម្បីស្តាប់ចម្លើយសាក្សីដូចមានចែងនៅមាត្រា ១៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

[60] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៧។

[61] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៨។

[62] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៥៣ កថាខណ្ឌទី១, ២ និង ៣។

នៅក្នុងករណីខ្លះ សាក្សីមួយចំនួនក៏អាចត្រូវអនុញ្ញាតឱ្យរួចផុតពីសម្បថផងដែរ ដោយគ្រាន់តែស្តាប់ចម្លើយមិនចាំបាច់ធ្វើសម្បថ សាក្សីទាំងនោះមានដូចតទៅ ៖

-ឪពុក ម្តាយ និង បុព្វជនគ្រប់រូបរបស់ជនត្រូវចោទ។

-កូនប្រុស កូនស្រី និងបច្ឆាជនគ្រប់រូបផ្សេងទៀតរបស់ជនត្រូវចោទ។

-បង ប្អូនប្រុស ស្រីរបស់ជនត្រូវចោទ។

-បង ប្អូនថ្លៃប្រុស ស្រីរបស់ជនត្រូវចោទ។

-ប្តី ឬប្រពន្ធរបស់ជនត្រូវចោទ ទោះបីបានលែងលះគ្នាហើយក៏ដោយ។

-កុមារអាយុតិចជាង ១៤ ឆ្នាំ។[63]

**២.១.៣.២. ករណីសាក្សីមិនព្រមចូលខ្លួនតាមដីកាកោះ**

ក្នុងករណីរឹងទទឹង ចៅក្រមស៊ើបសួរនៃសាលាដំបូង អាចសុំឱ្យកងកម្លាំងសាធារណៈបង្ខំសាក្សីនេះ ឱ្យចូលមកបង្ហាញខ្លួនបាន។ ចៅក្រមស៊ើបសួរចេញបញ្ជាឱ្យចូលមកបង្ហាញខ្លួន។ បញ្ជានេះ ត្រូវមានអត្តសញ្ញាណរបស់សាក្សី ហើយត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។[64]

**២.១.៣.៤. ស៊ើបសួរលើសាក្សីដែលមានតម្រុយពិរុទ្ធភាព (ដីកាបង្គាប់ឱ្យនាំខ្លួន)**

ចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឱ្យនាំខ្លួន។ ដីកាបង្គាប់ឱ្យនាំខ្លួន គឺជាបញ្ជាដល់កងកម្លាំងសាធារណៈ ឱ្យចាប់ និងនាំឱ្យបុគ្គលណាម្នាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ។ បានន័យថាចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យនាំខ្លួនសាក្សីទាំងឡាយណាដែលចៅក្រមស៊ើបសួរយល់ឃើញថាមានតម្រុយពិរុទ្ធភាព ឱ្យមកបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរនៃសាលាដំបូង។[65]

## ២.២. កិច្ចរបស់ចៅក្រមស៊ើបសួរនៅដំណាក់កាលសាលាដំបូងរាជធានី/ខេត្ត

### ២.២.១. ការចុះទៅដល់ទីកន្លែង

ចៅក្រមស៊ើបសួរនៃសាលាដំបូង អាចចុះដល់ទីកន្លែងជាមួយក្រឡាបញ្ជីរបស់ខ្លួននៅលើវិសាលភាពនៃសមត្ថកិច្ចដែនដីរបស់ខ្លួន ដើម្បីបំពេញកិច្ចស៊ើបសួរ ដូចជាការពិនិត្យសម្ភារៈ ការឆែកឆេរ និងការចាប់យក

[63] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៥៤, មាត្រា១៥៥ និងមាត្រា ១៥៦។

[64] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៥៣ កថាខណ្ឌទី៤។

[65] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៨៩ និងមាត្រា ១៩០។

វត្ថុតាង។[66] ចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាអំពីការចុះទៅពិនិត្យនេះ។ ក្នុងករណីចុះក្រៅដែនដីសមត្ថកិច្ចរបស់ខ្លួន ចៅក្រមស៊ើបសួរត្រូវជូនដំណឹងជាមុនដល់ព្រះរាជអាជ្ញាខាងដែនដី។

**២.២.២. ដីកាស៊ើបសួរជំនួស**

ចៅក្រមស៊ើបសួរនៃសាលាដំបូង អាចសុំឱ្យចៅក្រមផ្សេង ឬមន្ត្រីនគរបាលយុត្តិធម៌ ឬអង្គភាពនគរបាលយុត្តិធម៌បំពេញកិច្ចខ្លះតាមដីកាចាត់ឱ្យស៊ើបសួរជំនួស ដែលមានចែងក្នុងមាត្រា ១៧៣ (ដីកាចាត់ឱ្យស៊ើបសួរជំនួស) ដល់មាត្រា ១៨៤ (កំណត់ហេតុកសាងដោយមន្ត្រីនគរបាលយុត្តិធម៌) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**២.២.៣. ការស្វែងរកភស្តុតាង**

ក្នុងប្រទេសកម្ពុជា គេមិនទាន់ឃើញមានវិធានស្តីអំពីការប្រើប្រាស់ភស្តុតាង និងការរកភស្តុតាងទេ។ ការរក និងការបង្ហាញភស្តុតាងអាចធ្វើបានតាមគ្រប់វិធី ប៉ុន្តែចៅក្រមត្រូវប្រើឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីសម្រេចក្នុងរឿងនេះ។

**២.២.៣.១. ភស្តុតាងដាក់បន្ទុក**

ភស្តុតាងដាក់បន្ទុក គឺជាភស្តុតាងដែលគាំទ្រចំណុចនៃបណ្តឹងហើយដែលធ្វើឱ្យ មានប្រយោជន៍ដល់បណ្តឹង ពោលគឺបានបង្ហាញជនត្រូវចោទពិតជាប្រព្រឹត្តបទល្មើសមែន។ ភស្តុតាងនេះអាចធ្វើឱ្យមានគុណប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី និងបណ្តឹងអាជ្ញា។

**២.២.៣.១. ភស្តុតាងដោះបន្ទុក**

ភស្តុតាងដោះបន្ទុក គឺជាភស្តុតាងខាងជនជាប់ចោទដែលបង្ហាញថាជនល្មើសមិនបានប្រព្រឹត្តបទល្មើស ឬពុំមានភស្តុតាងគ្រប់គ្រាន់ថាបានប្រព្រឹត្តបទល្មើសដើម្បីបានឈ្នះជាប្រយោជន៍ដល់ខ្លួន ភស្តុតាងដែលគាំទ្រការដោះសាពីការចោទប្រកាន់របស់គេ។

**២.២.៤. ការស្នើរសុំបំពេញកិច្ចស៊ើបសួរ**

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌថ្មី បានផ្តល់សិទ្ធិក្នុងការស្នើសុំបំពេញកិច្ចអាចធ្វើឡើងតាមរយៈ ការស្នើសុំបំពេញកិច្ចដោយព្រះរាជអាជ្ញា ដែលជាអ្នកតំណាងឱ្យសណ្តាប់ធ្នាប់សាធារណៈរបស់រដ្ឋ ផលប្រយោជន៍របស់អនីតិជន ការស្នើសុំបំពេញកិច្ចធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី និងការស្នើសុំបំពេញកិច្ច ដោយជនត្រូវចោទ។

**២.២.៤.១. ការបំពេញកិច្ចដោយព្រះរាជអាជ្ញា**

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ព្រះរាជអាជ្ញាអាចសុំឱ្យចៅក្រមស៊ើបសួរនៃសាលាដំបូង ធ្វើកិច្ចស៊ើបសួរណាមួយ ដែលខ្លួនយល់ឃើញថាមានប្រយោជន៍បាន។ ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមសេចក្តី

[66] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៥៩។

សន្និដ្ឋានរបស់ ព្រះរាជអាជ្ញាទេ នោះចៅក្រមរូបនេះត្រូវចេញដីកាបដិសេធនៅក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ។ ដីកានេះត្រូវមានសំអាងហេតុ ហើយត្រូវតែជូនដំណឹងដល់ព្រះរាជអាជ្ញាក្នុងចិរវេលាយ៉ាងឆាប់បំផុត។ ហើយប្រសិនបើចៅក្រមស៊ើបសួរ មិនបានធ្វើការសម្រេចក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃនេះទេ ព្រះរាជអាជ្ញាអាចប្តឹងដោយផ្ទាល់តាមរយៈ ពាក្យសុំទៅសភាព្រហ្មទណ្ឌស៊ើបសួរដែលសម្រេចជំនួសឱ្យចៅក្រមស៊ើបសួរ។[67]

**២.២.៤.២. ការបំពេញកិច្ចដោយដើមបណ្តឹងរដ្ឋប្បវេណី**

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ដើមបណ្តឹងរដ្ឋប្បវេណីអាចសុំដល់ចៅក្រមស៊ើបសួរនៃសាលាដំបូងឱ្យស្តាប់ចម្លើយខ្លួន ស្តាប់ចម្លើយសាក្សី សួរចម្លើយជនត្រូវចោទ សួរតទល់ ឬចុះទៅដល់ទីកន្លែងកើតហេតុបាន។ ពាក្យសុំនេះត្រូវធ្វើ ជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។ ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំនេះទេ ចៅក្រមរូបនេះត្រូវចេញដីកាបដិសេធក្នុងចិរវេលា១(មួយ)ខែ ក្រោយពេលទទួលបានពាក្យបណ្តឹងសុំនេះ។ ចំពោះដីកាបដិសេធនេះត្រូវមានបញ្ជាក់នូវសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងដល់ដើមបណ្តឹងរដ្ឋប្បវេណី។ ប្រសិនបើចៅក្រមស៊ើបសួរ មិនបានសម្រេចក្នុងចិរវេលា១(មួយ)ខែទេ ដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើការដាក់ពាក្យបណ្តឹងដោយផ្ទាល់តាមរយៈពាក្យសុំដល់សភាស៊ើបសួរដែលសម្រេចជំនួសឱ្យចៅក្រមស៊ើបសួរ។[68]

**២.២.៤.៣. ការបំពេញកិច្ចដោយជនត្រូវចោទ**

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ជនត្រូវចោទអាចសុំឱ្យចៅក្រមស៊ើបសួរនៃសាលាដំបូងធ្វើការសួរចម្លើយខ្លួន ស្តាប់ ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សី សួរតទល់គ្នា ឬចុះទៅដល់ទីកន្លែងកើតហេតុ។ ពាក្យសុំ ត្រូវធ្វើជា លាយលក្ខណ៍អក្សរ និងត្រូវមានសំអាងហេតុ។ ប្រសិនបើចៅក្រមស៊ើបសួរ មិនព្រមធ្វើតាមពាក្យសុំទេ ចៅក្រម រូបនេះត្រូវចេញដីកាបដិសេធនៅក្នុងចិរវេលា១(មួយ)ខែ បន្ទាប់ពីពេលទទួលពាក្យសុំ។ ដីកានេះត្រូវតែមាន សំអាងហេតុ និងត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ។ ប្រសិនបើចៅក្រមស៊ើបសួរ មិនបានសម្រេចក្នុងចិរវេលា១ (មួយ) ខែទេ ជនត្រូវចោទអាចប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំដល់សភាស៊ើបសួរដែលជាអ្នកសម្រេចជំនួសឱ្យចៅក្រមស៊ើបសួរ។[69]

[67] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៣២។

[68] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៣២។

[69] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១៣៣។

# ជំពូកទី៣

# ចំណាត់ការរបស់ចៅក្រមស៊ើបសួរក្នុងការបិទការស៊ើបសួរ

# ជំពូកទី៣
# ចំណាត់ការរបស់ចៅក្រមស៊ើបសួរក្នុងការបិទការស៊ើបសួរ

## ១. មូលហេតុដែលនាំឱ្យបិទការស៊ើបសួរ

ការស៊ើបសួរនៅសាលាដំបូងត្រូវបិទបញ្ចប់បន្ទាប់ពីមានមូលហេតុនៃការបិទការស៊ើបសួរ ដោយត្រូវអនុវត្តតាមនីតិវិធីនៃការបិទការស៊ើបសួរ ហើយបន្ទាប់ពីការស៊ើបសួរត្រូវបានបិទហើយនោះ វានឹងបង្កើតឱ្យមាន នូវអានុភាពមួយចំនួនផងដែរ។ មុននឹងធ្វើការសិក្សាឱ្យបានលម្អិតពាក់ព័ន្ធនឹងនីតិវិធីនៃការបិទកិច្ចស៊ើបសួរនៅសាលាដំបូង គប្បីធ្វើការឈ្វេង យល់អំពីមូលហេតុនៃការបិទការស៊ើបសួរជាមុនសិន ដោយផ្តើមចេញពីស្ថាប័នដែលមានសមត្ថកិច្ចក្នុងការសម្រេចបិទការស៊ើបសួរ ដែលជាគោលការណ៍សមត្ថកិច្ចនេះ គឺជារបស់ចៅក្រមស៊ើបសួរ ប៉ុន្តែការបិទកិច្ចស៊ើបសួរនៅសាលាដំបូងក៏អាចធ្វើបានតាមរយៈការប្តឹងសុំរបស់ភាគី ដែលក្នុងនោះរួមមាន ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី។ ដោយឡែក ចំពោះថិរវេលានៃការបិទការស៊ើបសួរ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌពុំមានចែងអំពីការកំណត់ពេលណាមួយឱ្យច្បាស់លាស់នោះទេ ហើយកាលបើរឿងក្តីមួយត្រូវបានអូសបន្លាយក្នុងរយៈពេលវែងហួសហេតុពេក ជាហេតុនាំឱ្យមានការប៉ះពាល់សិទ្ធិរបស់ភាគី នៅក្នុងរឿងក្តីបានផងដែរ។ ហេតុនេះហើយ ទើបក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិនូវមាត្រាមួយចំនួន ដែលអនុញ្ញាតឱ្យភាគីបានចូលរួមធ្វើសកម្មភាពក្នុងដំណើរការកិច្ចនីតិវិធីព្រហ្មទណ្ឌ ដើម្បីបញ្ជៀសភាព អសកម្មនៃកិច្ចនីតិវិធីស៊ើបសួរ ដែលនោះគឺសិទ្ធិក្នុងការប្តឹងសុំឱ្យបិទការស៊ើបសួរ។

### ១.១. ការបិទការស៊ើបសួរដោយចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរនៃសាលាដំបូង ជាអ្នកពិនិត្យ និងវាយតម្លៃដោយឥស្សរចិត្តនៅខណៈពេលដែលត្រូវបញ្ចប់ការស៊ើបសួររបស់ខ្លួន ហើយនៅពេលដែលចៅក្រមស៊ើបសួរ យល់ឃើញថាការស្វែងរកភស្តុតាងមិនតម្រូវឱ្យមាននូវការបំពេញកិច្ចស្រាវជ្រាវអ្វីបន្ថែមទៀតទេ នោះចៅក្រមស៊ើបសួរនឹងសម្រេចបិទការស៊ើបសួរដោយឆន្ទានុសិទ្ធិ។ ផ្អែកតាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌ ពុំមានចែងអំពីថិរវេលានៃការស៊ើបសួរទេ ប៉ុន្តែអាចពិចារណាបានថាចំពោះការស៊ើបសួរនេះផងដែរ គឺជាសមត្ថកិច្ចរបស់សភាស៊ើបសួរក្នុងការ ធានារ៉ាប់រងឱ្យការស៊ើបសួរនេះ ធ្វើឡើងក្នុងថិរវេលាសមរម្យមួយដោយពុំមែនជាការទុកចោល ឬបង្អកឱ្យសំណុំរឿងមានភាពអសកម្មយូរពេកនោះឡើយ។

ចំពោះការបិទការស៊ើបសួរនេះផងដែរ គឺស្តែងឡើងតាមរយៈការចេញនូវដីកាដំណោះស្រាយ ដោយដីកានេះត្រូវធ្វើឡើងក្នុង ០២ (ពីរ) ដំណាក់កាល ដោយក្នុងនោះចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅ ព្រះរាជអាជ្ញា និងភាគី (ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី ឬ មេធាវី) ពីឆន្ទៈរបស់ខ្លួនក្នុងការបិទសំណុំរឿង។ បន្ទាប់មក

ទៀតនោះ គឺចៅក្រមស៊ើបសួរនឹងធ្វើការបិទការស៊ើបសួរតាមរយៈការចេញនូវដីកាដំណោះស្រាយ។ ដរាបណាចៅក្រមស៊ើបសួរ ពុំទាន់ចេញដីកាដំណោះស្រាយដើម្បីបិទការស៊ើបសួរនោះទេ គឺមានន័យថា ទោះបីជាបន្ទាប់ពីបានជូនដំណឹងដល់ភាគីពីឆន្ទៈក្នុងការបិទសំណុំរឿងរួចហើយក៏ដោយ ក៏ចៅក្រមស៊ើបសួរនៅតែអាចទទួលបណ្តឹង និងអាចបន្តការស្រាវជ្រាវរបស់ខ្លួនបានដដែល។ ដូច្នេះ ចំពោះការជូនដំណឹងអំពីការបិទកិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរនៃសាលាដំបូង ដែលបានធ្វើការជូនដំណឹងទៅភាគីនោះនឹងក្លាយទៅជាមោឃៈ។

### ១.២. ការបិទការស៊ើបសួរតាមរយៈការប្តឹងសុំរបស់ភាគី

នេះបើយោងតាមមាត្រា ៨ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស បានកំណត់ថា "មនុស្សគ្រប់រូបមានសិទ្ធិរកដំណោះស្រាយស័ក្តិសិទ្ធិមួយ នៅចំពោះមុខសាលាជំរះក្តីជាតិដែលមានសមត្ថកិច្ច ចំពោះអំពើទាំងឡាយណាដែលរំលោភសិទ្ធិមូលដ្ឋានរបស់ខ្លួន ដែលត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ ឬដោយច្បាប់"។ បន្ថែមពីនេះផងដែរ ផ្អែកតាមស្មារតីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក៏បានកំណត់អំពីសិទ្ធិក្នុងការប្តឹងទាមទារយុត្តិធម៌ ដោយក្នុងនោះបានចែងថា "ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ"។[70] ផ្អែកតាមស្មារតីនៃលិខិតបទដ្ឋានគតិយុត្តអន្តរជាតិ ក៏ដូចជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា គឺសរបញ្ជាក់ឱ្យឃើញថា ក្នុងនាមជាមនុស្សជាតិ ឬ ប្រជាពលរដ្ឋខ្មែរ មានសិទ្ធិពេញលេញក្នុងការស្វែងរកជំនួយយុត្តិធម៌តាមអំណាចដែលច្បាប់បានផ្តល់ឱ្យ។

បើក្រឡេកមកមើល ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ក៏បានផ្តល់សិទ្ធិពេញលេញទៅឱ្យភាគី មិនថាតែក្នុងឋានៈជាជនត្រូវចោទ ឬ ជនរងគ្រោះ ឬ ដើមបណ្តឹងរដ្ឋប្បវេណី នោះទេ សុទ្ធសឹងតែមានសិទ្ធិក្នុងការប្តឹងសុំទៅតុលាការ។ ជាក់ស្តែង ដូចករណីនៃការប្តឹងសុំបិទបញ្ចប់ការស៊ើបសួរនៅសាលាដំបូងច្បាប់ក៏បានបើកសិទ្ធិទូលាយដល់ភាគីក្នុងការប្តឹងសុំទៅចៅក្រមស៊ើបសួរ ដើម្បីបញ្ចប់ការស៊ើបសួរបានដែរ។ ដោយក្នុងនោះ ជនត្រូវចោទ និងជនរងគ្រោះ អាចសុំឱ្យចៅក្រមស៊ើបសួរបិទការស៊ើបសួរ នៅពេលផុតរយៈពេល ០១ (មួយ) ឆ្នាំ បន្ទាប់ពីការចោទប្រកាន់ ចំពោះជនត្រូវចោទ ឬ បន្ទាប់ពីមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចំពោះជនរងគ្រោះ។ ក្នុងករណីនេះ គឺចៅក្រមស៊ើបសួរ មានថិរវេលា ០១ (មួយ) ខែ ដើម្បីធ្វើការសម្រេច។ បើពុំនោះទេ អ្នកដែលសុំឱ្យបិទការស៊ើបសួរអាចប្តឹងទៅប្រធានសភាស៊ើបសួរ ដែលបង្គាប់ឱ្យចៅក្រមស៊ើបសួរធ្វើការសម្រេចសេចក្តី នេះបើយោងតាមស្មារតីនៃមាត្រា ២៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ចំពោះ

[70] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣, មាត្រា ៣៩។

ការប្រើប្រាស់សិទ្ធិក្នុងការសុំឱ្យបិទកិច្ចស៊ើបសួរនៅសាលាដំបូង គឺជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណីក៏អាចធ្វើការពឹងពាក់មេធាវីជាជំនួយបានផងដែរ។

## ២. នីតិវិធីនៃការបិទកិច្ចស៊ើបសួរនៅដំណាក់កាលសាលាដំបូងរាជធានី/ខេត្ត

### ២.១. ការត្រៀមរៀបចំនីតិវិធីនៃការបិទការស៊ើបសួរ

មុនចេញដីកាដំណោះស្រាយដើម្បីបិទបញ្ចប់កិច្ចស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវអនុវត្តកិច្ចមួយចំនួនសិន ដែលក្នុងនោះរួមមាន ការជូនព័ត៌មានអំពីការបិទកិច្ចស៊ើបសួរ(២.១.១) ការបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ(២.១.២) និងត្រូវទទួលដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា(២.១.៣)។

#### ២.១.១. ការជូនព័ត៌មានអំពីការបិទកិច្ចស៊ើបសួរ

កាលណាចៅក្រមស៊ើបសួរនៅសាលាដំបូងយល់ឃើញថា ការស៊ើបសួរបញ្ចប់ ចៅក្រមស៊ើបសួរជូនព័ត៌មាននេះ ដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី។[71] ដោយនៅក្នុងអត្ថបទច្បាប់ពុំបាន បញ្ជាក់អំពីបែបបទនៃការផ្តល់ព័ត៌មានទាំងនេះទេ ថាតើជាការផ្តល់ព័ត៌មានក្រោមទម្រង់ផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរនោះឡើយ ដូច្នេះដើម្បីជាការបង្ការគប្បីត្រូវមាននូវលិខិតជូនដំណឹង ឬ ការប្រកាសដោយមានការចុះវិមទំព័រក្នុងសំណុំរឿង និងធ្វើជាលាយលក្ខណ៍អក្សរឱ្យបានត្រឹមត្រូវ ប៉ុន្តែការកំណត់ទាំងនេះពុំបានចែងក្នុងក្រម ហើយការមិនធ្វើបែបនេះក៏មិនអាចចាត់ទុកជាមូលហេតុនៃការប្តឹងសុំមោឃភាពបានទេ។

##### ២.១.១.១. ការជូនព័ត៌មានទៅព្រះរាជអាជ្ញា

ដើម្បីអាចបិទកិច្ចស៊ើបសួរបាន ចៅក្រមស៊ើបសួរត្រូវធ្វើការបញ្ជូនព័ត៌មានអំពីការបិទកិច្ចស៊ើបសួរនោះទៅឱ្យព្រះរាជអាជ្ញា តាមរយៈដីកាបញ្ជូនព័ត៌មាន ឬ លិខិតជូនព័ត៌មាន ឬ លិខិតជូនដំណឹងអំពី ការបិទការស៊ើបសួរ។ ចំពោះការកំណត់ឈ្មោះនេះផងដែរ គឺទៅតាមទម្រង់របស់ចៅក្រមស៊ើបសួរ នីមួយៗនៅសាលាដំបូង ហើយដីកា ឬ លិខិតនេះទៀតសោត ត្រូវមានការចុះហត្ថលេខា ឯកភាព ឬ ផ្តល់យោបល់ពីតំណាងអយ្យការ ទើបចៅក្រមស៊ើបសួរអាចបន្តចំណាត់ការរបស់ខ្លួនបាន។ ប៉ុន្តែក្នុងករណីនេះមិនមែនមានន័យថា នៅពេលតំណាងអយ្យការទទួលបានដីកា ឬ លិខិតបញ្ជូនព័ត៌មាន ពីចៅក្រមស៊ើបសួរ គឺត្រូវតែឯកភាពគ្រប់ពេលនោះទេ ពីព្រោះថានៅមណ្ឌលកម្មសិក្សានៃសាលាដំបូង និងអយ្យការអមសាលាដំបូង សង្កេតឃើញថា តំណាងអយ្យការធ្វើការឯកភាព លុះត្រាតែ សំណុំរឿងដែលចៅក្រមស៊ើបសួរបញ្ជូនមកនោះមួលសព្វគ្រប់នឹងអាចបិទការស៊ើបសួរបាន។ ក្នុងករណី ដែលចៅក្រមស៊ើបសួរធ្វើការបញ្ជូនព័ត៌មាន ហើយតំណាងអយ្យការធ្វើការពិនិត្យត្រួសៗនៅលើបញ្ជី រាយលិខិតលើក្របសំណុំរឿងព្រហ្មទណ្ឌនោះ ឃើញថាកិច្ចស៊ើបសួរនោះមិនទាន់មូលសព្វ

---

[71] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា២៤៦, កថាខណ្ឌទី១។

គ្រប់ទេនោះ តំណាងអយ្យការនឹងបង្គាប់ឱ្យធ្វើការបំពេញកិច្ច តាមនីតិវិធីច្បាប់ឱ្យគ្រប់ជ្រុងជ្រោយសិន ទើបធ្វើការបញ្ជូនសំណុំរឿងមកបិទការស៊ើបសួរជាថ្មីម្តងទៀត។

**២.១.១.២. ការជូនព័ត៌មានទៅភាគី**

បន្ទាប់ពីមានការឯកភាពលើដីកា ឬ លិខិតបញ្ជូនព័ត៌មានហើយនោះ ចៅក្រមស៊ើបសួរត្រូវធ្វើការជូនព័ត៌មានដែលទាក់ទងនឹងការបិទកិច្ចស៊ើបសួរទៅឱ្យភាគីដែលពាក់ព័ន្ធ ដោយក្នុងនោះរួមមាន ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ ឬ មេធាវី ជាអាទិ៍។ ការជូនព័ត៌មាននេះទៀតសោត នៅមណ្ឌលកម្មសិក្សានៃសាលាដំបូង គឺចៅក្រមស៊ើបសួរធ្វើការជូនព័ត៌មានអំពីការបិទកិច្ច ស៊ើបសួរ ក្រោមទម្រង់ជាលិខិតជូនដំណឹងអំពីការបិទការស៊ើបសួរទៅកាន់ភាគីដែលពាក់ព័ន្ធនៅក្នុងសំណុំរឿង ហើយបន្ទាប់មកទៀត ចៅក្រមស៊ើបសួរត្រូវធ្វើការបញ្ជូនលិខិតនោះទៅឱ្យភាគី ដើម្បីឱ្យ បានជ្រាបជាព័ត៌មាន ក៏ដូចជា ជាសញ្ញាមួយក្នុងការប្រាប់ទៅភាគីថា នៅរយៈពេល ០២ (ពីរ) ថ្ងៃទៀត ចៅក្រមស៊ើបសួរនឹងធ្វើការបញ្ជូនសំណុំរឿងទៅឱ្យតំណាងអយ្យការធ្វើការពិនិត្យ។

**២.១.១.៣. ការបញ្ជូនលិខិតជូនដំណឹងអំពីការបិទការស៊ើបសួរ**

លិខិតជូនដំណឹងអំពីការបិទការស៊ើបសួរនេះផងដែរ គឺចៅក្រមស៊ើបសួរត្រូវធ្វើការបញ្ជូនទៅឱ្យ ភាគីដែលពាក់ព័ន្ធនឹងសំណុំរឿងព្រហ្មទណ្ឌ តាមរយៈដីកាបញ្ជូន ឬ របាយការណ៍បញ្ជូន។ ការបញ្ជូន តាមរយៈដីកាបញ្ជូន ឬ របាយការណ៍បញ្ជូននេះ គឺមានលក្ខណៈខុសគ្នាត្រង់ថា ចៅក្រមស៊ើបសួរធ្វើ ការបញ្ជូនតាមរយៈដីកាបញ្ជូនក្នុងករណីដែលភាគីពាក់ព័ន្ធដែលត្រូវធ្វើការជូនដំណឹងនោះ ស្ថិតក្នុងដែន សមត្ថកិច្ចនៃសាលាដំបូងប៉ុណ្ណោះ។ ដោយឡែកចំពោះភាគីដែលស្ថិតនៅក្រៅសមត្ថកិច្ចវិញ ចៅក្រមស៊ើបសួរក៏ធ្វើការបញ្ជូនតាមរយៈដីកាបញ្ជូនផងដែរ ប៉ុន្តែត្រូវមានភ្ជាប់ជាមួយនឹងរបាយការណ៍បញ្ជូនអមជាមួយ។ ចំពោះការបញ្ជូននេះផងដែរ នៅក្នុងមណ្ឌលកម្មសិក្សាខេត្តកណ្តាល គឺឃើញថា នៅ ពេលដែលធ្វើការបញ្ជូនទៅភាគីដែលមានទីលំនៅស្ថិតក្នុងដែនដីនៃខេត្តកណ្តាល ត្រូវធ្វើការបញ្ជូនតាម រយៈស្នងការនគរបាលទទួលបន្ទុកផ្នែកកិច្ចការរដ្ឋបាលដែលជាមន្ត្រីទទួលបន្ទុកក្នុងការបញ្ជូនដីកាផ្សេងៗ របស់តុលាការ ដោយធ្វើការបញ្ជូនដីកាទាំងនេះទៅឱ្យអធិការដ្ឋាននគរបាលស្រុក ឬ ក្រុងនីមួយៗចាត់ការ តាមនីតិវិធីច្បាប់ក្នុងការប្រគល់នូវដីកាទៅឱ្យសាមីខ្លួនផ្ទាល់។ ចំណែកឯ ភាគីដែលមានទីលំនៅក្រៅដែន ដីនៃសាលាដំបូងវិញ គឺចៅក្រមស៊ើបសួរត្រូវធ្វើរបាយការណ៍បញ្ជូនទៅកាន់ប្រធានសាលា ដំបូងនៃលំនៅដ្ឋានរបស់ជននោះ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ក្នុងការប្រគល់ដីកាទៅឱ្យសាមីខ្លួនផ្ទាល់ ហើយចំពោះរបាយការណ៍បញ្ជូននេះផងដែរ ត្រូវធ្វើការបញ្ជូនតាមរយៈបុគ្គលិកប្រៃសនីយ៍ មិនមែនតាម រយៈស្នងការនគរបាលទទួលបន្ទុកផ្នែកកិច្ចការរដ្ឋបាលឡើយ។ ជាមួយគ្នានេះដែរ ក្នុងករណីដែលត្រូវបញ្ជូនលិខិតជូនដំណឹងអំពីការបិទការស៊ើបសួរ ឬ បញ្ជូនព័ត៌មាននេះទៅឱ្យជនត្រូវចោទ ដែលជាប់ឃុំ

ជាបណ្ដោះអាសន្ននៅក្នុងពន្ធនាគារ គឺត្រូវធ្វើការបញ្ជូនលិខិតទៅពន្ធនាគារនៃសាលាដំបូងដែលជនត្រូវចោទនោះស្ថិតនៅ ដើម្បីជ្រាបជាព័ត៌មានថាចៅក្រមស៊ើបសួរ បានធ្វើការបិទបញ្ចប់កិច្ចស៊ើបសួរ។

**២.១.២. ការបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ**

កាលណាចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួរបានបញ្ចប់ ចៅក្រមស៊ើបសួរជូនព័ត៌មាននេះដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវី។ ០២ (ពីរ) ថ្ងៃ ក្រោយមក ចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ។[72] ជាមួយគ្នានេះដែរ ព្រះរាជអាជ្ញាអាចធ្វើការពិនិត្យ លើសំណុំរឿងស៊ើបសួរ ឬស្នើសុំឱ្យបញ្ជូនរឿងមកពិនិត្យបានគ្រប់ពេលវេលា ដោយមិនចាំបាច់ទាល់ត ចៅក្រមស៊ើបសួរយល់ឃើញថាការស៊ើបសួរបានបញ្ចប់ឡើយ ប៉ុន្តែព្រះរាជអាជ្ញាត្រូវមានភារកិច្ចក្នុង ការបង្វិលសំណុំរឿងនោះទៅវិញ ក្នុងចិរវេលា ២៤ (ម្ភៃបួន) ម៉ោង យោងតាមខ្លឹមសារនៃមាត្រា ១៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

យោងតាមស្មារតីមាត្រា ១៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សង្កេតឃើញថា ក្រោយពីបានពិនិត្យ លើសំណុំរឿងរួចហើយ ប្រសិនបើព្រះរាជាអាជ្ញាយល់ឃើញថា នៅក្នុងនីតិវិធីស៊ើបសួរនោះនៅមាន កិច្ចមួយចំនួនដែលមិនទាន់ចប់សព្វគ្រប់ ឬ នៅមានកិច្ចណាមួយមិនទាន់បានធ្វើការស៊ើបសួរ ហើយព្រះរាជអាជ្ញាយល់ឃើញថាមានប្រយោជន៍ដល់នីតិវិធីនៃការស៊ើបសួរដែរ នោះព្រះរាជអាជ្ញាក៏អាចធ្វើ ការស្នើសុំឱ្យចៅក្រមស៊ើបសួរធ្វើកិច្ចស៊ើបសួរលើកិច្ចដែលខ្លួនយល់ឃើញថាមានប្រយោជន៍បានដែរ។ ប្រសិនបើ ចៅក្រមស៊ើបសួរមិនព្រមធ្វើតាមការស្នើសុំឱ្យបំពេញកិច្ចនោះទេ ចៅក្រមស៊ើបសួរត្រូវចេញ ដីកាបដិសេធក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ។ ចំពោះដីកានេះផងដែរ ចៅក្រមស៊ើបសួរត្រូវមាន សំអាងហេតុ ហើយត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាក្នុងចិរវេលាយ៉ាងឆាប់បំផុត។ ក្នុងករណីដែល ចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្ដឹងដោយផ្ទាល់ តាមរយៈពាក្យសុំទៅសភាស៊ើបសួរដែលធ្វើការសម្រេចជំនួសចៅក្រមស៊ើបសួរបាន។

លើសពីនេះទៅទៀត ចំពោះការស្នើសុំឱ្យចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរ គឺមិនមែនត ព្រះរាជអាជ្ញាទេដែលអាចធ្វើបាន ក្នុងនោះចំពោះជនត្រូវចោទ និងដើមបណ្ដឹងរដ្ឋប្បវេណីក៏អាចធ្វើបានដែរ។ យោងទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌ ដែលបញ្ញត្តិនៅត្រង់មាត្រា ១៣៣ និងមាត្រា ១៣៤ ក៏បានចែងយ៉ាងច្បាស់អំពីសិទ្ធិក្នុងការស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរទៅចៅក្រមស៊ើបសួរ ដោយជនត្រូវចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី។ បន្ទាប់ពីបំពេញកិច្ចស៊ើបសួរដែលបានសុំដោយគូភាគី ចៅក្រមស៊ើបសួរ ត្រូវជូនដំណឹងសាជាថ្មីដល់ភាគី នៅពេលដែលខ្លួនយល់ឃើញថាការស៊ើបសួរត្រូវបញ្ចប់។ ការជូនដំណឹង នេះ ត្រូវធ្វើឡើងក្នុងចិរវេលា ០២ (ពីរ) ថ្ងៃ មុនការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាចាប់ផ្ដើមពិនិត្យសាជាថ្មី។ ដូចគ្នាផងដែរ បន្ទាប់ពីព្រះរាជអាជ្ញា ទទួល

[72] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា២៤៦។

សំណុំរឿងដែលចៅក្រមស៊ើបសួរបានបំពេញកិច្ច តាមការសុំដោយភាគីរួចរាល់ហើយ ប្រសិនបើព្រះរាជអាជ្ញាសុំឱ្យមានកិច្ចស៊ើបសួរបន្ថែម ហើយមាន ការយល់ព្រមដោយចៅក្រមស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងពីការបញ្ចប់ការស៊ើបសួរជាថ្មី ម្តងទៀត។ គួរគួសបញ្ជាក់ថា ការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាមិនអាចដកសមត្ថកិច្ចពីចៅក្រម ស៊ើបសួរទេ ព្រោះចៅក្រមស៊ើបសួរអាចបន្តស៊ើបសួររហូតដល់ថ្ងៃចេញដីកាដំណោះស្រាយលើពាក្យ សុំឱ្យដោះលែងជនត្រូវចោទដែលជាប់ឃុំ ជាដើម។

រយៈពេល ០២ (ពីរ) ថ្ងៃ បន្ទាប់ពីចៅក្រមស៊ើបសួរ ធ្វើការជូនព័ត៌មានទៅឱ្យតំណាងអយ្យការ ក៏ដូចជាជូនដំណឹងអំពីការបិទការស៊ើបសួរទៅភាគីពាក់ព័ន្ធរួចរាល់ហើយ គឺចៅក្រមស៊ើបសួរត្រូវបន្តចំណាត់ការរបស់ខ្លួនក្នុងការបិទកិច្ចស៊ើបសួរ ដោយធ្វើការបញ្ជូនសំណុំរឿងឱ្យតំណាងអយ្យការធ្វើការពិនិត្យ ហើយការបញ្ជូនសំណុំរឿងឱ្យពិនិត្យនេះផងដែរ ចៅក្រមស៊ើបសួរចេញក្រោមទម្រង់ជាដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យ ឬដីកាបញ្ជូនសំណុំរឿង។

នៅពេលដែលតំណាងអយ្យការពិនិត្យទៅលើកិច្ចស៊ើបសួរដែលបញ្ជូនមកនោះ នៅមិនទាន់មូលសព្វគ្រប់នៅឡើយទេ តំណាងអយ្យការនឹងចេញដីកាស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម ដើម្បីឱ្យចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួររបស់ខ្លួនឱ្យបានពេញលេញ សឹមបញ្ជូនមកឱ្យតំណាងអយ្យការធ្វើការបិទការស៊ើបសួរជាថ្មីម្តងទៀត។ ប៉ុន្តែ ចំពោះការស្នើសុំរបស់តំណាងអយ្យការឱ្យចៅក្រមស៊ើបសួរបំពេញកិច្ចបន្ថែម គឺឃើញថាមានការអូសបន្លាយ និងយឺតយ៉ាវចំពោះការដំណើរ ការកិច្ចនីតិវិធីក្នុងការបិទការស៊ើបសួរ។ ហេតុដូច្នេះហើយ ទើបឃើញមានតំណាងអយ្យការមួយចំនួន មិនចេញដីកាស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែមទេ ដោយគ្រាន់តែប្រាប់ទៅចៅក្រមស៊ើបសួរឱ្យបំពេញកិច្ចដែលខ្វះខាតនោះបន្ថែមសិន សឹមធ្វើការបញ្ជូនព័ត៌មានជាថ្មីមកតំណាងអយ្យការម្តងទៀត។ បន្ទាប់មកទៀត តំណាងអយ្យការនឹងធ្វើការពិនិត្យមើលសំណុំរឿងដែលចៅក្រមស៊ើបសួរនឹងធ្វើការបញ្ជូនមកនៅរយៈពេល ០២ (ពីរ) ថ្ងៃទៀត បន្ទាប់ពីបញ្ជូនព័ត៌មាន។ ចំពោះការណ៍ដែលតំណាងអយ្យការអាចដឹងថាកិច្ចស៊ើបសួរដែលចៅក្រមស៊ើបសួរធ្វើការបញ្ជូនមក ដើម្បីបិទការស៊ើបសួរនោះមិនទាន់មូលសព្វគ្រប់នៅឡើយទេ គឺតាមរយៈការពិនិត្យមើលការរាយលិខិតរបស់ក្រឡាបញ្ជីតុលាការ (ចៅក្រមស៊ើបសួរ) នៅលើក្របសំណុំរឿងព្រហ្មទណ្ឌដែលបញ្ជូនមកតំណាងអយ្យការដើម្បីបិទការស៊ើបសួរ នៅពេលចៅក្រមស៊ើបសួរធ្វើការបញ្ជូនព័ត៌មាន។

**២.១.៣. សេចក្តីសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា**

ព្រះរាជអាជ្ញាត្រូវចេញដីកាសន្និដ្ឋានស្ថាពរ ក្រោយពីបានទទួលការជូនដំណឹងរបស់ចៅក្រមស៊ើបសួរស្តីពីការបិទបញ្ចប់កិច្ចស៊ើបសួរ។ ប៉ុន្តែ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាចាំបាច់ត្រូវធ្វើកិច្ច ស៊ើបសួរថ្មីទៀតនោះ ព្រះរាជអាជ្ញាត្រូវស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរ ហើយក្រោយពីបានស៊ើបសួរបន្ថែមចប់សព្វគ្រប់ហើយ

ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានពីការបិទការស៊ើបសួរម្តងទៀត។ កាលបើ ព្រះរាជអាជ្ញាយល់ឃើញដូចចៅក្រមស៊ើបសួរដែរថាការស៊ើបសួរត្រូវបានបញ្ចប់ នោះព្រះរាជអាជ្ញាត្រូវ បង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ ដោយមានដីកាសន្និដ្ឋានស្ថាពរភ្ជាប់មកជាមួយផងក្នុងរយៈ ពេល ១៥ (ដប់ប្រាំ) ថ្ងៃ បើជនត្រូវចោទត្រូវឃុំខ្លួន និងរយៈពេល ០១ (មួយ) ខែ បើជនត្រូវចោទនៅក ឃុំ គិតចាប់ពីថ្ងៃដែលព្រះរាជអាជ្ញាបានទទួលសំណុំរឿងពីចៅក្រមស៊ើបសួរ។ ដីកាសន្និដ្ឋានស្ថាពរតូវ ធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ ហើយនៅក្នុងដីកាសន្និដ្ឋានស្ថាពរនេះផងដែរ គឺព្រះរាជអាជ្ញាអាចប្តឹងសុំឱ្យចៅក្រមស៊ើបសួរសម្រេចបញ្ជូនខ្លួនជនត្រូវចោទទៅកាន់តុលាការជំនុំជម្រះ ឬធ្វើការលើកលែងចោទប្រកាន់ យោងតាមអត្ថន័យមាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

នៅមណ្ឌលកម្មសិក្សានៃសាលាដំបូង និងអយ្យការអមសាលាដំបូង សង្កេតឃើញថា ព្រះរាជអាជ្ញាត្រូវចេញដីកាសន្និដ្ឋានស្ថាពរ ក្រោយពីទទួលបានដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យពីសំណាក់ចៅក្រមស៊ើបសួរ។ បន្ទាប់ពីព្រះរាជអាជ្ញាធ្វើការពិនិត្យសំណុំរឿងដែលចៅក្រមស៊ើបសួរធ្វើការបញ្ជូន មកឱ្យពិនិត្យរួចរាល់ហើយនោះ ព្រះរាជអាជ្ញានឹងធ្វើការបង្វិលសំណុំរឿងទៅឱ្យចៅក្រមស៊ើបសួរវិញ ដោយក្នុងនោះមានភ្ជាប់ជាមួយនឹងដីកាសន្និដ្ឋានស្ថាពរផង។ ចំពោះចិរវេលានៃការបង្វិលសំណុំរឿង ដោយភ្ជាប់ជាមួយនឹងដីកាសន្និដ្ឋានស្ថាពរនេះផងដែរ គឺព្រះរាជអាជ្ញានឹងធ្វើការបង្វិលមកវិញក្នុងចន្លោះរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បើជនត្រូវចោទត្រូវឃុំខ្លួន និង ០១ (មួយ) ខែ បើជនត្រូវចោទនៅក្រៅឃុំ ហើយចិរវេលានៃការបង្វិលគិតចាប់ពីថ្ងៃដែល ព្រះរាជអាជ្ញាទទួលបានដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យ។ ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា គឺធ្វើឡើងជាលាយលក្ខណ៍អក្សរ ព្រមទាំងមានសំអាងហេតុដូចនឹងអ្វីដែលច្បាប់កំណត់ ហើយសំអាងហេតុនេះទៀតសោតអាចជាការសម្រេចបញ្ជូនជនត្រូវចោទទៅតុលាការជំនុំជម្រះ ឬ ធ្វើការលើកលែងចោទប្រកាន់ ដោយអាស្រ័យទៅលើចម្លើយរបស់ភាគីពាក់ព័ន្ធ នៅក្នុងសំណុំរឿងព្រហ្មទណ្ឌ ដោយធ្វើការឆ្លើយទាំង ០៣ (បី) ដំណាក់កាលរួមមានដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ តំណាងអយ្យការ និងចៅក្រមស៊ើបសួរ ក៏ដូចជាភស្តុតាងដែល ភាគីធ្វើការដាក់ជូនតុលាការដើម្បីពិនិត្យ និងភស្តុតាងដែលតុលាការរកឃើញ។

ចំពោះ ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញានៅសាលាដំបូង សង្កេតឃើញថាមិនចងកាតព្វកិច្ចដល់ចៅក្រមស៊ើបសួរឡើយ ពោលគឺចៅក្រមស៊ើបសួរនឹងធ្វើសេចក្តីសម្រេចបិទបញ្ចប់ការស៊ើបសួររបស់ខ្លួន ដោយសេចក្តីសម្រេចនេះ អាចជាការសម្រេចឱ្យលើកលែងចោទប្រកាន់ ឬ បញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ទៅតាមបន្ទុកភស្តុតាងដែលខ្លួនរកឃើញ ដែលមិនអាស្រ័យទៅតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទាំងស្រុងនោះទេ។ ក្នុងករណីនេះផងដែរ ប្រសិនបើព្រះរាជអាជ្ញាមិនយល់ស្របទៅនឹងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរទេនោះ គឺព្រះរាជអាជ្ញាអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនដោយធ្វើការប្តឹងទៅកាន់សភាស៊ើបសួរ តាមរយៈការធ្វើបណ្តឹងឧទ្ធរណ៍ នេះបើយោងទៅតាមស្មារតីមាត្រា ២៦៦ និងមាត្រា ២៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

### ២.១.៤. ដីកាដំណោះស្រាយ

បន្ទាប់ពីចៅក្រមស៊ើបសួរទទួលបាននូវសំណុំរឿង និងដីកាសន្និដ្ឋានស្ថាពរពីព្រះរាជអាជ្ញាហើយ នោះចៅក្រមស៊ើបសួរនឹងបន្តចំណាត់ការរបស់ខ្លួនក្នុងការបិទការស៊ើបសួរ ដោយធ្វើការចេញនូវដីកាដំណោះស្រាយ។ ចំពោះដីកាដំណោះស្រាយ គឺចៅក្រមស៊ើបសួរអាចនឹងសម្រេចអំពីការបញ្ជូនទៅជំនុំ- ជម្រះ ឬ លើកលែងចោទប្រកាន់ ដោយអាស្រ័យលើភស្តុតាងដាក់បន្ទុក និងដោះបន្ទុក ក្រោមទម្រង់ ជាដីកាដំណោះស្រាយ ឬ ដីកាបញ្ជូនទៅជំនុំជម្រះ ឬ ដីកាលើកលែងចោទប្រកាន់ អាស្រ័យតាមការ កំណត់របស់ចៅក្រមស៊ើបសួរនីមួយៗនៃសាលាដំបូង។ ទន្ទឹមនឹងនេះផងដែរ ដីកានេះគឺ មានចង្អុលបង្ហាញអំពីអត្តសញ្ញាណរបស់ជនត្រូវចោទ ឈ្មោះបទល្មើស ក៏ដូចជាអត្ថបទច្បាប់ដែល កំណត់ថាជាបទល្មើស ព្រមទាំងសំអាងហេតុក្នុងការដាក់បន្ទុក ឬ ដោះបន្ទុកទៅលើជនត្រូវចោទ ហើយដីកាដំណោះស្រាយនេះ ត្រូវមានការចុះកាលបរិច្ឆេទនៃការចេញដីការួមទាំងហត្ថលេខារបស់ចៅក្រម និងក្រឡាបញ្ជីអមជាមួយផង។

#### ២.១.៤.១. ការជូនដំណឹងអំពីដីកាដំណោះស្រាយ

❖ ការជូនដំណឹងទៅព្រះរាជអាជ្ញ

នៅពេលដែលចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយរួចរាល់ហើយ ចៅក្រមស៊ើបសួរនឹង បញ្ជូនដីកាដំណោះស្រាយទៅតំណាងអយ្យការក្នុងរយៈពេលខ្លីបំផុត ដោយការបញ្ជូនដីកាដំណោះស្រាយ ទៅតំណាងអយ្យការនេះផងដែរ គឺត្រូវមានការចុះហត្ថលេខាពីសំណាក់តំណាងអយ្យការ នៅលើដីកា ដំណោះស្រាយ ដើម្បីបញ្ជាក់អំពីការបានទទួលដំណឹងអំពីដីកាដំណោះស្រាយ។ នៅពេលដែលតំណាង អយ្យការទទួលបានដីកាដំណោះស្រាយពីចៅក្រមស៊ើបសួរហើយ ព្រះរាជអាជ្ញាអាចប្រើប្រាស់សិទ្ធិ អំណាចរបស់ខ្លួនដែលក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់ឱ្យ ដោយធ្វើការប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីដីកាដំណោះស្រាយ ប៉ុន្តែចំពោះតថភាពនៃការអនុវត្តជាក់ស្តែង នៅមណ្ឌលកម្មសិក្សា ករណីប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាចំពោះដីកាដំណោះស្រាយនេះ គឺកម្រកើតមានណាស់។

❖ លិខិតជូនដំណឹងអំពីដីកាដំណោះស្រាយ

ចៅក្រមស៊ើបសួរត្រូវធ្វើការជូនដំណឹងទាក់ទងនឹងដីកាដំណោះស្រាយទៅឱ្យភាគីដែលពាក់ព័ន្ធ នៅក្នុងសំណុំរឿងក្តីព្រហ្មទណ្ឌ ដោយក្នុងនោះរួមមាន ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី មេធាវី។ ការជូនដំណឹងនេះផងដែរ នៅមណ្ឌលកម្មសិក្សានៃសាលាដំបូង គឺចៅក្រមស៊ើបសួរធ្វើការ ជូនដំណឹង ក្រោមទម្រង់ជាលិខិតជូនដំណឹងអំពីដីកាដំណោះស្រាយ ទៅកាន់ភាគីដែលពាក់ព័ន្ធនៅក្នុង សំណុំរឿង ហើយបន្ទាប់មកទៀត ចៅក្រមស៊ើបសួរត្រូវធ្វើការបញ្ជូនលិខិតនោះទៅឱ្យភាគី ដើម្បីឱ្យ បានដឹងអំពីចំណាត់ការនៃសំណុំរឿងនៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរត្រូវបានបិទបញ្ចប់ ហើយក្នុងនោះចៅក្រមស៊ើបសួរអាចធ្វើការសម្រេចលើកលែងចោទ

ប្រកាន់ទៅលើជនត្រូវចោទ ឬ បញ្ជូនទៅជំនុំជម្រះ។ ជាមួយគ្នានេះផងដែរ ចំពោះការបញ្ជូនលិខិតជូនដំណឹងអំពីដីកាដំណោះស្រាយរបស់ចៅក្រម ស៊ើបសួរ គឺមានលក្ខណៈដូចទៅនឹងការបញ្ជូនលិខិតជូនដំណឹងអំពីការបិទការស៊ើបសួរដែរ ជាហេតុមិន ធ្វើការបកស្រាយឡើងវិញអំពីការបញ្ជូនលិខិតជូនដំណឹងអំពីដីកាដំណោះស្រាយម្តងទៀតឡើយ។

**២.១.៤.២. អានុភាពនៃដីកាដំណោះស្រាយ**

❖ ការបញ្ចប់អានុភាពនៃការឃុំបណ្តោះអាសន្ន

ដីកាដំណោះស្រាយបញ្ចប់ការឃុំខ្លួនបណ្តោះអាសន្ន។ ប៉ុន្តែ តាមសេចក្តីសម្រេចដោយឡែក ដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរអាចរក្សាជនត្រូវចោទឱ្យនៅជាប់ឃុំបណ្តោះអាសន្ន រហូតដល់ពេលចូលបង្ហាញខ្លួននៅមុខតុលាការ។ នៅក្នុងដីកានេះផងដែរ ចៅក្រមស៊ើបសួរត្រូវមានសំអាងហេតុទៅលើសេចក្តីសម្រេចរក្សាទុកឱ្យនៅក្នុងឃុំជាបណ្តោះអាសន្ន ដោយមូលហេតុណាមួយក្នុង ចំណោមមូលហេតុនានាដូចមានចែងក្នុងមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ កាលណាការឃុំខ្លួន បណ្តោះអាសន្ននេះជាការចាំបាច់៖

១- ដើម្បីបញ្ចប់បទល្មើស ឬ បង្ការបទល្មើសកុំឱ្យកើតជាថ្មី។

២- ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬ ជនរងគ្រោះ ឬ ដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត ។

៣- ដើម្បីរក្សាភស្តុតាង ឬ តម្រុយជាសម្ភារៈ។

៤- ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី។

៥- ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ។

៦- ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឱ្យមានការច្របូកច្របល់ ដែលបណ្តាល មកពីបទល្មើស។

ចំពោះករណីអនីតិជនវិញ ឃើញថា ច្បាប់ស្តីពីយុត្តិធម៌អនីតិជន បានធ្វើការគាំពារសិទ្ធិរបស់ អនីតិជនជាជាងសិទ្ធិរបស់នីតិជន ដោយកំណត់ថា "ដើម្បីជាឧត្តមប្រយោជន៍របស់អនីតិជនក្នុងពេល រង់ចាំការជំនុំជម្រះ តុលាការត្រូវពិចារណាដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នឱ្យមានសេរីភាព។" ប៉ុន្តែករណីពាក់ព័ន្ធនឹងការពន្យារពេលក្នុងការរក្សាជនត្រូវចោទ ដែលជាអនីតិជនឱ្យនៅជាប់ឃុំជាបណ្តោះអាសន្ននេះ ក៏មិនមែនជាលក្ខខណ្ឌដាច់ខាត ដើម្បីឱ្យតុលាការធ្វើការដោះលែងជន នេះឱ្យមានសេរីភាពវិញដែរ ពោលគឺជាឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរក្នុងការសម្រេចបន្តឃុំខ្លួនជា បណ្តោះអាសន្ន ដើម្បីរក្សាជននេះទុកជូនតុលាការជំនុំជម្រះ ឬ ធ្វើការដោះលែងឱ្យមានសេរីភាពជា បណ្តោះអាសន្ន។

ពាក់ព័ន្ធនឹងសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយនេះផងដែរ ឃើញថា ជនត្រូវចោទនឹងត្រូវដោះលែងនៅក្រៅឃុំជាបណ្តោះអាសន្នដោយឯកឯង ប្រសិនបើ ជនត្រូវចោទមិនបានចូលបង្ហាញ ខ្លួននៅមុខ

តុលាការក្នុងរយៈពេល ០៤ (បួន) ខែ គិតពីកាលបរិច្ឆេទនៃការចេញដីកាបញ្ជូនទៅជំនុំជម្រះ យោងតាមវាក្យខណ្ឌទី២ នៃកថាខណ្ឌទី៣ នៃមាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ដោយឡែក ចំពោះការដោះលែងឱ្យមានសេរីភាព តាមអំណាចដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ ឃើញថា យោងតាមមាត្រា ២៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់អំពីការដោះលែងឱ្យ មានសេរីភាព ថានឹងមានអានុភាពជាក់លាក់ លុះត្រាតែផុតចិរវេលាប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា លើកលែងតែព្រះរាជអាជ្ញា យល់ព្រមឱ្យដោះលែងភ្លាមៗ។ ប្រសិនបើ ព្រះរាជអាជ្ញាប្តឹងឧទ្ធរណ៍ពីដីកា លើកលែងចោទប្រកាន់ ជនត្រូវចោទ ដែលជាប់ឃុំជាបណ្តោះអាសន្ន ត្រូវរក្សាទុកក្នុងពន្ធនាគារបន្តរហូត ដល់ពេលដែលសភាស៊ើបសួរសម្រេចអំពី បណ្តឹងឧទ្ធរណ៍នេះ។ ប្រសិនបើ សភាស៊ើបសួរយល់ស្របនឹង ដីកាលើកលែងចោទប្រកាន់នេះ គឺជនត្រូវចោទ នឹងត្រូវដោះលែងឱ្យមានសេរីភាពភ្លាម តែផ្ទុយទៅវិញប្រសិនបើ សភាស៊ើបសួរសម្រេចចេញសាលដីកាដំណោះស្រាយបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ សភាស៊ើបសួរត្រូវសម្រេចអំពីការរក្សាជនត្រូវចោទឱ្យនៅក្នុងឃុំជាបណ្តោះអាសន្ន។

ជាគោលការណ៍ ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរនឹងបញ្ចប់អានុភាពនៃការឃុំខ្លួនបណ្តោះអាសន្ន។ ប៉ុន្តែ ចៅក្រមស៊ើបសួរអាចរក្សាជនត្រូវចោទឱ្យនៅជាប់ឃុំបណ្តោះអាសន្ន រហូតដល់ពេលចូលបង្ហាញខ្លួននៅមុខតុលាការ តាមអំណាចនៃដីកាសម្រេចរក្សាជនត្រូវចោទឱ្យនៅក្នុងឃុំ ជាបណ្តោះអាសន្ន។ នៅក្នុងដីកាសម្រេចរក្សាជនត្រូវចោទឱ្យនៅក្នុងឃុំជាបណ្តោះអាសន្ននេះ ចៅក្រមស៊ើបសួរត្រូវមានសំអាងហេតុ ដោយមូលហេតុណាមួយក្នុងចំណោមមូលហេតុនានា ដូចជា ដើម្បីបញ្ចប់បទល្មើស ឬ ដើម្បីបង្ការទប់ស្កាត់បទល្មើស កុំឱ្យកើតជាថ្មី ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬ ជនរងគ្រោះ ឬ ដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នា រវាងជនត្រូវចោទ និងអ្នកសមគំនិត ក្នុងគោលដៅ ដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធីក៏ដូចជាដើម្បីការពារជនត្រូវចោទ និងរក្សាសណ្តាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស។

បន្ទាប់ពីចៅក្រមស៊ើបសួរ សម្រេចរក្សាជនត្រូវចោទឱ្យនៅក្នុងឃុំជាបណ្តោះអាសន្នហើយនោះ ចៅក្រមស៊ើបសួរនឹងបញ្ជូនដីកានេះទៅឱ្យប្រធានពន្ធនាគារដើម្បីរក្សាជនត្រូវចោទទុកជូនតុលាការ រហូតដល់ពេលជំនុំជម្រះ។ ចៅក្រមស៊ើបសួរនឹងបន្តចំណាត់ការរបស់ខ្លួនក្នុងការបញ្ជូនសំណុំរឿងព្រហ្មទណ្ឌដែលបានបិទបញ្ចប់ការស៊ើបសួរតាមរយៈដីកាដំណោះស្រាយទៅប្រធានសាលាដំបូង ដើម្បីឱ្យប្រធានសាលាដំបូងចាត់តាំងចៅក្រមជំនុំជម្រះ ឬ ក្រុមប្រឹក្សាជំនុំជម្រះ ដោយជៀសវាងនូវការអូសបន្លាយ ក្នុងការកំណត់កាលបរិច្ឆេទជំនុំជម្រះ ព្រោះថាដីកាសម្រេចរក្សាជនត្រូវចោទឱ្យនៅក្នុងឃុំបណ្តោះអាសន្ន នេះមានតែរយៈពេល ០៤ (បួន) ខែ ប៉ុណ្ណោះ គិតពីកាលបរិច្ឆេទនៃការចេញដីកាបញ្ជូនទៅជំនុំជម្រះ។ ចំពោះអានុភាពនៃដីកាសម្រេចរក្សាជនត្រូវចោទឱ្យនៅ

ក្នុងឃុំជាបណ្ដោះអាសន្ននេះផងដែរ គឺឃើញថា បើទោះបីជាក្នុងរយៈពេល ០៤ (បួន) ខែ ជនត្រូវចោទមិនបាន បង្ហាញខ្លួននៅមុខតុលាការជំនុំជម្រះក៏ដោយ ក៏ប្រធានពន្ធនាគារមិនដោះលែងឱ្យជននោះមានសេរីភាពដែរ ដោយហេតុថា រាល់ការសម្រេច ឃុំខ្លួន ឬ សម្រេចដោះលែងជនត្រូវចោទនីមួយៗអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការសម្រេចអនុញ្ញាត ពីតុលាការជាមុនសិន។ ដូច្នេះ នៅមណ្ឌលកម្មសិក្សាខេត្តកណ្ដាល ចំពោះសំណុំរឿងព្រហ្មទណ្ឌដែល ជនត្រូវចោទស្ថិតនៅក្នុងឃុំជាបណ្ដោះអាសន្ន តាមអំណាចនៃដីការក្សាជនត្រូវចោទឱ្យនៅក្នុងឃុំជា បណ្ដោះអាសន្ន គឺចៅក្រមតែងតែមានភាពប្រុងប្រយ័ត្នខ្ពស់ និងតាមដានជាប្រចាំ ដោយហេតុថាជៀសវាងនូវការឃុំខ្លួនជនត្រូវចោទហួសពេលកំណត់ ក៏ដូចជាការប្ដឹងពីសំណាក់ជនត្រូវចោទពាក់ព័ន្ធ នឹងការឃុំខ្លួនដោយខុសច្បាប់។

❖ ការបញ្ចប់អានុភាពនៃការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

កថាខណ្ឌទី ៤ នៃមាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ កំណត់អំពីអានុភាពនៃដីកាដំណោះស្រាយដែលបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ។ ក្នុងករណីដែលជនត្រូវចោទជាប់កាតព្វកិច្ចនៃការត្រួត ពិនិត្យតាមផ្លូវតុលាការ ដោយចៅក្រមស៊ើបសួរដាក់កំហិតឱ្យបង់ប្រាក់ធានា ឬ ឱ្យប្រគល់ឯកសារបញ្ជាក់ អត្តសញ្ញាណ ឬ ឱ្យប្រគល់អាវុធមិនទាក់ទិនបទល្មើស ហើយវត្ថុទាំងនេះត្រូវប្រគល់សងសាមីខ្លួនវិញ ដោយក្រឡាបញ្ជី ដោយមានបង្កាន់ដៃទទួលទុកជាសម្គាល់។ ប៉ុន្តែតាមរយៈសេចក្ដីសម្រេចដោយឡែក នៃដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរអាចរក្សាទុកជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាម ផ្លូវតុលាការ រហូតដល់ពេលចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ ផ្អែកតាមកថាខណ្ឌទី ៥ និងកថាខណ្ឌ ទី៦ នៃមាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ចំពោះកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ អាចត្រូវរក្សាទុកតាមបែបបទតែមួយដូចនឹងការឃុំខ្លួនបណ្ដោះអាសន្នរហូតដល់ពេលចូលបង្ហាញខ្លួននៅមុខតុលាការ។ ការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវបញ្ចប់នៅពេលប្រកាសសាលក្រម។

ចំពោះអានុភាពនៃដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ នឹងបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ។ ករណីដែលជនត្រូវចោទជាប់កាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយចៅក្រមស៊ើបសួរតម្រូវឱ្យបង់ប្រាក់ធានា ឬ ឱ្យប្រគល់ឯកសារបញ្ជាក់អត្តសញ្ញាណ ឬ ឱ្យប្រគល់អាវុធមិន ទាក់ទិនបទល្មើស ចំពោះវត្ថុទាំងនេះត្រូវប្រគល់សងសាមីខ្លួនវិញដោយក្រឡាបញ្ជី នៅពេលដែលមាន ការដាក់ពាក្យសុំពីសំណាក់ភាគី បើពុំដូច្នោះទេការសម្រេចអំពីការប្រគល់ទាំងនេះ គឺទុកសិទ្ធិឱ្យចៅក្រម ជំនុំជម្រះជាអ្នកសម្រេចប្រគល់វត្ថុនោះទៅភាគីវិញ។ ជាមួយគ្នានេះផងដែរ ចំពោះករណីដែលចៅក្រម ស៊ើបសួរ មានបំណងក្នុងការរក្សាទុកជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ រហូតដល់ពេលចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ តាមអំណាចសេចក្ដីសម្រេចដោយឡែកនៃដីកា ដំណោះស្រាយ ដូចទៅនឹងការរក្សាទុកជនត្រូវចោទឱ្យនៅក្នុងឃុំជាបណ្ដោះអាសន្ន

នោះ គឺមិនមានការ ជួបប្រទះក្នុងអំឡុងពេលចុះកម្មសិក្សា ក៏ដូចជាក្នុងរយៈពេលនៃការអនុវត្តកន្លងមកនោះទេ។ ដោយហេតុថា ចំពោះវិធានការនៃការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ គឺធ្វើឡើងក្នុងគោលដៅរឹតបន្តឹងនូវសិទ្ធិសេរីភាពមួយចំនួនរបស់ជនត្រូវចោទ ក៏ដូចជាបង្ការនូវការរត់គេចខ្លួនមិនទទួលខុសត្រូវ ព្រោះថាចំពោះករណីនេះ គឺចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួនជនត្រូវចោទរូបនេះទេ។ ដូច្នេះ ចំពោះការរក្សាទុកជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ រហូតដល់ពេលចូលបង្ហាញ ខ្លួននៅចំពោះមុខចៅក្រមជំនុំជម្រះក៏មិនមែនជាករណីចាំបាច់ដែរ ព្រោះថាប្រសិនបើជននេះមានបំណង ក្នុងការគេចវេសមិនចូលមកបង្ហាញខ្លួននៅចំពោះមុខតុលាការទេ នោះចៅក្រមជំនុំជម្រះនឹងប្រើអំណាច របស់ខ្លួនតាមរយៈការចេញសាលក្រមបង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទ ដើម្បីឱ្យមកទទួលទោសតាមផ្លូវ ច្បាប់ជាក់ជាពុំខានឡើយ។

❖ ការបញ្ចប់អានុភាពនៃមោឃភាព

ដីកាដំណោះស្រាយដែលចូលជាស្ថាពរ លុបលាងមោឃភាពនីតិវិធីមុន ប្រសិនបើមាន។ គ្មានមោឃភាពណាមួយនៃនីតិវិធីមុន អាចត្រូវបានលើកឡើងនៅចំពោះមុខតុលាការជំនុំជម្រះបានទៀតឡើយ។ ចំពោះចំណុចនេះផងដែរ គឺមានន័យថា រាល់ពាក្យសុំមោឃភាពនៃកិច្ចនីតិវិធីទាំងអស់ ត្រូវធ្វើឡើងមុនពេលដីកាដំណោះស្រាយចូលជាស្ថាពរ បើពុំដូច្នោះទេ ទោះបីជាកិច្ចនីតិវិធីដែលធ្វើឡើងកន្លង មកនេះ មានមូលហេតុនៃមោឃភាពក៏ដោយ ក៏មិនអាចធ្វើការប្ដឹងសុំបានដែរ ដោយសារអានុភាពស្ថាពរ នៃដីកាដំណោះស្រាយ។ បទប្បញ្ញត្តិនេះមានគោលបំណងក្នុងការរារាំងគូភាគី មិនឱ្យធ្វើការបង្វិលត្រលប់ កិច្ចនីតិវិធីក្នុងការលើកឡើងអំពីភាពមិនប្រក្រតីនៃនីតិវិធីដែលបានធ្វើកន្លងមកទេ ព្រោះថានៅពេលដែល ភាពមិនប្រក្រតីនេះទើបតែលេចចេញមកភ្លាមៗហេតុអ្វីខ្លួនមិនធ្វើការលើកឡើង តែបែរជាលើកឡើងនា ពេលក្រោយទៅវិញ ដែលនេះគឺស្ដែងចេញនូវចេតនាទុច្ចរិតក្នុងការពន្យឺតការងាររបស់តុលាការក្នុងការចាត់ការរឿងក្ដីឱ្យបានទាន់ពេលវេលា និងឆាប់រហ័ស។

អានុភាពនៃដីកាដំណោះស្រាយដែលចូលជាស្ថាពរ នឹងធ្វើការលុបលាងមោឃភាពនៃកិច្ចនីតិវិធី មុនៗ បើទោះបីជាភាគីពិនិត្យឃើញមាននូវភាពមិនប្រក្រតីនៃកិច្ចនីតិវិធី ដែលជាមូលហេតុនៃការប្ដឹង សុំមោឃភាពក៏ដោយ ក៏ភាគីមិនមានសិទ្ធិក្នុងការប្ដឹងទៅសភាស៊ើបសួរអំពីមោឃភាពនេះដែរ។ ពាក់ព័ន្ធនឹងការប្ដឹងសុំមោឃភាពនេះផងដែរ នៅមណ្ឌលកម្មសិក្សាខេត្តកណ្ដាលវិញ សង្កេតឃើញថា រាល់ ពាក្យសុំមោឃភាពនៃកិច្ចនីតិវិធីរបស់ភាគីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌ គឺរមែងតែងតែធ្វើឡើងមុនពេល ដីកាដំណោះស្រាយចូលជាស្ថាពរ ជាហេតុចំពោះការអនុវត្តជាក់ស្ដែង មិនមានភាពខុសគ្នាទៅនឹងអ្វីដែល ច្បាប់បានកំណត់នោះឡើយ ។

❖ ការផ្លាស់ប្ដូរឋានៈរបស់ជនត្រូវចោទ

បន្ទាប់ពីដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរបានចូលជាស្ថាពររួចហើយ ចំពោះជនដែលស្ថិតក្នុងដំណាក់កាលចៅក្រមស៊ើបសួរ ដែលត្រូវបានគេស្គាល់ថាជាជនត្រូវចោទនោះ ត្រូវបានផ្លាស់ប្ដូរ ឋានៈរបស់

ខ្លួនភ្លាម ដោយប្រែក្លាយពីជនត្រូវចោទ មកជាជនជាប់ចោទ។ បើទោះបីជាជននេះប្រែឋានៈ ជាជនជាប់ចោទក៏ពិតមែន ប៉ុន្តែបើយោងតាមស្មារតីនៃលិខិតបទដ្ឋានគតិយុត្តអន្តរជាតិបានកំណត់ថា "ជនណាដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ត្រូវសន្មតជាជនគ្មានទោសរហូតដល់ពិរុទ្ធភាពត្រូវបាន រកឃើញ នៅក្នុងសវនាការជាសាធារណៈដែលមានការធានាចាំបាច់ដើម្បីឱ្យជននោះការពារខ្លួន។"

អានុភាពនៃដីកាដំណោះស្រាយដែលបានចូលជាស្ថាពរហើយនោះ នឹងធ្វើការផ្លាស់ប្តូរឋានៈរបស់ជនត្រូវចោទ ឱ្យក្លាយជាជនជាប់ចោទ ក្នុងករណីដែលដីកាដំណោះស្រាយនេះ ជាប្រភេទដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ។ ចំពោះដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះដែលចូលជាស្ថាពរ នឹងធ្វើការ ផ្លាស់ប្តូរឋានៈរបស់ជនត្រូវចោទ ដើម្បីអាចឱ្យជននេះធ្វើការបង្ហាញខ្លួននៅចំពោះមុខចៅក្រមជំនុំជម្រះ ព្រមទាំងជាកាតព្វកិច្ចចងតុលាការជំនុំជម្រះក្នុងការបើកសវនាការសម្រេចសេចក្តីថាជនជាប់ចោទដែល ចៅក្រមស៊ើបសួរធ្វើការបញ្ជូនមកនោះ ថាពិតជាមានពិរុទ្ធភាពក្នុងការប្រព្រឹត្តបទល្មើសដែរឬយ៉ាងណា? ចំពោះការអនុវត្តនៅមណ្ឌលកម្មសិក្សានៃសាលាដំបូង និងអយ្យការអមសាលាដំបូង ឋានៈរបស់ជនត្រូវចោទនេះផងដែរ គឺប្រែប្រួលនៅពេលដែលដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរបាន ចូលជាស្ថាពរ។

### ២.២. សេចក្តីសម្រេចបិទកិច្ចស៊ើបសួរនៅជំណាក់កាលសាលាដំបូងរាជធានី/ខេត្ត

ផ្អែកតាមស្មារតីមាត្រា ២៤៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ សង្កេតឃើញថា ចៅក្រមស៊ើបសួរបិទការស៊ើបសួរតាមដីកាដំណោះស្រាយ ដោយដីកានេះអាចជាដីកាបញ្ជូនទៅជំនុំជម្រះ ឬ ដីកាលើកលែងចោទប្រកាន់។ ដីកាដំណោះស្រាយ ត្រូវបង្ហាញឈ្មោះបទល្មើស ប្រភេទអត្ថបទច្បាប់ ដែលនឹងដាក់បន្ទុកទៅលើជនត្រូវចោទ ព្រមជាមួយនឹងមូលហេតុដែលមាន ឬ គ្មានការដាក់បន្ទុកគ្រប់គ្រាន់ ប្រឆាំងនឹងបុគ្គលនោះ។ ដីកាដំណោះស្រាយនេះផងដែរ ធ្វើឱ្យមានការប្រគល់សងឯកសារអត្តសញ្ញាណ ដែលបានសុំក្នុងពេលស៊ើបសួរ និងអាវុធដែលបានចាប់យកក្នុងលក្ខខណ្ឌដែលអាវុធនោះមិនបានប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស និងប្រាក់ធានាដែលជនត្រូវចោទត្រូវបានបង្ខំឱ្យបង់ ជាអាទិ៍។

ជានិច្ចកាល ដីកាដំណោះស្រាយត្រូវមានសំអាងហេតុ និងត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុត ដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។ ដីកាដំណោះស្រាយ អាចប្តឹងឧទ្ធរណ៍ដោយ ព្រះរាជអាជ្ញា និងជនត្រូវចោទ ក៏ដូចជាដើមបណ្តឹងរដ្ឋប្បវេណី[73] ហើយថិរវេលានៃការធ្វើបណ្តឹងឧទ្ធរណ៍ មានរយៈពេល ០៥ (ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីដីកាដំណោះស្រាយ ឬ ប្រសិនបើការជូនដំណឹង ធ្វើឡើងដោយការប្រគល់សេចក្តីចម្លងនៃដីកាដោយមានចំណារទទួល នោះរយៈពេលប្តឹងឧទ្ធរណ៍ ផ្តើម គិតចាប់ពីកាលបរិច្ឆេទនៃចំណារ

[73] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា២៦៦ មាត្រា ២៦៧ និងមាត្រា ២៦៨។

ទទួលនោះ។[74] នៅក្នុងដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរសមច អំពីការប្រគល់សងទៅឱ្យម្ចាស់ដើមវិញនូវវត្ថុដែលចាប់យក។ បទប្បញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា ១១៩ (អាជ្ញាធរមានសមត្ថកិច្ចបង្គាប់ឱ្យប្រគល់វត្ថុជូនម្ចាស់ដើមវិញ) នៃក្រមនេះ ក៏ត្រូវយកមកអនុវត្តដែរ។[75]

ចំពោះដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរនេះផងដែរ ចៅក្រមស៊ើបសួរមិនជាប់កាតព្វកិច្ច ត្រូវគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញានោះទេ ដោយចៅក្រមស៊ើបសួរអាចចេញនូវដីកា បញ្ជូនទៅជំនុំជម្រះចំពោះអំពើមួយចំនួន (២.២.១) និងអាចជាដីកាលើកលែងចោទប្រកាន់ (២.២.២) បានផងដែរ។

**២.២.១. ដីកាបញ្ជូនរឿងទៅជំនុំជម្រះ**

យោងតាមអត្ថន័យមាត្រា ២៤៧ថ្មី កថាខណ្ឌទី២ នៃច្បាប់ស្តីពីវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់ថា កាលណាយល់ឃើញថា អំពើនោះ ជាបទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ ចៅក្រមស៊ើបសួរ សម្រេចបញ្ជូនជនត្រូវចោទទៅមុខតុលាការជំនុំជម្រះ ដោយដីកាបញ្ជូននោះ ត្រូវរៀបរាប់អំពីអំពើដែល ត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់។ នៅពេលចៅក្រមស៊ើបសួរយល់ឃើញថា ជនត្រូវចោទ មានពិរុទ្ធភាពគ្រប់គ្រាន់ស៊ីសង្វាក់នឹងអង្គហេតុ ក៏ដូចជាភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ ដែលអំពើរបស់ជនត្រូវចោទបង្កបានជាបទល្មើសព្រហ្មទណ្ឌ នោះចៅក្រមស៊ើបសួរនឹងធ្វើការបញ្ជូនសំណុំ រឿង និងជនត្រូវចោទទៅជំនុំជម្រះ។ ប្រសិនបើចៅក្រមស៊ើបសួរសម្រេចចេញដីកាបញ្ជូនសំណុំរឿង ទៅជំនុំជម្រះ ចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងជាបន្ទាន់ទៅកាន់ប្រធានតុលាការ ដើម្បីកំណត់ពេល សវនាការជំនុំជម្រះ។[76]

**២.២.២. ដីកាលើកលែងចោទប្រកាន់**

ដីកាលើកលែងចោទប្រកាន់ គឺជាទម្រង់មួយនៃដីកាដំណោះស្រាយ ដែលចៅក្រមស៊ើបសួរសម្រេចថា មិនបញ្ជូនជនត្រូវចោទទៅជំនុំជម្រះនោះទេ។ ចំពោះចំណុចនេះមានន័យថា ចៅក្រមស៊ើបសួរមាន សិទ្ធិក្នុងការសម្រេចលើកលែងការចោទប្រកាន់លើជនត្រូវចោទដែលទទួលរងនូវការចោទប្រកាន់ដាក់ បន្ទុកពីសំណាក់ព្រះរាជអាជ្ញា។ ប៉ុន្តែ ទន្ទឹមនឹងការសម្រេចចេញនូវការលើកលែងចោទប្រកាន់នេះដែរ ចៅក្រមស៊ើបសួរត្រូវមានសំអាងហេតុ និងមូលហេតុដែលចៅក្រមស៊ើបសួរអាចសម្រេចបាន ក្នុងករណី ដូចដែលមានកំណត់ដូចខាងក្រោមនេះ ៖

១- អំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ។

២- ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់។

---

[74] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា២៧០។

[75] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា២៤៨។

[76] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ២៥០។

៣- គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ។

៤- ករណីដែលបណ្តឹងអាជ្ញារលត់ ។[77]

ក្នុងករណីដែលមានការលើកលែងចោទប្រកាន់ដោយមូលហេតុអត្តសញ្ញាណរបស់ជនត្រូវចោទ មិនត្រូវបានស្គាល់ ឬ ក្នុងករណីដែលជនត្រូវចោទទទួលមរណភាព ចៅក្រមស៊ើបសួរអាចប្តឹងទៅតុលាការ ព្រហ្មទណ្ឌតាមដីកាបញ្ជូនឱ្យសម្រេចរឹបអូសឧបករណ៍ សម្ភារៈ មូលនិធិ ផលទុន ឬទ្រព្យសម្បត្តិ ប្រសិន បើមានការសង្ស័យដោយសមហេតុផលថា ឧបករណ៍ សម្ភារៈ មូលនិធិ ផលទុន ឬទ្រព្យសម្បត្តិទាំងនោះ ពាក់ព័ន្ធនឹងបទល្មើស។ ក្នុងករណីនេះ តុលាការព្រហ្មទណ្ឌត្រូវសម្រេចអំពីការរឹបអូសដោយសាលក្រម ក្នុងសវនាការជាសាធារណៈ ដោយមានការចូលរួមពីតំណាងអយ្យការ និងបុគ្គលពាក់ព័ន្ធ ប្រសិនបើមាន។ សាលក្រមដែលសម្រេចអំពីការរឹបអូសត្រូវបិទផ្សាយនៅទីកន្លែងដែលតុលាការបានចេញសាលក្រម និងផ្សាយជាសាធារណៈតាមសារព័ត៌មាន ឬ មធ្យោបាយទូរគមនាគមន៍សោតទស្សន៍។ បុគ្គលដែលមាន ប្រយោជន៍ពាក់ព័ន្ធ ឬ ដែលអះអាងថាខ្លួនជាម្ចាស់នៃវត្ថុដែលជាកម្មវត្ថុនៃការរឹបអូស មានសិទ្ធិប្តឹងឧទ្ធរណ៍ ប្រឆាំងនឹងសេចក្តីសម្រេចនោះបានក្នុងរយៈពេល ០១ (មួយ) ខែ គិតពីថ្ងៃប្រកាសសាលក្រម ប្រសិនបើ បុគ្គលនេះបានចូលរួមនៅក្នុងនីតិវិធីនៃការជំនុំជម្រះរបស់តុលាការ និងក្នុងរយៈពេល ០២ (ពីរ) ខែ គិត ពីថ្ងៃប្រកាសផ្សាយជាសាធារណៈតាមសារព័ត៌មាន ឬ មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ប្រសិន បើបុគ្គលនេះមិនបានចូលរួមនៅក្នុងនីតិវិធីតុលាការ។[78]

ដោយឡែក ក្នុងករណីដែលសភាស៊ើបសួរទទួលបន្ទុកក្នុងការស៊ើបសួរ និងដឹកនាំនីតិវិធីដោយ ខ្លួនឯងផ្ទាល់ ដីកាលើកលែងចោទប្រកាន់នេះ គឺចេញដោយសភាស៊ើបសួរ ហើយសភាស៊ើបសួរបិទការ ស៊ើបសួរតាមសាលដីកាដំណោះស្រាយ និងមានអានុភាពដោះលែងជនត្រូវចោទដែលជាប់ឃុំភ្លាម ផ្អែក តាមបញ្ញត្តិមាត្រា ២៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ មាត្រា ២៦៨ នៃក្រមដដែល ក៏បានផ្តល់សិទ្ធិឱ្យ ដើមបណ្តឹងរដ្ឋប្បវេណី អាចធ្វើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធជាមួយនឹងដីកាលើកលែងចោទប្រកាន់នេះបាន ផងដែរ។ ជាមួយគ្នានេះដែរ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍ ចំពោះគ្រប់ដីកាសម្រេចទាំងអស់របស់ចៅក្រមស៊ើបសួរបាន។[79]

សេចក្តីសម្រេចលើកលែងចោទប្រកាន់មិនរំលត់បណ្តឹងអាជ្ញាទេ ព្រោះប្រសិនបើការលើកលែង ចោទប្រកាន់ មានហេតុផលមកពីអវត្តមាននៃបន្ទុកគ្រប់គ្រាន់ប្រឆាំងនឹងជនត្រូវចោទ ឬ មកពីការពុំ ស្គាល់ចារី ហើយ

---

[77] ច្បាប់ស្តីពីវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៦១៣/០០៩, ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៣, មាត្រា ២៤៧ថ្មី។

[78] ច្បាប់ស្តីពីវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៦១៣/០០៩, ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៣, កថាខណ្ឌទី៧ និង កថាខណ្ឌទី៨ នៃមាត្រា ២៤៧ថ្មី។

[79] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ២៦៦។

ក្រោយមករកឃើញមាននូវបន្ទុកថ្មី គឺអនុញ្ញាតឱ្យបើកការស៊ើបសួរទៅលើអង្គហេតុតែមួយជាថ្មីម្តងទៀត តាមការផ្តើមគំនិតរបស់ព្រះរាជអាជ្ញា នេះបើយោងតាមស្មារតីមាត្រា ២៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## ៣. អានុភាពនៃការបិទកិច្ចស៊ើបសួរនៅដំណាក់កាលសាលាដំបូងរាជធានី/ខេត្ត

ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ បង្កើតឱ្យមាននូវការបញ្ចប់អានុភាពនៃការឃុំខ្លួន បណ្តោះអាសន្ន (៣.១) បញ្ចប់អានុភាពនៃការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ (៣.២) បញ្ចប់អានុភាពនៃមោឃភាព (៣.៣) ព្រមទាំងការផ្លាស់ប្តូរឋានៈរបស់ជនត្រូវចោទ (៣.៤)។

### ៣.១. ការបញ្ចប់អានុភាពនៃការឃុំខ្លួនបណ្តោះអាសន្ន

ដីកាដំណោះស្រាយបញ្ចប់ការឃុំខ្លួនបណ្តោះអាសន្ន។ ប៉ុន្តែ តាមសេចក្តីសម្រេចដោយឡែកដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរអាចរក្សាជនត្រូវចោទឱ្យនៅជាប់ឃុំបណ្តោះអាសន្ន រហូតដល់ ពេលចូលបង្ហាញខ្លួននៅមុខតុលាការ។[80] នៅក្នុងដីកានេះផងដែរ ចៅក្រមស៊ើបសួរ ត្រូវមានសំអាងហេតុទៅលើសេចក្តីសម្រេចរក្សាទុកឱ្យនៅក្នុងឃុំជាបណ្តោះអាសន្ន ដោយមូលហេតុណាមួយក្នុង ចំណោមមូលហេតុនានាដូចមានចែងក្នុងមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ កាលណាការឃុំខ្លួនបណ្តោះអាសន្ននេះជាការចាំបាច់ ៖

១- ដើម្បីបញ្ចប់បទល្មើស ឬ បង្ការបទល្មើសកុំឱ្យកើតជាថ្មី។

២- ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬ ជនរងគ្រោះ ឬ ដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត ។

៣- ដើម្បីរក្សាភស្តុតាង ឬ តម្រុយជាសម្ភារៈ។

៤- ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី។

៥- ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ។

៦- ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឱ្យមានការច្របូកច្របល់ ដែលបណ្តាល មកពីបទល្មើស។

ចំពោះករណីអនីតិជនវិញ ឃើញថា ច្បាប់ស្តីពីយុត្តិធម៌អនីតិជន បានធ្វើការគាំពារសិទ្ធិរបស់ អនីតិជនជាជាងសិទ្ធិរបស់នីតិជន ដោយកំណត់ថា "ដើម្បីជាឧត្តមប្រយោជន៍របស់អនីតិជនក្នុងពេល រង់ចាំការជំនុំជម្រះ តុលាការត្រូវពិចារណាដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នឱ្យមានសេរីភាព។"[81] ប៉ុន្តែករណីពាក់ព័ន្ធនឹងការពន្យារពេលក្នុងការរក្សាជនត្រូវចោទ ដែលជាអនីតិជនឱ្យនៅជាប់ឃុំជាបណ្តោះអាសន្ននេះ ក៏មិនមែនជាលក្ខខណ្ឌដាច់ខាត ដើម្បីឱ្យតុលាការធ្វើការដោះលែងជន នេះឱ្យមានសេរីភាពវិញដែរ ពោលគឺជាឆន្ទានុសិទ្ធិ

[80] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា២៤៩។

[81] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, លេខ នស/រកម/០៧១៦/០០៩, ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦, មាត្រា៤៥។

របស់ចៅក្រមស៊ើបសួរក្នុងការសម្រេចបន្តឃុំខ្លួនជា បណ្តោះអាសន្ន ដើម្បីរក្សាជននេះទុកជូនតុលាការជំនុំជម្រះ ឬ ធ្វើការដោះលែងឱ្យមានសេរីភាពជា បណ្តោះអាសន្ន។

ពាក់ព័ន្ធនឹងសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយនេះផងដែរ ឃើញថា ជនត្រូវចោទ នឹងត្រូវដោះលែងនៅក្រៅឃុំជាបណ្តោះអាសន្នដោយឯកឯង ប្រសិនបើ ជនត្រូវចោទមិនបានចូលបង្ហាញ ខ្លួននៅមុខតុលាការក្នុងរយៈពេល ០៤ (បួន) ខែ គិតពីកាលបរិច្ឆេទនៃការចេញដីកាបញ្ជូនទៅជំនុំជម្រះ យោងតាម វាក្យខណ្ឌទី២ នៃកថាខណ្ឌទី៣ នៃមាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ដោយឡែក ចំពោះការដោះលែងឱ្យមានសេរីភាព តាមអំណាចដីកាដំណោះស្រាយរបស់ចៅក្រម ស៊ើបសួរ ឃើញថា យោងតាមមាត្រា ២៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់អំពីការដោះលែងឱ្យ មានសេរីភាព ថានឹងមានអានុភាពជាក់លាក់ លុះត្រាតែផុតចិរវេលាប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា លើកលែងតែព្រះរាជអាជ្ញាយល់ព្រមឱ្យដោះលែងភ្លាមៗ។ ប្រសិនបើ ព្រះរាជអាជ្ញាប្តឹងឧទ្ធរណ៍ពីដីកា លើកលែងចោទប្រកាន់ ជនត្រូវចោទដែលជាប់ឃុំជាបណ្តោះអាសន្ន ត្រូវរក្សាទុកក្នុងពន្ធនាគារបន្តរហូត ដល់ពេលដែលសភាស៊ើបសួរសម្រេចអំពីបណ្តឹងឧទ្ធរណ៍នេះ។ ប្រសិនបើ សភាស៊ើបសួរយល់ស្របនឹង ដីកាលើកលែងចោទប្រកាន់នេះ គឺជនត្រូវចោទនឹងត្រូវដោះលែងឱ្យមានសេរីភាពភ្លាម តែផ្ទុយទៅវិញ ប្រសិនបើ សភាស៊ើបសួរសម្រេចចេញសាលដីកាដំណោះស្រាយបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ សភាស៊ើបសួរត្រូវសម្រេចអំពីការរក្សាជនត្រូវចោទឱ្យនៅក្នុងឃុំជាបណ្តោះអាសន្ន។

### ៣.២.ការបញ្ចប់អានុភាពនៃការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

កថាខណ្ឌទី ៤ នៃមាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ កំណត់អំពីអានុភាពនៃដីកាដំណោះស្រាយដែលបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ។ ក្នុងករណីដែលជនត្រូវចោទជាប់កាតព្វកិច្ចនៃការត្រួត ពិនិត្យតាមផ្លូវតុលាការ ដោយចៅក្រមស៊ើបសួរដាក់កំហិតឱ្យបង់ប្រាក់ធានា ឬ ឱ្យប្រគល់ឯកសារបញ្ជាក់ អត្តសញ្ញាណ ឬ ឱ្យប្រគល់អាវុធមិនទាក់ទិនបទល្មើស ហើយវត្ថុទាំងនេះត្រូវប្រគល់សងសាមីខ្លួនវិញ ដោយក្រឡាបញ្ជី ដោយមានបង្កាន់ដៃទទួលទុកជាសម្គាល់។ ប៉ុន្តែតាមរយៈសេចក្តីសម្រេចដោយឡែក នៃដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរអាចរក្សាទុកជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ រហូតដល់ពេលចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ ផ្អែកតាមកថាខណ្ឌទី ៥ និងកថាខណ្ឌ ទី៦ នៃមាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ចំពោះកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ អាចត្រូវរក្សាទុកតាមបែបបទតែមួយដូចនឹងការឃុំខ្លួនបណ្តោះអាសន្នរហូតដល់ពេលចូលបង្ហាញខ្លួននៅមុខតុលាការ។ ការត្រួតពិនិត្យតាមផ្លូវតុលាការត្រូវបញ្ចប់នៅពេលប្រកាសសាលក្រម។[82]

[82] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា៣៥២។

### ៣.៣. ការបញ្ចប់អានុភាពនៃមោឃភាព

ដីកាដំណោះស្រាយដែលចូលជាស្ថាពរ លុបលាងមោឃភាពនីតិវិធីមុន ប្រសិនបើមាន។ គ្មានមោឃភាពណាមួយនៃនីតិវិធីមុន អាចត្រូវបានលើកឡើងនៅចំពោះមុខតុលាការជំនុំជម្រះបានទៀតឡើយ។[83] ចំពោះចំណុចនេះផងដែរ គឺមានន័យថា រាល់ពាក្យសុំមោឃភាពនៃកិច្ចនីតិវិធីទាំងអស់ ត្រូវ ធ្វើឡើងមុនពេលដីកាដំណោះស្រាយចូលជាស្ថាពរ បើពុំដូច្នោះទេ ទោះបីជាកិច្ចនីតិវិធីដែលធ្វើឡើងកន្លង មកនេះ មានមូលហេតុនៃមោឃភាពក៏ដោយ ក៏មិនអាចធ្វើការប្ដឹងសុំបានដែរ ដោយសារអានុភាពស្ថាពរ នៃដីកាដំណោះស្រាយ។ បទប្បញ្ញត្តិនេះ មានគោលបំណងក្នុងការរារាំងគូភាគី មិនឱ្យធ្វើការបង្វិលត្រលប់ កិច្ចនីតិវិធីក្នុងការលើកឡើងអំពីភាពមិនប្រក្រតីនៃនីតិវិធីដែលបានធ្វើកន្លងមកទេ ព្រោះថានៅពេលដែល ភាពមិនប្រក្រតីនេះទើបតែលេចចេញមកភ្លាមៗ ហេតុអ្វីខ្លួនមិនធ្វើការលើកឡើង តែបែរជាលើកឡើងនា ពេលក្រោយទៅវិញ ដែលនេះគឺស្ដែងចេញនូវចេតនាទុច្ចរិតក្នុងការពន្យឺតការងាររបស់តុលាការក្នុងការចាត់ការរឿងក្ដីឱ្យបានទាន់ពេលវេលា និងឆាប់រហ័ស។

### ៣.៤. ការផ្លាស់ប្ដូរឋានៈរបស់ជនត្រូវចោទ

បន្ទាប់ពីដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរបានចូលជាស្ថាពររួចហើយ ចំពោះជនដែល ស្ថិតក្នុងដំណាក់កាលចៅក្រមស៊ើបសួរ ដែលត្រូវបានគេស្គាល់ថាជាជនត្រូវចោទនោះ ត្រូវបានផ្លាស់ប្ដូរ ឋានៈរបស់ខ្លួនភ្លាម ដោយប្រែក្លាយពីជនត្រូវចោទ មកជាជនជាប់ចោទ។ បើទោះបីជាជននេះប្រែឋានៈ ជាជនជាប់ចោទក៏ពិតមែន ប៉ុន្តែបើយោងតាមស្មារតីនៃលិខិតបទដ្ឋានគតិយុត្តអន្តរជាតិបានកំណត់ថា "ជនណាដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ត្រូវសន្មត់ជាជនគ្មានទោសរហូតដល់ពិរុទ្ធភាពត្រូវបាន រកឃើញ នៅក្នុងសវនាការជាសាធារណៈដែលមានការធានាចាំបាច់ដើម្បីឱ្យជននោះការពារខ្លួន។"[84]

[83] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា២៥៦។

[84] សេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្ស, មាត្រា១១។

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

ក្រោយពីឆ្លងកាត់ការបង្ហាញជូន និងបកស្រាយដូចខាងលើយើងខ្ញុំទាំងពីរនាក់បានធ្វើសិក្សាស្រាវជ្រាវយ៉ាងលម្អិតទៅលើប្រធានបទស្ដីពី "នីតិវិធីស៊ើបសួរនៅដំណាក់កាលសាលាដំបូង" អំពីចំណាត់ការរបស់ចៅក្រមស៊ើបសួរក្នុងបើកការស៊ើបសួរ និងចំណាត់ការរបស់ចៅក្រមស៊ើបសួរក្នុងការបិទការស៊ើបសួររួចមក យើងខ្ញុំទាំងពីរអាចទាញបានថា នៅតាមបណ្ដាលសាលាដំបូងរាជធានីខេត្តនីមួយៗដាច់ខាតនៅពេលដែលព្រះរាជអាជ្ញាបានចោទប្រកាន់លើជនល្មើសរួច ហើយចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅចៅក្រមស៊ើបសួរ នោះចៅក្រមស៊ើបសួរត្រូវបើកការស៊ើបសួរតាមសំណុំរឿងដែលព្រះរាជអាជ្ញាបានបញ្ជូនមក ហើយនៅពេលដែលចៅក្រមស៊ើបសួរបើកការស៊ើបសួរលើជនត្រូវចោទរួចហើយ ចៅក្រមស៊ើបសួរត្រូវបិទការស៊ើបសួររួចចេញដីកាបញ្ជូនជនត្រូវចោទទៅជំនុំជម្រះដោយចៅក្រមជំនុំជម្រះ។

នៅដំណាក់កាលចៅក្រមស៊ើបសួរ ត្រូវមានការបើកការស៊ើបសួរ ដើម្បីធានានូវសុក្រឹតភាពដែលស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តិថា ចៅក្រមស៊ើបសួរមិនអាចជាចៅក្រមជំនុំជម្រះបានទេ។ លើសពីនេះទៅទៀតការបើកការស៊ើបសួររបស់គាត់មិនត្រូវធ្វើឡើងតាមទំនើងចិត្តបានទេ គឺកើតឡើងដោយមានការទទួលពាក្យបណ្ដឹងជាមុនសិន ដោយមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ព្រមទាំងមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការដាក់បណ្ដឹងឱ្យមានចលនាផងដែរ។ បន្ទាប់ពីនីតិវិធីបើកការស៊ើបសួរហើយទាក់ទងនឹងវិធានការស្រាវជ្រាវ ដែលជាផ្នែកដ៏សំខាន់សម្រាប់ដំណើរការស៊ើបសួរនេះកាន់តែមានភាពយុត្តិធម៌ ប្រកបដោយ តម្លាភាព ក្នុងនោះត្រូវគោរពតាមវិធានការរួមមាន ត្រូវមានការជូនដំណឹងអំពីការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ ការសួរចម្លើយជនត្រូវចោទ ការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ការចុះទៅកន្លែងកើតហេតុការណ៍ ស្ដាប់ចម្លើយសាក្សី ការឆែកឆេរនិងការចាប់យកវត្ថុតាង ការធ្វើកោសលវិច័យ ការស្ដាប់ទូរស័ព្ទ និងការថតការសន្ទនាជាដើម។ ហើយរាល់នីតិវិធីនេះព្រះរាជអាជ្ញាដែលជាម្ចាស់បណ្ដឹងអាជ្ញាក៏អាចមានការចូលរួមបានដែរ។ ក្រៅពីវិធានការស្រាវជ្រាវចៅក្រមស៊ើបសួរក៏នៅមានអំណាចក្នុងដាក់ឱ្យជនត្រូវចោទនូវវិធាននិន្នាយមួយចំនួនដែលចៅក្រមស៊ើបសួរតែងតែប្រើប្រាស់ក្នុងការអនុវត្តបេសកកម្មរបស់ខ្លួនរួមមាន ដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យចាប់ខ្លួន និងដីកាបង្គាប់ឱ្យឃុំខ្លួន។

ដំណាក់កាលចុងក្រោយនៃការស៊ើបសួរបានបញ្ចប់សព្វគ្រប់ហើយ គឺត្រូវបិទការស៊ើបសួរតាមរយៈដីកាដំណោះស្រាយចំនួនពីរប្រភេទរួមមាន ដីកាបញ្ជូនទៅជំនុំជម្រះ និងដីកាលើកលែងការចោទប្រកាន់។ បន្ទាប់មកចៅក្រមស៊ើបសួរត្រូវរៀបចំរបាយការណ៍មួយហៅថា "របាយការណ៍ជូនរឿងទៅជំនុំជម្រះ" កាលបើក្នុងដីកានោះត្រូវបញ្ជូនទៅជំនុំជម្រះមិនថាតែមួយផ្នែក ឬទាំងអស់នោះទេ។ ចំពោះការលើកលែងការចោទប្រកាន់ក៏ដោយ

មិនថាមួយតែមួយផ្នែក ឬទាំងអស់ត្រូវមានសំអាងហេតុដែរ។ របាយការណ៍ព្រមទាំងសំណុំរឿងទាំងអស់ត្រូវដាក់ជូនទៅប្រធានតុលាការដើម្បីចាត់ការបន្តតាមនីតិវិធីច្បាប់។ ប្រសិនបើតុលាការយល់ឃើញថា សំណុំរឿងមូលសព្វគ្រប់ហើយប្រធាននោះនឹងចាត់តាំង ចៅក្រមម្នាក់ទទួលបន្ទុកធ្វើការជំនុំជម្រះលើរឿងក្តីនោះ។

សរុបជារួមមក ដើម្បីធានានូវភាពយុត្តិធម៌ នីតិវិធីស៊ើបសួរនៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានី/ខេត្ត ពិតជាមានតួនាទីយ៉ាងសំខាន់ណាស់ក្នុងរឿងក្តីព្រហ្មទណ្ឌនេះ ហើយក៏ជាការលើកស្ទួយប្រព័ន្ធតុលាការនៅកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាពដែលគួរជាទីទុកចិត្តរបស់ប្រជាពលរដ្ឋគ្រប់រូបផងដែរ។ ដូច្នេះហើយការគោរពសិទ្ធិមនុស្សនេះជាផ្នែកចម្បងមួយ ដែលពិភពលោកយើងបានកំពុងយកចិត្តទុកដាក់បំផុតទៅលើសិទ្ធិសេរីភាពរបស់បុគ្គលកាលណាមាន ភាពយុត្តិធម៌សម្រាប់បុគ្គលគ្រប់រូបនោះទើបច្បាប់យើងមានប្រសិទ្ធភាពទៅបាន។

# អនុសាសន៍

# អនុសាសន៍

ក្នុងពេលបច្ចុប្បន្នយើងសង្កេតឃើញថា វិស័យច្បាប់ និងប្រព័ន្ធយុត្តាធិការ នៃប្រទេសកម្ពុជាមានភាពល្អ ប្រសើរជាច្រើន ប៉ុន្តែក៏មានការសម្តែងមតិអវិជ្ជមានមួយចំនួនចំពោះការអនុវត្តនៅក្នុងប្រព័ន្ធយុត្តាធិការផងដែរ។ ទាំងនេះវាអាចកើតចេញមកពីកត្តា៣យ៉ាងគឺះ

១.កត្តាយឺតយ៉ាវ ចំណុចនេះសំដៅទៅដល់ភាពយឺតយ៉ាវនៃនីតិវិធី ចៅក្រមស៊ើបសួរគួរតែពន្លឿននីតិវិធីបានន័យថា ចៅក្រមស៊ើបសួរគួរតែផ្តល់អទិភាពទៅដល់សំណុំរឿងព្រហ្មទណ្ឌទាំងឡាយណាដែលជនត្រូវចោទស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន។

២.កត្តាចំណេះដឹង ប្រជាពលរដ្ឋមួយចំនួននៅមានកម្រិតយល់ដឹងអំពីផ្នែកច្បាប់ ដែលជាហេតុធ្វើឱ្យមានការភ័ន្តច្រលំទៅនឹងការអនុវត្តនីតិវិធីរបស់តុលាការ ហើយគិតថាតុលាការមានភាពលំអៀងដោយមានមូលហេតុណាមួយ ឬពុំបានដឹង ឮពាក់ព័ន្ធនឹងច្បាប់ជាធរមានណាមួយ ដែលជាហេតុធ្វើផ្ទុយនឹងច្បាប់។

៣.កត្តាផ្សព្វផ្សាយ ការផ្សព្វផ្សាយក៏ជាមូលហេតុសំខាន់មួយផងដែរ ព្រោះបុគ្គលដែលផ្សព្វផ្សាយនូវព័ត៌មានភាគច្រើនធ្វើការផ្សព្វផ្សាយមិនទាន់ដឹងច្បាស់អំពីមូលហេតុ ចំណងដើមហេតុច្បាស់លាស់អំពីករណីនិងនីតិវិធីទាំងនោះឡើយហើយធ្វើការផ្សព្វផ្សាយមានការយល់ច្រលំ។ ហេតុដូច្នេះដើម្បីបញ្ចៀសបាតុភាពអសកម្មនានាទាំងនេះ រាជរដ្ឋាភិបាលគួរតែចាត់វិធានការពង្រឹងវិស័យអប់រំបណ្តុះបណ្តាលមន្ត្រីផ្នែកប្រព័ន្ធយុត្តធិការឱ្យមានឯកទេស និងជំនាញរបស់ខ្លួនឱ្យបានច្បាស់លាស់ ក្នុងការផ្សព្វផ្សាយជាសារធារណៈតាមរយៈសោតទស្សន៍ តាមការបិទផ្សាយជាសាធារណៈ ឬគ្រប់មធ្យោបាយដើម្បីប្រជាពលរដ្ឋតាមជនបទបានដឹងឮចៀសវៀងការវិនិច្ឆ័យ និងការប្រព្រឹត្តដោយភាពអគតិនាំឱ្យមានភាពចលាចល គ្មានសណ្តាប់ធ្នាប់ អសន្តិសុខដល់ប្រទេសនីតិរដ្ឋ។

# ឯកសារយោង

# ឯកសារយោង

## ១. រដ្ឋធម្មនុញ្ញ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

## ២. សន្ធិសញ្ញា

- សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស ឆ្នាំ២០១០។

## ៣. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត

- ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩។
- ក្រមនីតិវិធីពញ្ញហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។
- ច្បាប់ស្ដីពីវិសោធនកម្ម ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០១៣។
- ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤។
- ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឆ្នាំ២០១៤។
- ច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤។
- ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦។

## ៤. សៀវភៅ និងឯកសារផ្សេងទៀត

- សៀវភៅសិក្សា នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធិ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០២២។
- សៀវភៅ ដំណើរការរឿងក្ដីព្រហ្មទណ្ឌ នៅកម្ពុជាបច្ចុប្បន្ន រៀបរៀងដោយ ឧត្ដមសេនីយ៍ត្រី អាន សុរីដា បោះពុម្ពផ្សាយឆ្នាំ២០២១។
- សៀវភៅព្រហ្មទណ្ឌថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ រៀបរៀងដោយសាស្ត្រចារ្យ ហ៊ី សោភា។
- បទបង្ហាញស្ដីពី លំហូរនីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយលោក សេង រិទ្ធី ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល ឆ្នាំ២០១៨។
- នីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ ឌី លីឡា និង ខាន់ សុខា។
- មេរៀន ចៅក្រមស៊ើបសួរ បង្រៀនដោយលោកសាស្ត្រាចារ្យ មីន សំអុល សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- សេចក្ដីពន្យល់ទូទៅអំពី សមត្ថកិច្ច និងសិទ្ធិរបស់ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជីក្នុងនីតិវិធីស៊ើបសួរ រៀបរៀងដោយ លោក សេង នាង ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ។

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

- ឧបសម្ព័ន្ធទី១ ៖ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ
- ឧបសម្ព័ន្ធទី២ ៖ នីតិវិធីនៃការបើកការស៊ើបសួរ
- ឧបសម្ព័ន្ធទី៣ ៖ វិធានការនិរន្តរាយ
- ឧបសម្ព័ន្ធទី៤ ៖ នីតិវិធីនៃការបិទការស៊ើបសួរ
- ឧបសម្ព័ន្ធទី៥ ៖ ដីកាបញ្ជូនព័ត៌មាន ឬលិខិតបញ្ជូនព័ត៌មានដល់តំណាងអយ្យការ ឬលិខិតជូនដំណឹងអំពីការស៊ើបសួរ
- ឧបសម្ព័ន្ធទី៦ ៖ លិខិតជូនដំណឹងអំពីការបិទស៊ើបសួរ ឬលិខិតជូនដំណឹង ឬជូនព័ត៌មាន
- ឧបសម្ព័ន្ធទី៧ ៖ ដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យ ឬដីកាបញ្ជូនសំណុំរឿង
- ឧបសម្ព័ន្ធទី៨ ៖ ដីកាសន្និដ្ឋានស្ថាពរ (បញ្ជូនទៅជម្រះ)
- ឧបសម្ព័ន្ធទី៩ ៖ ដីកាសន្និដ្ឋានស្ថាពរ (លើកលែងចោទប្រកាន់)
- ឧបសម្ព័ន្ធទី១០ ៖ ដីកាដោះស្រាយ ឬដីកាបញ្ជូនទៅជម្រះ
- ឧបសម្ព័ន្ធទី១១ ៖ ដីកាដំណោះស្រាយ ឬដីកាលើកលែងការចោទប្រកាន់
- ឧបសម្ព័ន្ធទី១២ ៖ លិខិតជូនដំណឹងអំពីដីកាដំណោះស្រាយ ឬលិខិតជូនដំណឹងអំពីដីការបញ្ជូនទៅជំនុំជម្រះ
- ឧបសម្ព័ន្ធទី១៣ ៖ លិខិតជូនដំណឹងអំពីដីកាដំណោះស្រាយ (លើកលែងចោទប្រកាន់)

# ឧបសម្ព័ន្ធទី១

# ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងរាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ:៧៣០

ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០២២

លេខ:......................អ.យ.ណ

## <u>ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ</u>

យើង ........................ ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញរបាយការណ៍សំយោគលេខ: **០១៩/២២** រ.ប.ក ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលខណ្ឌឫស្សីកែវ ផែនការងារនគរបាលព្រហ្មទណ្ឌ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ................. ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

### ក្រោយពីបានពិនិត្យឯកសារខាងលើ

ឃើញមានតម្រុយសន្និដ្ឋានថា៖

-គោត្តនាម និងនាមខ្លួន៖..............................ហៅ **វែង** ភេទប្រុស អាយុ ២៩ឆ្នាំ ជនជាតិខ្មែរ, មុខរបរ គ្មាន, ទីកន្លែងកំណើតនៅ ខេត្តសៀមរាប , ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅមិនពិតប្រាកដ, នៅលីវ, ឪពុកមិនស្គាល់ឈ្មោះ "រ.ស", ម្ដាយឈ្មោះ.................... "រ.ស", កំរិតវប្បធម៌ថ្នាក់ទី ៣ថ្មី។ (ឃាត់ខ្លួន)

**បានប្រព្រឹត្តអំពើដូចតទៅ**[1]៖ កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង២៣ និង៤៥នាទី ជនរងគ្រោះឈ្មោះ................ភេទប្រុស អាយុ ៤៤ឆ្នាំ បានសម្រាកនៅចំណុចការដ្ឋានសំណង់ ផ្លូវលំ ក្រុមទី០១ ភូមិបឹងសាឡាង សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ ដោយទុកទូរស័ព្ទមួយគ្រឿងម៉ាកវីវ៉ូ ពណ៌ខៀវ មានស៊ីមលេខ: ០៩៦៥៧៤២៦៤៦ នៅក្បាលដំណេក ហើយក៏មានជនសង្ស័យឈ្មោះ.........................ហៅ **វែង** ដើរមកដល់ឃើញមានឱកាសស្ងាត់ក៏ផ្លោះរបងចូលក្នុងការដ្ឋានសំណង់ ឃើញទូរស័ព្ទរបស់ជនរងគ្រោះទុកលើក្បាលដំណេក ក៏យកដៃកលួសស្មាខោអាវនៅក្បែរនោះការយកទូរស័ព្ទជនរងគ្រោះបានសម្រេច ហើយត្រូវជនរងគ្រោះភ្ញាក់ដឹងខ្លួនទាន់ស្រែកឆោឡោផ្អើលដល់កម្មករនាំគ្នាជួយចាប់ជនសង្ស័យ ប្រគល់ឲ្យប៉ុស្តិ៍នគរបាល រដ្ឋបាលឫស្សីកែវតែម្តង។

-អំពើប្រព្រឹត្តខាងលើជាបទល្មើស៖ **លួច (ទូរស័ព្ទ)** ប្រព្រឹត្តនៅចំណុចការដ្ឋានសំណង់ ផ្លូវលំ ក្រុមទី០១ ភូមិបឹងសាឡាង សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា **៣៥៣** មាត្រា **៣៥៦** នៃក្រមព្រហ្មទណ្ឌ ។

-បានឃើញ: មាត្រា **៤៤** និងមាត្រា **១២៤** នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

### ហេតុដូច្នេះ

បើកការស៊ើបសួរលើអង្គហេតុខាងលើ និង ៖

☐ ដាក់ឱ្យស្ថិតក្រោមការពិនិត្យ[2] ៖

-ឈ្មោះ..............................ហៅ **វែង** ភេទប្រុស អាយុ ២៩ឆ្នាំ ។ (ឃាត់ខ្លួន)

---

[1] សេចក្ដីសង្ខេបអង្គហេតុ

[2] ឈ្មោះជនត្រូវចោទ

ពីបទ៖ **លួច (ខុសើរួ)** ប្រព្រឹត្តនៅចំណុចការដ្ឋានសំណង់ ផ្លូវលំ ក្រុមទី០១ ភូមិបឹងសាឡាង សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា **៣៥៣** មាត្រា **៣៥៦** នៃក្រមព្រហ្មទណ្ឌ ។

ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[3] ៖.........................................................

☐ ដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្នលើជនសង្ស័យខាងលើ[4] ៖

ថ្ងៃអាទិត្យ ១២កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២២

**តំណាងអយ្យការ**

[3]កាតព្វកិច្ចណាមួយដែលបាននៅក្នុងមាត្រា ២២៣

[4]មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នដែលមានចែងនៅក្នុងមាត្រា២០៥

# ឧបសម្ព័ន្ធទី២

# នីតិវិធីនៃការបើកការស៊ើបសួរ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

ណ៉ុំរឿងព្រហ្មទណ្ឌលេខ ៖............អក
ថ្ងៃទី............ខែ..............ឆ្នាំ២០......
ណ៉ុំរឿងស៊ើបសួរលេខ ៖..............សស
ថ្ងៃទី............ខែ..............ឆ្នាំ២០.....

# កំណត់ហេតុស្តីពី
# ការសួរចម្លើយតទល់

(មាត្រា ១៥៥ និងមាត្រាបន្តបន្ទាប់ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់................ខែ......................ថ្ងៃទី......................វេលាម៉ោង........................។

យើង **ហុក វ៉ាន់ធីណា** ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្តាល

អមដោយលោក..................................ជាក្រឡាបញ្ជី ។

បានមកបង្ហាញខ្លួនក្នុងនាមជាជនត្រូវចោទ នៅក្នុងមន្ទីរស៊ើបសួរចំពោះមុខយើង ជនដែលមានអត្តសញ្ញាណ ដូចខាងក្រោម ៖

នាមត្រកូល ៖................................នាមខ្លួន ៖...............................ភេទ.............ថ្ងៃ ខែ ឆ្នាំកំណើត.........................................ជាតិ........................................មុខរបរ............................................

ទីកន្លែងកំណើត ៖ នៅភូមិ...................................ឃុំ...............................ស្រុក...............................

ខេត្ត.............................. ទីលំនៅបច្ចុប្បន្ននៅភូមិ..................................ឃុំ..................................

ស្រុក..........................................ខេត្ត................................... ។

☐ នៅលីវ ☐ រៀបការរួច ប្រពន្ធ ឬ ប្តីឈ្មោះ...............................(ស/ស) មានកូន.............នាក់ ។

ឪពុកឈ្មោះ..............................................(ស/ស) ម្តាយឈ្មោះ............................................(ស/ស)

☐ អនីតិជន ☐ នីតិជន ប្រវត្តិផ្តន្ទាទោសដោយតុលាការ........................................................................។

☐ ជននេះបានប្រកាសប្រាប់ថា ខ្លួនមានអំណាចមេបាលើក្មេងអាយុក្រោម ១០ (ដប់) ឆ្នាំដែលស្ថិតនៅលំនៅបច្ចុប្បន្ន ។

ជននេះ ៖ ☐ ចេះនិយាយភាសាខ្មែរ ☐ ចេះអានអក្សរខ្មែរ ☐ ចេះសរសេរអក្សរខ្មែរ

ជននេះ ៖ ☐ មិនចេះនិយាយភាសាខ្មែរ ☐ មិនចេះអានអក្សរខ្មែរ ☐ មិនចេះសរសេរអក្សរខ្មែរ

បានមកបង្ហាញខ្លួនក្នុងនាមជា.....................................នៅក្នុងមន្ទីរស៊ើបសួរចំពោះមុខយើង ជនដែលមានអត្ត សញ្ញាណដូចខាងក្រោម ៖

ឈ្មោះ...................................ភេទ..............ជាតិ.................កើតថ្ងៃទី.............................

នៅភូមិ.......................................ឃុំ..................................ស្រុក...........................ខេត្ត.................។

ទីលំនៅបច្ចុប្បន្នភូមិ.....................................ឃុំ...................................ស្រុក.......................................

ខេត្ត................................ មុខរបរ.....................................................................................................។

□នៅលីវ□រៀបការរួច ប្រពន្ធ ឬ ប្តីឈ្មោះ.................................(ប/ស) មានកូន.................នាក់ ។

ឪពុកឈ្មោះ............................................(ប/ស)ម្តាយឈ្មោះ............................................(ប/ស)

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ.........................................................................................។

ជននេះ ៖ □ ចេះនិយាយភាសាខ្មែរ □ ចេះអានអក្សរខ្មែរ □ ចេះសរសេរអក្សរខ្មែរ

ជននេះ ៖ □ មិនចេះនិយាយភាសាខ្មែរ □ មិនចេះអានអក្សរខ្មែរ □ មិនចេះសរសេរអក្សរខ្មែរ

□ជននេះបានប្រកាសប្រាប់ថា ខ្លួនមានអំណាចមេបាលើក្មេងអាយុក្រោម ១០ (ដប់)ឆ្នាំ ដែលស្ថិតនៅលំនៅបច្ចុប្បន្ន ។

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជននេះ យើងបានប្រាប់ដល់ជននេះ ឱ្យដឹងយ៉ាងច្បាស់អំពីរឿងក្តី ដែលតំណាងអយ្យការបានប្តឹង តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ លេខ ៖.................ដកសស ចុះថ្ងៃទី............ខែ..............ឆ្នាំ២០.........ដែលជាហេតុ នាំឱ្យជននេះត្រូវដាក់ស្ថិតនៅក្រោមការពិនិត្យ □ ការឃុំខ្លួនបណ្តោះអាសន្ន តាមដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នលេខ ៖......................ដកសឃខ ចុះថ្ងៃទី...........ខែ................ ឆ្នាំ២០........។

ជនត្រូវចោទឈ្មោះ.................................អមដោយលោក..........................ជាមេធាវី ។

ជនត្រូវចោទឈ្មោះ................................អមដោយលោក..........................ជាមេធាវី ។

យើងបានសួរចម្លើយតទល់ដូចខាងក្រោម ៖

សួរ-ឆ្លើយ ៖.................................................................................................................

...................................................................................................................................

...................................................................................................................................

...................................................................................................................................

...................................................................................................................................

...................................................................................................................................

...................................................................................................................................

...................................................................................................................................

...................................................................................................................................

...................................................................................................................................

...................................................................................................................................

...................................................................................................................................

...................................................................................................................................

...................................................................................................................................

...................................................................................................................................

...................................................................................................................................

...................................................................................................................................

...................................................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

☐ យើងបានឱ្យជនត្រូវចោទ អានឡើងវិញនូវចម្លើយទាំងអស់របស់ខ្លួន ដែលយើងបានកត់ត្រាចូលក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ឱ្យចុះហត្ថលេខា ឬ ឱ្យផ្ដិតមេដៃលើកំណត់ហេតុនេះ ។

☐ បានអានចប់សព្វគ្រប់ ហើយជនត្រូវចោទ មិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខា ឬ ផ្ដិតមេដៃជាមួយយើង និងក្រឡាបញ្ជី ។

☐ បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនត្រូវចោទ មិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខា ឬ ផ្ដិតមេដៃជាមួយយើង ក្រឡាបញ្ជី និងអ្នកបកប្រែ ។

**ជនត្រូវចោទ** **មេធាវី** **ក្រឡាបញ្ជី** **ចៅក្រមស៊ើបសួរ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងព្រហ្មទណ្ឌលេខ ៖...........អក
ចុះថ្ងៃទី...........ខែ..............ឆ្នាំ២០......
សំណុំរឿងស៊ើបសួរលេខ ៖...........សស
ចុះថ្ងៃទី...........ខែ..............ឆ្នាំ២០......

## កំណត់ហេតុស្ដីពីការស្ដាប់ចម្លើយ
## សាក្សី

(មាត្រា ១៥៣ និងមាត្រាបន្តបន្ទាប់ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់.................ខែ................ថ្ងៃទី......................វេលាម៉ោង..............................។

**យើង ហុក វ៉ាន់ធីណា** ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្ដាល

អមដោយលោក...............................................ជាក្រឡាបញ្ជី ។

បានមកបង្ហាញខ្លួនក្នុងនាមជាសាក្សី នៅក្នុងមន្ទីរស៊ើបសួរចំពោះមុខយើង ជនដែលមានអត្តសញ្ញាណដូចខាងក្រោម ៖

ឈ្មោះ...................................ភេទ..............ជាតិ.................កើតថ្ងៃទី.........................
នៅភូមិ......................................ឃុំ..................................ស្រុក............................ខេត្ត..................។
ទីលំនៅបច្ចុប្បន្នភូមិ...................................ឃុំ................................ស្រុក.......................................
ខេត្ត................................ មុខរបរ...............................................................................................។
☐នៅលីវ☐រៀបការរួច ប្រពន្ធ ឬ ប្ដីឈ្មោះ..................................(ស/ស) មានកូន..................នាក់ ។
ឪពុកឈ្មោះ..............................................(ស/ស)ម្ដាយឈ្មោះ..............................................(ស/ស)
ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ.............................................................................................។

តើអ្នកឯងចេះអាន និងសរសេរភាសាខ្មែរដែរ ឬទេ?

☐ចេះអាន និងចេះសរសេរភាសាខ្មែរ ☐មិនចេះអាន និងមិនចេះសរសេរភាសាខ្មែរ

☐ជននេះបានប្រកាសប្រាប់ថា ខ្លួនមានអំណាចមេបាលើក្មេងអាយុក្រោម ១០ (ដប់)ឆ្នាំ ដែលស្ថិតនៅលំនៅបច្ចុប្បន្ន ។

លោក...................................................ជាមេធាវី ។

....................................................................................................... ។

☐ ចោទប្រកាន់បន្ថែម តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមដែលមានភ្ជាប់ជូនមកជាមួយ ។

☐ បន្តការស៊ើបសួរ ។

ថ្ងៃ.......................... ខែ........ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ខេត្តកណ្តាល,ថ្ងៃទី ...21...... ខែ.....12..... ឆ្នាំ២០២០

**តំណាងអយ្យការ**

# ឧបសម្ព័ន្ធទី៨

# ដីកាសន្និដ្ឋានស្ថាពរ ( បញ្ជូនទៅជម្រះ )

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្តកណ្ដាល

# ដីកាសន្និដ្ឋានស្ថាពរ

សំណុំរឿងព្រហ្មទណ្ឌលេខ ១៥០៤ អ.ក
ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០
លេខ: 1542 ដកសព/២០

**យើង** **តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល**

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១០៨៨ ដកសស/២០ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០

-បានឃើញសំណុំរឿងស៊ើបសួរលេខ ៧៥៤ សស ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល

-បានឃើញដីកាបញ្ជូនឱ្យឆ្លើយដើម្បីបញ្ចប់ការស៊ើបសួរលេខ ២០៨៣ ពសសប/២០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល

-បានឃើញដីកាបញ្ជូនរឿងទៅពិនិត្យលេខ ២០៤១ ពសប/២០ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

**ឃើញថា៖**

| | |
|---|---|
| ១.នាមត្រកូល | ៖ នាមខ្លួន ៖ ឈ្មោះហៅក្រៅ ភេទ ៖ ប្រុស |
| អាយុ | ៖ ឆ្នាំ |
| ទីកន្លែងកំណើត | ៖ ភូមិកំពង់ក្ដី ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ |
| ទីលំនៅបច្ចុប្បន្ន | ៖ (ផ្ទះជួល)ភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្ដាល |
| មុខរបរ | ៖ មិនពិតប្រាកដម |
| ស្ថានភាពគ្រួសារ | ៖ នៅលីវ |
| សញ្ជាតិ | ៖ ខ្មែរ |
| ឪពុកឈ្មោះ | ៖ "រស់" ម្ដាយឈ្មោះ ៖ "រស់" |
| កម្រិតវប្បធម៌ | ៖ ថ្នាក់ទី៩ ជា អនីតិជន |
| ទោសពីមុន | ៖ គ្មាន |

ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ "អំពើលួច" ប្រព្រឹត្តនៅភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។



អាស័យដ្ឋាន៖ ផ្លូវជាតិលេខ២ ភូមិតាខ្មៅ២ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល
Address: National Road2, Phum Takhmao2, Sangkat Takhmao, Takhmao City, Kandal Province

ឃើញថា[1]៖ កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ ម៉ោង១៤ និង៣០នាទី ស្ថិតនៅភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល ជនសង្ស័យឈ្មោះ ហៅក្រៅ ភេទប្រុស អាយុ ឆ្នាំ ជាតិខ្មែរ បានធ្វើសកម្មភាពលួចម៉ូតូ០១គ្រឿងម៉ាក HONDA DREAM ស៊េរី២០២០ ពាក់ស្លាកលេខ កណ្តាល 1AG-3612 របស់ជនរងគ្រោះឈ្មោះ ហៅក្រៅ ភេទប្រុស អាយុ ឆ្នាំ ជាតិខ្មែរ ដែលចត់ទុកនៅមុខផ្ទះជួល ហើយភ្លាមនោះជនសង្ស័យជិះគេចខ្លួនទៅដល់ឃុំកំពង់សឹង ស្រុកព្រះស្តេច ខេត្តព្រៃវែង តែដោយសារម៉ូតូជាប់ជីភីអេស ក៏ត្រូវសមត្ថកិច្ចស្រាវជ្រាវរកឃើញ និងឃាត់ខ្លួនជនសង្ស័យឈ្មោះ ហៅក្រៅ និងដកហូតកស្តុតាងម៉ូតូខាងលើតែម្តង ។

ឃើញថា:

<u>នៅដំណាក់កាលស៊ើបអង្កេតរបស់អធិការដ្ឋាននគរបាលស្រុកពញាឮ</u>

-យោងតាមពាក្យបណ្តឹងរបស់ឈ្មោះ អធិការដ្ឋាននគរបាលក្រុងតាខ្មៅ បានចាប់ផ្តើមធ្វើការស៊ើបអង្កេត ដោយបានចុះទៅពិនិត្យ និងវិភាគកន្លែងកើតហេតុក៏ដូចជាធ្វើកំណត់ហេតុសួរ និងស្តាប់ចម្លើយនូវ៖

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ បានឆ្លើយថា៖ កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ ម៉ោង ១៤ និង៣០នាទី ខ្លួនបានបណ្តើរម៉ូតូចេញពីបន្ទប់ជួលយកមកទុកនៅមុខបន្ទប់ ដោយពុំបានដកសោរម៉ូតូទេ រួចខ្លួនក៏ដើរចូលទៅបន្ទប់វិញដើម្បីយកសំបកកង់ម៉ូតូចាស់របស់ខ្ញុំទៅលក់ ពេលខ្លួនចេញពីបន្ទប់វិញ ស្រាប់តែមានបុរសម្នាក់ឈ្មោះ អាយុ ឆ្នាំ ដែលវាស្នាក់នៅផ្ទះជួលជាន់ខាងលើ វាបានជិះម៉ូតូរបស់ខ្ញុំចេញយ៉ាងលឿន ឃើញដូចនេះខ្លួនរត់ដេញតាម និងបានឱ្យពូម៉ូតូឌុបជួយដេញតាម ប៉ុន្តែគាត់មិនដេញតាមទេគាត់ខ្លាចគ្រោះថ្នាក់ បន្ទាប់មកខ្ញុំបានទៅប្រាប់ម្តាយ ហើយម្តាយខ្លួនបានទូរស័ព្ទទៅប្រាប់ក្រុមហ៊ុនបង់រំលោះអេជីអឹមឱ្យបានដឹង បន្តិចក្រោយមកខាងក្រុមហ៊ុនអេជីអឹមបានមកសហការជាមួយសមត្ថកិច្ចកំពង់សំណាញ់ដើម្បីស្វែងរក ដោយម៉ូតូរបស់ខ្លួនបានភ្ជាប់ប្រព័ន្ធ GPS ហើយខ្លួន និងម្តាយបានមកប៉ុស្តិ៍នគរបាលកំពង់សំណាញ់មកដាក់ពាក្យបណ្តឹង បញ្ជាក់ម៉ូតូរបស់ខ្លួនម៉ាក HONDA DREAM ស៊េរី២០២០ ពណ៌ខ្មៅ ពាក់ស្លាកលេខ 1AG-3612 ។

-ជនសង្ស័យឈ្មោះ ហៅក្រៅ បានឆ្លើយថា៖ ខ្លួនបានចូលលួចម៉ូតូរបស់គេនៅមុំផ្ទះជួល ខ្លួនធ្វើសកម្មភាពលួចម៉ូតូតែម្នាក់ឯងគត់ ខ្លួនទើបតែធ្វើសកម្មភាពលួចម៉ូតូជាលើកទី១នេះទេ ។ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ ម៉ោង១២ និង០០នាទី ខ្លួន និងឈ្មោះ បាននាំគ្នាយកប្រាក់ទៅកន្លែងណែតដោយខ្លួនអ្នកបើកម៉ូតូ មួយសន្ទុះក្រោយពួកខ្លួនក៏ត្រឡប់មកផ្ទះជួលនៅភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល បន្ទាប់មកម្ចាស់ម៉ូតូឈ្មោះ បានដើរចូលបន្ទប់ជួលរបស់ខ្លួន ភ្លាមនោះខ្ញុំបាទឃើញមានឱកាសល្អក៏បានលួចយកម៉ូតូម៉ាក HONDA DREAM ពណ៌ខ្មៅ ស៊េរី២០២០ ពាក់ស្លាកលេខ កណ្តាល 1AG-3612 របស់ឈ្មោះ ជិះម៉ូតូគេចទៅខេត្តព្រៃវែង ដល់ឃុំកំពង់សឹង ខ្ញុំបាទបើកម៉ូតូចូលទៅកន្លែងជួសជុលម៉ូតូខ្ញីទុយឡាស៊ែរដោះផ្តាច់ប្រព័ន្ធGPS កុំឱ្យម្ចាស់ម៉ូតូ ឬសមត្ថកិច្ចរកឃើញ តែក្រោយមកក៏ត្រូវបានកម្លាំងសមត្ថកិច្ចប៉ុស្តិ៍នគរបាលកំពង់សំណាញ់ តាមទាន់នៅចំណុចឃុំកំពង់សឹង ឃាត់ខ្លួនខ្ញុំបាទបញ្ជូនមកអធិការដ្ឋាននគរបាលក្រុងតាខ្មៅតែម្តង។

-តាមសៀវភៅរូបថត ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០ របស់អធិការនគរបាលក្រុងតាខ្មៅ ។

---

[1] រៀបរាប់សង្ខេបអង្គហេតុ និងរាល់ចំណាត់ការនៃនីតិវិធីតាមលំដាប់ ( ឧទាហរណ៍ អង្គហេតុដែលបានកើតឡើង ចំណាត់ការរបស់មន្ត្រីនគរបាលយុត្តិធម៌ អយ្យការ ចៅក្រមស៊ើបសួរ)

**<u>នៅដំណាក់កាលស៊ើបអង្កេតរបស់តំណាងអយ្យការ</u>**

ក្រោយពីបានទទួលសំណុំរឿង និងពិនិត្យរបាយការណ៍សរុបលេខ ៣៣៣ របក ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០ របស់អធិការដ្ឋាននគរបាលក្រុងតាខ្មៅរួចមក តំណាងអយ្យការបានធ្វើកំណត់ហេតុសួរយកចម្លើយ៖

-ជនសង្ស័យឈ្មោះ បានឆ្លើយថា៖ ខ្ញុំបាទទទួលស្គាល់ចម្លើយរបស់ខ្ញុំបាទ ដែលបានឆ្លើយនៅមន្ត្រីនគរបាលយុត្តិធម៌ទាំងអស់ ដោយពុំមានកែប្រែត្រង់ចំណុចណាមួយឡើយ។ សមត្ថកិច្ចនគរបាលឃាត់ខ្លួនខ្ញុំបាទ ដោយសារខ្ញុំបាទលួចម៉ូតូមិត្តភក្តិឈ្មោះ ភេទប្រុស អាយុប្រហែល ឆ្នាំ។ ម៉ូតូដែលខ្ញុំលួចនោះ ម៉ាក ហុងដាឌ្រីម ស៊េរី២០២០ ពាក់ស្លាកលេខ កណ្តាល 1AG-3612 លួចនៅម្តុំផ្ទះជួលទល់មុខផ្ទះសំណាក់មហាលាភ ស្ថិតនៅភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល។ ពេលលួចម៉ូតូបានហើយ ខ្ញុំជិះម៉ូតូនោះទៅព្រៃវែង ដល់កន្លែងជាងម៉ូតូម្តុំផ្សារកំពង់សឹង ស្រាប់តែមានសមត្ថកិច្ចចុះមកឃាត់ខ្លួនខ្ញុំបាទតែម្តង។ ខ្ញុំបាទធ្វើសកម្មភាពលួចម៉ូតូនេះតែម្នាក់ឯងប៉ុណ្ណោះ មិនមានបក្សពួកទេ។ នៅថ្ងៃកើតហេតុទី០១ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង០១ និង៣០នាទី ពេលខ្ញុំជិះម៉ូតូរបស់មិត្តភក្តិឈ្មោះ ឌុបមិត្តភក្តិខ្ញុំឈ្មោះ ទៅផ្ទះជួលទល់មុខផ្ទះសំណាក់មហាលាភ ហើយនៅពេលឈ្មោះ យកកង់ម៉ូតូទៅលក់ឱ្យគេនៅម្តុំនោះ ឆ្លៀតពេលនោះខ្ញុំបាទក៏បានលួចម៉ូតូមិត្តភក្តិរបស់ខ្ញុំបាទតែម្តងទៅ។ ខ្ញុំបាទសំណូមពរមកដល់តុលាការមេត្តាបន្ធូរបន្ថយទោសមកដល់ខ្ញុំបាទផង ។

បន្ទាប់មកតំណាងអយ្យការបានធ្វើការចោទប្រកាន់លើឈ្មោះ ហៅក្រៅ ភេទប្រុស អាយុ ឆ្នាំ ជាតិខ្មែរ ពីបទ "អំពើលួច" ប្រព្រឹត្តនៅភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៩ តាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១០៨៨ ដកសស/២០ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០ ។

**<u>នៅដំណាក់កាលស៊ើបសួររបស់ចៅក្រមស៊ើបសួរ</u>**

តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់តំណាងអយ្យការ ចៅក្រមស៊ើបសួរបានផ្តើមធ្វើការស៊ើបសួរ ដោយដាក់ជនត្រូវចោទឈ្មោះ ហៅក្រៅ ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ "អំពើលួច" ប្រព្រឹត្តនៅភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ និងបានធ្វើកំណត់ហេតុសួរយកចម្លើយនូវឈ្មោះ ៖

-ជនត្រូវចោទឈ្មោះ ហៅក្រៅ បានឆ្លើយថា៖ ខ្ញុំបាទទទួលស្គាល់ចម្លើយដែលខ្ញុំបានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងដំណាក់កាលអយ្យការ ។ នៅថ្ងៃកើតហេតុទី០១ ខែកញ្ញា ឆ្នាំ២០២០ ម៉ោង១ថ្ងៃ ខ្ញុំបានជិះម៉ូតូជាមួយមិត្តភក្រ្តឈ្មោះ ទៅមុខផ្ទះសំណាក់មហាលាភ នៅភូមិកំពង់សំណាញ់ ឈ្មោះ បានចុះពីលើម៉ូតូចូលទៅផ្ទះយកសំបកកង់ម៉ូតូលក់ មានឱកាសខ្ញុំក៏បានជិះម៉ូតូរត់គេចទៅខេត្តព្រៃវែង ខ្ញុំកំពុងតែដោះGPSចេញ ខ្ញុំក៏ត្រូវសមត្ថកិច្ចខេត្តព្រៃវែងឃាត់ខ្លួនតែម្តងទៅ។ ខ្ញុំគ្មានសម្ភារៈអ្វីទេ មានតែម៉ូតូ០១គ្រឿងរបស់ឈ្មោះ ហើយម៉ូតូនោះម្ចាស់គេយកទៅវិញហើយ ខ្ញុំបាទសុំតុលាការមេត្តាបន្ធូរបន្ថយទោស។

បន្ទាប់មកចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល បានចេញដីកាសម្រេចឃុំខ្លួនជនត្រូវចោទឈ្មោះ ហៅក្រៅ តាមរយៈដីកាលេខ ៣៥៥៥ ដស.ឃ.ខប /២០ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ ២០២០ និងបង្គាប់ឱ្យឃុំខ្លួនតាមរយៈដីកាលេខ ៣៥៥៦ ដក.ប.ឃខ /២០ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ ២០២០ ។

## **យល់ឃើញថា**[2]

-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ចម្លើយរបស់ជនត្រូវចោទឈ្មោះ ហៅក្រៅ តាមសៀវភៅរូបថត ព្រមទាំងរបាយការណ៍សុបលេខ ៣៣៣ របក ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០ របស់អធិការដ្ឋាននគរបាលក្រុងតាខ្មៅ អាចបញ្ជាក់បានថាពិតមានអង្គហេតុនៃបទល្មើស "**អំពើលួច**" ប្រព្រឹត្តនៅភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ ២០២០ តាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ប្រាកដមែន។

-តាមចម្លើយបំភ្លឺរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ និងចម្លើយសារភាពរបស់ជនត្រូវចោទ ឈ្មោះ ហៅក្រៅ គឺមានភាពស៊ីសង្វាក់គ្នាដែលបញ្ជាក់បានថាជនត្រូវចោទឈ្មោះ ហៅក្រៅ ពិតជាបានធ្វើសកម្មភាពលួចម៉ូតូ០១គ្រឿងម៉ាក HONDA DREAM ពណ៌ខ្មៅ ស៊េរី២០២០ ពាក់ស្លាកលេខ កណ្តាល 1AG-3612 របស់ឈ្មោះ ប្រាកដមែន ដែលអំពើនេះច្បាប់ចាត់ទុកជាបទល្មើស "**អំពើលួច**" ។

-ឆ្លងតាមការស៊ើបអង្កេត និងការស៊ើបសួរកន្លងមក តំណាងអយ្យការជឿជាក់ថា ជនត្រូវចោទឈ្មោះ ហៅក្រៅ ពិតជាបានប្រព្រឹត្តអំពើល្មើសដូចការចោទប្រកាន់។

-អំពើរបស់ជនត្រូវចោទឈ្មោះ ហៅក្រៅ បានប្រព្រឹត្តជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិរបស់អ្នកដទៃ ក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។

-អំពើប្រព្រឹត្តរបស់ជនត្រូវចោទឈ្មោះ ហៅក្រៅ ខាងលើ បានធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយក្នុងសង្គម ដែលច្បាប់បញ្ញត្តិជាបទល្មើស "**អំពើលួច**" និងត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

-ជនត្រូវចោទឈ្មោះ ហៅក្រៅ ជាអនីតិជន អាយុ ឆ្នាំ មានស្មារតីយល់ដឹងអាចនឹងទទួលខុសត្រូវចំពោះមុខច្បាប់បាន ។

-មានភស្តុតាងដាក់បន្ទុកលើឈ្មោះ ហៅក្រៅ ភេទប្រុស អាយុ ឆ្នាំ ជាតិខ្មែរ ពីបទ "**អំពើលួច**" ប្រព្រឹត្តនៅភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

## <u>**ហេតុដូច្នេះ**</u>

**ប្តឹងសុំឱ្យចៅក្រមស៊ើបសួរ សម្រេច ÷**

☐ **បញ្ជូនជនត្រូវចោទ** ឈ្មោះ ហៅក្រៅ ភេទប្រុស អាយុ ឆ្នាំ ជាតិខ្មែរ (ក្នុងឃុំ) ពីបទ "**អំពើលួច**" ប្រព្រឹត្តនៅភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ **ទៅជំនុំជម្រះ** ។

ថ្ងៃ...ពុធ ១១ រោច........ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

កណ្តាល ថ្ងៃទី...២៨...ខែតុលា ឆ្នាំ២០២០

**តំណាងអយ្យការ**

[2] សំអាងហេតុ សំអាងច្បាប់

# ឧបសម្ព័ន្ធទី៩

# ដីកាសន្និដ្ឋានស្ថាពរ ( លើកលែងចោទប្រកាន់ )

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអមសាលាដំបូងខេត្តកណ្ដាល

## ដីកាសន្និដ្ឋានស្ថាពរ

លេខ: 1785....ដក.សព.២០

**យើង** **តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល**

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ០៩៣ អ.ក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥
-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ: ០៦០ ដកសស.១៥ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥
-បានឃើញ សំណុំរឿងស៊ើបសួរលេខ: ០៣៣ សស ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តកណ្ដាល
-បានឃើញ ដីកាបញ្ជូនពត៌មានបញ្ចប់ការស៊ើបសួរលេខ: ២១៨៧ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២០
-បានឃើញ ដីកាបញ្ជូនសំណុំរឿងឲ្យពិនិត្យលេខ: ២២១៨ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២០

**ក្រោយពិនិត្យឯកសារខាងលើ**

ឃើញថា:

១-នាម-គោត្តនាម: ភេទប្រុស អាយុ ២៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកម្មករឡូតិ៍ង្វ មានទីកន្លែងកំណើតនៅភូមិជងគោម ឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្ដាល និងទីលំនៅបច្ចុប្បន្ននៅភូមិទេពមន្ត្រី ឃុំព្រះប្រសប់ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ឪពុកឈ្មោះ (រស់) ម្ដាយឈ្មោះ (រស់) ប្រពន្ធឈ្មោះ មានកូនចំនួន ០១នាក់ ជានីតិជន ។ (ក្រៅឃុំ)

២-នាម-គោត្តនាម: ភេទប្រុស អាយុ ២០ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកម្មករឡូតិ៍ង្វ មានទីកន្លែងកំណើតនៅភូមិក្រាំងចិន ឃុំក្រាំងចិន ស្រុកពាមជរ ខេត្តព្រៃវែង និងទីលំនៅបច្ចុប្បន្ននៅភូមិទេពមន្ត្រី ឃុំព្រះប្រសប់ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ឪពុកឈ្មោះ (ស្លាប់) ម្ដាយឈ្មោះ (រស់) ប្រពន្ធឈ្មោះ មានកូនចំនួន ០១នាក់ ជានីតិជន ។ (ក្រៅឃុំ)

៣-នាម-គោត្តនាម: ភេទប្រុស អាយុ ៥០ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកម្មករឡូតិ៍ង្វ មានទីកន្លែងកំណើតនៅភូមិតាំងគោក ឃុំតាំងក្រាំង ស្រុកបាធាយ ខេត្តកំពង់ចាម និងទីលំនៅបច្ចុប្បន្ននៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្ដាល ឪពុកឈ្មោះ , ម្ដាយឈ្មោះ , ប្រពន្ធឈ្មោះ មានកូនចំនួន ០៦នាក់ ជានីតិជន ។ (ក្រៅឃុំ)

៤-នាម-គោត្តនាម: ភេទប្រុស អាយុ ១៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកម្មករឡូតិ៍ង្វ មានទីកន្លែងកំណើតនៅភូមិជងគោម ឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្ដាល និងទីលំនៅបច្ចុប្បន្ននៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្ដាល ឪពុកឈ្មោះ (រស់) ម្ដាយឈ្មោះ នៅលីវ ជាអនីតិជន ។ (ក្រៅឃុំ)



អាស័យដ្ឋាន: ផ្លូវជាតិលេខ២ ភូមិតាខ្មៅ២ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល
Address: National Road2, Phum Takhmao2, Sangkat Takhmao, Takhmao City, Kandal Province

៥-នាម-គោត្តនាមៈ ភេទប្រុស អាយុ ៣៦ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកម្មករឡុតដ្ឋ មានទីកន្លែងកំណើតនៅភូមិព្រៃអង្គក្នុង ឃុំវើល ស្រុកពញាក្រែក ខេត្តកំពង់ចាម និងទីលំនៅបច្ចុប្បន្ន នៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ឪពុកឈ្មោះ (ស្លាប់) , ម្តាយឈ្មោះ (រស់) , ប្រពន្ធឈ្មោះ មានកូនចំនួន ០៣នាក់ ជានីតិជន ។ (ក្រៅឃុំ)

៦-នាម-គោត្តនាមៈ ភេទប្រុស អាយុ ៣៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកម្មករឡុតដ្ឋ ជានីតិជន ។ (ក្រៅឃុំ)

៧-នាម-គោត្តនាមៈ ភេទប្រុស សញ្ជាតិខ្មែរ មុខរបរកម្មករឡុតដ្ឋ ជានីតិជន ។ (ក្រៅឃុំ)

៨-នាម-គោត្តនាមៈ ភេទប្រុស សញ្ជាតិខ្មែរ មុខរបរកម្មករឡុតដ្ឋ ជានីតិជន ។ (ក្រៅឃុំ)

៩-នាម-គោត្តនាមៈ ភេទប្រុស សញ្ជាតិខ្មែរ មុខរបរកម្មករឡុតដ្ឋ ជានីតិជន ។ (ក្រៅឃុំ)

ត្រូវបានដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យពីបទៈ **ធ្វើឱ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅភូមិទេពមន្ត្រី ឃុំព្រះប្រសប់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ ។

<u>ឃើញថា៖</u>

កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ២០ និង ៣០នាទី ឈ្មោះ ភេទស្រី បានទៅបត់ជើងធំនៅក្រោយផ្ទះរបស់ឈ្មោះ ភេទស្រី ។ នៅពេលនោះឈ្មោះ បានស្រែកប្រាប់កុំឱ្យជុះអញ្ចឹងស្អុយណាស់ ហើយឈ្មោះ បានឆ្លើយថា " ខ្ញុំជុះនៅលើដីក្បែរឡុតដ្ឋខ្ញុំទេ " ហើយឈ្មោះ ក៏បានដើរមកប្រាប់ប្តីឈ្មោះ ហើយឈ្មោះ ក៏ដើរទៅសួរនាំ ហើយក៏មានទំនាស់គ្នាតែម្តង ។ ភ្លាមនោះឈ្មោះ និងឈ្មោះ បានយកដុំថ្មគប់ទៅលើដំបូលផ្ទះឈ្មោះ យ៉ែម ម៉ាប់ និងដំបូលឡុតដ្ឋរបស់ឈ្មោះ ជាច្រើនដុំ។ ក្រោយមកឈ្មោះ បានទូរស័ព្ទហៅឪពុកឈ្មោះ មកជួយ ។ លុះដល់ម៉ោង ២១ និង០០នាទី ឈ្មោះ , ឈ្មោះ , ឈ្មោះ , ឈ្មោះ , ឈ្មោះ , ឈ្មោះ , ឈ្មោះ បានជិះម៉ូតូមកដល់ឡុតដ្ឋរបស់ឈ្មោះ ហើយឈ្មោះ បានដើរទៅបត់ជើងនៅកន្លែងឈ្មោះ បត់ជើងនោះ ហើយក៏មានគេបាញ់គ្រាប់ជំពាមកៅស៊ូត្រូវដៃរបស់ឈ្មោះ ភ្លាមនោះក៏ផ្អើលឆោឡោ ហើយឈ្មោះ , ឈ្មោះ , ឈ្មោះ , ឈ្មោះ , ឈ្មោះ , ឈ្មោះ , ឈ្មោះ បានយកដុំថ្មគប់ទៅលើផ្ទះកម្មករ និងដំបូលឡុតដ្ឋរបស់ឈ្មោះ បណ្តាលឱ្យធ្លុះធ្លាយ ។

<u>**យល់ឃើញថា៖**</u>

-អង្គហេតុខាងលើត្រូវបានតំណាងអយ្យការ បានបើកការស៊ើបសួរ តាមដីការសសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរលេខៈ ០៦០ ដកសស.១៥ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ បញ្ជូនទៅចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្តាល ។

-ក្រោយពីបើកការស៊ើបសួររួចមក គឺចៅក្រមស៊ើបសួរពុំបានបំពេញកិច្ចស៊ើបសួរតាមនីតិវិធីទេ គឺទុកសំណុំរឿងបណ្តាលឱ្យផុតអាជ្ញាយុកាលនៃបទល្មើស ។ ដូចនេះគប្បីតំណាងអយ្យការលើកលែងចោទប្រកាន់លើឈ្មោះ ភេទប្រុស អាយុ ២៧ឆ្នាំ , ឈ្មោះ ភេទប្រុស អាយុ ២០ឆ្នាំ , ឈ្មោះ ភេទប្រុស អាយុ ៥០ឆ្នាំ , ឈ្មោះ ភេទប្រុស អាយុ ១៧ឆ្នាំ , ឈ្មោះ

គេទប្រុស អាយុ ៣៦ឆ្នាំ , ឈ្មោះ      គេទប្រុស អាយុ ៣៤ឆ្នាំ , ឈ្មោះ      គេទប្រុស , ឈ្មោះ      គេទប្រុស និងឈ្មោះ      គេទប្រុស ពីបទ៖ **ធ្វើឱ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅភូមិទេពមន្ត្រី ឃុំព្រះប្រសប់ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ ។

**<u>ហេតុដូច្នេះ</u>**

ប្តឹងសុំទៅចៅក្រមស៊ើបសួរ:

- លើកលែងចោទប្រកាន់លើ៖

| | |
|---|---|
| ១.ឈ្មោះ | គេទប្រុស អាយុ ២៧ឆ្នាំ |
| ២.ឈ្មោះ | គេទប្រុស អាយុ ២០ឆ្នាំ |
| ៣.ឈ្មោះ | គេទប្រុស អាយុ ៥០ឆ្នាំ |
| ៤.ឈ្មោះ | គេទប្រុស អាយុ ១៧ឆ្នាំ |
| ៥.ឈ្មោះ | គេទប្រុស អាយុ ៣៦ឆ្នាំ |
| ៦.ឈ្មោះ | គេទប្រុស អាយុ ៣៤ឆ្នាំ |
| ៧.ឈ្មោះ | គេទប្រុស |
| ៨.ឈ្មោះ | គេទប្រុស |
| ៩.ឈ្មោះ | |

ពីបទ៖ **ធ្វើឱ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅភូមិទេពមន្ត្រី ឃុំព្រះប្រសប់ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ ។

ថ្ងៃ [illegible] ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅកណ្ដាល, ថ្ងៃទី ១០ ខែធ្នូ ឆ្នាំ២០២០

**តំណាងអយ្យការ**

# ឧបសម្ព័ន្ធទី១០

# ដីការដោះស្រាយ ឬដីកាបញ្ជូនទៅជម្រះ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**
បន្ទប់ស៊ើបសួរ (ប)
លេខ: ១៩៤៩ ដកជរ/២០

# ដីកាបញ្ជូនរឿងទៅជំនុំជម្រះ

យើង ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល

អមដោយលោក ជាក្រឡាបញ្ជី។

-បានឃើញ មាត្រា២៤៧ច្បាប់ស្តីពីសោធនកម្មមាត្រា២៥០ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខនស/រកម/០៨០៧ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ៖ ៨០៦ អ.ក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៧ របស់ អយ្យការអមសាលាដំបូងខេត្តកណ្ដាល។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ៖៤៤៥ ដក.សស ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងខេត្តកណ្ដាល។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ៖១៨៨១ ដក.សព ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

## ក្រោយពីបានស៊ើបសួរ និង ពិនិត្យសំណុំរឿងចប់សព្វគ្រប់

-មានភស្តុតាងដាក់បន្ទុក គ្រប់គ្រាន់លើជនត្រូវចោទ៖

-ឈ្មោះ ភេទប្រុស អាយុ៣០ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ កំពង់ចាម សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម។

ជាប់ចោទពីបទ៖**បើកបរដោយធ្វេសប្រហែសបណ្ដាលឱ្យមានរបួសអ្នកដទៃ** ប្រព្រឹត្តនៅលើកំណាត់ ផ្លូវជាតិលេខ៤ ចន្លោះគីឡូម៉ែត្រលេខ២០-២១ ត្រង់ចំណុចភូមិត្រពាំងសុក្រម ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្ដាល កាល ពីថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

## <u>ហេតុដូច្នេះសម្រេច</u>

-<u>បញ្ជូនជនត្រូវចោទ</u>ឈ្មោះ ភេទប្រុស អាយុ ៣០ ឆ្នាំ និងសំណុំរឿងព្រហ្មទណ្ឌលេខ៖ ៨០៦ អក ចុះថ្ងៃទី ០៥ **ខែកក្កដា ឆ្នាំ២០១៧** និងបញ្ជីរាយនាមជនដែលជាប់ទាក់ទិនក្នុងសំណុំរឿងលើនេះទៅសាលាដំបូងខេត្តកណ្ដាល **ដើម្បីកំណត់ពេលសវនាការជំនុំជម្រះ**។

ថ្ងៃព្រហស្បតិ៍ ២ រោច .ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ខេត្តកណ្ដាល,ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០២០

បានទទួលអនុវត្ត

ក្រឡាបញ្ជី

**ចៅក្រមស៊ើបសួរ**

**បានទទួលដំណឹងរួចហើយ**

ថ្ងៃ.......................... ខែ........ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ខេត្តកណ្ដាល,ថ្ងៃទី ...21.......ខែ...12..... ឆ្នាំ២០២០

**តំណាងអយ្យការ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

- សំណុំរឿងព្រហ្មទណ្ឌលេខ **១៥០៤ អ.ក** ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០
- សំណុំរឿងស៊ើបសួរលេខ **២៦០ ស.ស** ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០

លេខ ១៥៧៩........**ដក.ដស/២០**

## **ដីកាដំណោះស្រាយ**

យើង ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល

អមដោយលោក ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល

- បានឃើញ មាត្រា ២៤៧ ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មមាត្រា ២៤៧ មាត្រា ៣៦៨ មាត្រា ៣៧២ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ **១៥០៤ អ.ក.** ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០។

- បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ **១០៨៨ ដក.សស/២០** ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តកណ្ដាល។

- បានឃើញ សំណុំរឿងស៊ើបសួរលេខ **៧៥៤ ស.ស** ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០ ដែលមានជនត្រូវចោទ៖

ឈ្មោះ **ហៅ** ភេទប្រុស អាយុ ឆ្នាំ ជានីតិជន ជនជាតិ ខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើតភូមិកំពង់ក្ដី ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ ទីលំនៅ(ផ្ទះជួល) ភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្ដាល។

ឪពុកឈ្មោះ (រស់) ម្ដាយឈ្មោះ (រស់) នៅលីវ។

ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ៖ គ្មាន។

កាលបរិច្ឆេទនៃការឃាត់ខ្លួន៖ ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០។

កាលបរិច្ឆេទនៃការឃុំខ្លួនបណ្ដោះអាសន្ន៖ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០។ (ក្នុងឃុំ)

ដែលជននេះត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ **អំពើលួច** ប្រព្រឹត្តនៅភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ បទល្មើសដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣ មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

### **អំពីអង្គហេតុ**

កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ១៤ និង ៣០ នាទី ស្ថិតនៅភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្ដាល ជនសង្ស័យឈ្មោះ ហៅក្រៅ ភេទប្រុស អាយុ ឆ្នាំ ជាតិខ្មែរ បានធ្វើសកម្មភាពលួចម៉ូតូ ០១ គ្រឿង ម៉ាក HONDA DREAM ស៊េរី២០២០ ពាក់ស្លាកលេខ កណ្ដាល 1AG-3612 របស់ជនរងគ្រោះឈ្មោះ ហៅក្រៅ ភេទប្រុស អាយុ ឆ្នាំ ជាតិខ្មែរ ដែលចតទុកនៅមុខផ្ទះជួល ហើយភ្លាមនោះជនសង្ស័យជិះគេចខ្លួនទៅដល់ឃុំកំពង់សឹង ស្រុកព្រះស្ដេច ខេត្តព្រៃវែង តែដោយសារម៉ូតូជាប់ជីភី

រអេស ក៏ត្រូវបានសមត្ថកិច្ចស្រាវជ្រាវរកឃើញ និងឃាត់ខ្លួនជនសង្ស័យឈ្មោះ ហៅ និងដកហូតភស្តុតាងម៉ូតូខាងលើតែម្តង។

- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ **១៥៤២ ដក.សត/២០** ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល បានប្តឹងសុំឱ្យចៅក្រមស៊ើបសួរ បញ្ជូនជនត្រូវចោទឈ្មោះ ហៅ ដែលបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ **អំពើលួច** ប្រព្រឹត្តនៅភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ទៅជំនុំជម្រះ។

## សំអាងហេតុ

១. **យល់ឃើញថា** តាមចម្លើយជនត្រូវចោទឈ្មោះ ហៅ នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ចំពោះមុខតំណាងអយ្យការ និងចំពោះមុខចៅក្រមស៊ើបសួរ បានបង្ហាញថាពីភាពប្រហាក់ប្រហែលគ្នា៖

ក. កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ១៤ និង ៣០ នាទី ស្ថិតនៅភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល ពិតជាមានអង្គហេតុ ដូចក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ លេខ **១០៨៨ ដក.សស/២០** ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០ ពិតប្រាកដមែន។ ចៅក្រមស៊ើបសួរយល់ឃើញថា អំពើរបស់ជនត្រូវចោទឈ្មោះ ហៅ គឺជាការដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬ វត្ថុផ្សេងៗ របស់អ្នកដទៃ តាមមធ្យោបាយក្នុងបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ដែលអំពើនេះត្រូវបានចាត់ទុកថាជាបទ "**អំពើលួច**" បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

ខ. តាមសកម្មភាពរបស់ជនត្រូវចោទ ដែលបានប្រព្រឹត្តអំពើលួចបាន បង្ហាញនូវចេតនាក្នុងការដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬ វត្ថុផ្សេងៗ របស់អ្នកដទៃ អាចសន្និដ្ឋានបានថា ជនត្រូវចោទបានដឹងយ៉ាងច្បាស់ថាសកម្មភាពប្រើមធ្យោបាយក្នុងបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន គឺជាអំពើខុសច្បាប់ ព្រោះពុំមានភស្តុតាងណាមួយអាចបញ្ជាក់បានថា ជនត្រូវចោទមានលក្ខណៈសម្បត្តិ ឬនីតិសម្បទាដែលត្រូវបានផ្តល់ឱ្យដោយអាជ្ញាធររដ្ឋក្នុងការដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬ វត្ថុផ្សេងៗ របស់អ្នកដទៃនោះទេ។ ចៅក្រមស៊ើបសួរយល់ឃើញថា ជនត្រូវចោទមានចេតនាទុច្ចរិតក្នុងការប្រព្រឹត្តសកម្មភាព អំពើលួច តាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

គ. ជនត្រូវចោទឈ្មោះ ហៅ គឺជាអនីតិជនដែលមាននីតិសម្បទាបរិបូរណ៍ និងស្មារតីគ្រប់គ្រាន់ដែលអាចវិនិច្ឆ័យពីអំពើល្មើសរបស់ខ្លួនបានពុំមានសញ្ញាណណាមួយដែលបញ្ជាក់ថា ជននេះមានបញ្ហាផ្នែកបញ្ញា ឬស្មារតីក្នុងពេលប្រព្រឹត្តបទល្មើស។

២. យល់ឃើញថា តាមសំអាងហេតុចំណុចទី១ ជនត្រូវចោទឈ្មោះ ហៅ បានបំពេញធាតុផ្សំនៃបទល្មើស "**អំពើលួច**" ប្រព្រឹត្តនៅភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

៣. **យល់ឃើញថា** តាមរយៈភស្តុតាងក្នុងសំណុំរឿង ពុំបានបង្ហាញអំពី ភស្តុតាងណាមួយដែលអាចដោះបន្ទុកលើបទចោទប្រកាន់ ប៉ុន្តែបានបង្ហាញអំពី ភស្តុតាងដែលបានដាក់បន្ទុកលើជនត្រូវចោទឈ្មោះ ហៅ ពីបទ **អំពើលួច** ប្រព្រឹត្តនៅភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

**៤. យល់ឃើញថា** តាមកថាខណ្ឌទី២ នៃមាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ការរក្សាជនត្រូវចោទឱ្យនៅជាប់ឃុំបណ្ដោះអាសន្ន រហូតដល់ពេលចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ គឺដើម្បី៖

☐ ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី

☐ ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នា រវាងជនត្រូវចោទ និងអ្នកសមគំនិត។

☐ ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ។

☑ ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី។

☑ ដើម្បីការពារសន្តិសុខជនត្រូវចោទ

☑ ដើម្បីធានារក្សាសណ្ដាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ ដែលបណ្ដាលមកពីបទល្មើស។

**៥. យល់ឃើញថា** តាមមាត្រា ២៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការនឹងសម្រេចបញ្ជូនសំណុំរឿងព្រហ្មទណ្ឌនេះ ទៅ ឯកឧត្តមប្រធានសាលាដំបូងខេត្តកណ្ដាល ដើម្បីកំណត់កាលបរិច្ឆេទបើកសវនាការ។

## សេចក្ដីសម្រេច

១. បញ្ជូនជនត្រូវចោទឈ្មោះ ហៅ ភេទប្រុស អាយុ ឆ្នាំ (ដូចមានក្នុងអត្តសញ្ញាណខាងលើ) (ក្នុងឃុំ) ដែលត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ **"អំពើលួច"** ប្រព្រឹត្តនៅភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ បទល្មើសដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣ មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ***ដើម្បីជំនុំជម្រះ***។

២. រក្សាជនត្រូវចោទឈ្មោះ ហៅ ភេទប្រុស អាយុ ឆ្នាំ (ដូចមានក្នុងអត្តសញ្ញាណខាងលើ) (ក្នុងឃុំ) ឱ្យជាប់ឃុំខ្លួនជាបណ្ដោះអាសន្ន ដែលយើងនឹងសម្រេចឱ្យរក្សាទុកជនត្រូវចោទ នៅជាប់ឃុំជាបណ្ដោះអាសន្នតាមអំណាចដីកាបង្គាប់។

៣. បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ **១៥០៤ អ.ក.** ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០ ទៅឯកឧត្តមប្រធានសាលាដំបូងខេត្តកណ្ដាល ដើម្បីកំណត់កាលបរិច្ឆេទបើកសវនាការ។

ថ្ងៃ ចន្ទ ០៣ រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

ខេត្តកណ្ដាល, ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០

**ក្រឡាបញ្ជី** **ចៅក្រមស៊ើបសួរ**

បានទទួលដំណឹងរួចហើយ.......................

ខេត្តកណ្ដាល, ថ្ងៃទី..២១..ខែ..តុលា..ឆ្នាំ២០២០

**តំណាងអយ្យការ**

# ឧបសម្ព័ន្ធទី១១

# ដីកាដំណោះស្រាយ ឬដីកាលើកលែង

# ការចោទប្រកាន់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

លេខ ៖ ១៧៧៣ /២០

# ដីកាដំណោះស្រាយ

យើង ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល

អមដោយលោក ជាក្រឡាបញ្ជី។

-បានឃើញ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើដោយព្រះរាជ ក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ១១០៧ អ.ក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៥។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: ៩៦១ ដកសស ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ ៖ ៣១៣ ដកសស ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ ។

--បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៖ ១៦០៦ ដកសព ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០ ។

**ក្រោយពីបានស៊ើបសួរចប់សព្វគ្រប់ហើយឃើញថា÷**

តំណាងអយ្យការបានចោទប្រកាន់ជនត្រូវចោទ ៖

-ជនមិនស្គាល់មុខ (ក្រៅឃុំ)

ជននេះត្រូវបានដាក់ឱ្យនៅក្រោមការត្រួតពិនិត្យពីបទ ៖ **ដឹកជញ្ជូនផល ផលិតផលជលផលដែលបានមកពីការធ្វើនេសាទខុសច្បាប់** ប្រព្រឹត្តនៅភូមិអន្លង់ស្លែង ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៥ តាមបញ្ញត្តិមាត្រា ១០១ ចំណុច១៥ នៃច្បាប់ស្តីពីជលផល។

**យល់ឃើញថា÷**

១. កាលពីថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៥ ស្ថិតនៅភូមិអន្លង់ស្លែង ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្តាល ក្រុមអធិការកិច្ចនៃផ្នែករដ្ឋបាលជលផលរកាកោង បានសហការជាមួយអធិការដ្ឋានរដ្ឋបាលជលផលចតុមុខ សង្កាត់រដ្ឋបាលជលផលមុខកំពូល និងនគរបាលប៉ុស្តិ៍ឃុំសំបួរមាសបានចុះប្រតិបត្តិការ ប្រទះឃើញម៉ូតូសណ្តោងរ៉ឺម៉កដឹកជញ្ជូនកូនត្រីនុយសរុបចំនួន ២៥០ គីឡូក្រាម ដែលបានមកពីការធ្វើការនេសាទខុសច្បាប់ រួចសមត្ថកិច្ចក៏បានឃាត់វត្ថុតាង និងឯកសារសំណុំរឿងបញ្ជូនមកតុលាការតែម្តង។

២. យោងតាមលិខិតបញ្ជូនសំណុំរឿង, របាយការណ៍សរុប ,ព្រមទាំងឯកសារនានា គឺមានភាពស៊ីសង្វាក់ដែលអាចបញ្ជាក់ឱ្យឃើញថា៖ ជនមិនស្គាល់មុខពិតជាបានប្រព្រឹត្តបទល្មើស **ដឹកជញ្ជូនផលផលិត ផលជលផលដែលបានមកពីការធ្វើនេសាទខុសច្បាប់** ប្រាកដមែន។

៣. ជនត្រូវចោទ **ជនមិនស្គាល់មុខ** មានសមត្ថភាព និងលក្ខណៈសម្បត្តិគ្រប់គ្រាន់យល់ដឹងពីបច្ច័យដែលខ្លួនបានប្រព្រឹត្ត និងអាចទទួលខុសត្រូវព្រហ្មទណ្ឌចំពោះទង្វើរបស់ខ្លួន។

៤. អំពើរបស់ជនត្រូវចោទ **ជនមិនស្គាល់មុខ** បានធ្វើឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិ សន្តិសុខសណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ជាពិសេសច្បាប់បញ្ញត្តិអំពើនេះជាបទល្មើស៖ **ដឹកជញ្ជូនផល ផលិតផលជលផលដែលបានមកពីការធ្វើនេសាទខុសច្បាប់** បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **១០១ ចំណុច១៥ នៃច្បាប់ស្តីពីជលផល។**

៥. មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនត្រូវចោទ **ជនមិនស្គាល់មុខ (ក្រៅឃុំ)** ពីបទ៖ **ដឹកជញ្ជូនផល ផលិតផលជលផលដែលបានមកពីការធ្វើនេសាទខុសច្បាប់** ប្រព្រឹត្តនៅភូមិឈើទាលភ្លោះ ឃុំស្វាយអំពារ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី២៧ខែសីហា ឆ្នាំ២០១៣ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **១០១ ចំណុច១៥ នៃច្បាប់ស្តីពីជលផល។**

៦. ជនត្រូវចោទជា ជនមិនស្គាល់មុខ ពុំមានសាវតាជាតិគ្រប់គ្រាន់ គប្បីលើកលែងចោទប្រកាន់ តាមមាត្រា ២៤៧ ថ្មី កថាខណ្ឌទី៣ ចំណុចទី២ នៃច្បាប់ស្តីពីវិសោធនកម្ម មាត្រា ២៤៧ មាត្រា ៣៦៨ មាត្រា ៣៧២ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**ហេតុដូច្នេះសម្រេច**

១/. លើកលែងចោទប្រកាន់លើ **ជនមិនស្គាល់មុខ** ពីបទ៖ **ដឹកជញ្ជូនផល ផលិតផលជលផលដែលបានមកពីការធ្វើនេសាទខុសច្បាប់** ប្រព្រឹត្តនៅភូមិប្រព្រឹត្តនៅភូមិអន្លង់ស្លែង ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៥ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **១០១ ចំណុច១៥ នៃច្បាប់ស្តីពីជលផល។**

**២/.** បញ្ជូនវត្ថុតាងល្មើសច្បាប់ដែលពាក់ព័ន្ធក្នុងសំណុំរឿងនេះ ទៅប្រធានសាលាដំបូងខេត្តកណ្តាល ដើម្បីជំនុំជំម្រះតាមច្បាប់។

ថ្ងៃ..................ខែ..........ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

កណ្តាល,ថ្ងៃទី.......ខែ.......ឆ្នាំ២០២០

បានអនុវត្ត

**ក្រឡាបញ្ជី**

**ចៅក្រមស៊ើបសួរ**

បានទទួលដំណឹងរួចហើយ

កណ្តាល,ថ្ងៃទី.........ខែ.......ឆ្នាំ២០២០

**តំណាងអយ្យការ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

បន្ទប់ស៊ើបសួរ (ប)

លេខ: **៦២៥**

## ដីកាលើកលែងចោទប្រកាន់

យើង ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល

-បានឃើញ មាត្រា២៤៧ ច្បាប់ស្តីពីវិសោធនកម្ម នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ៖ ៥៩៣ អ.ក ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៩។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ៖ ១៣៦៤ ដកសស ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៩ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល។

-បានឃើញសំណុំរឿងស៊ើបសួរ ១១៧៤ សស ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ៖ ៥២១ ដក.សព/២១ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល។

### ក្រោយពីបានស៊ើបសួរ និងពិនិត្យសំណុំរឿងចប់សព្វគ្រប់

### យល់ឃើញថា

ឈ្មោះ ភេទប្រុស អាយុ ៤៧ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិកំពង់ចម្លង ឃុំកំពង់ចម្លង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ឪពុកឈ្មោះ (ស្លាប់) ម្តាយឈ្មោះ (រស់) ប្រពន្ធឈ្មោះ មានកូនចំនួន ០៤នាក់ ជានីតិជន ទោសពីមុនគ្មាន។ (ក្រៅឃុំ)

ពីបទ៖ **បង្ករបួសដោយចេតនា** ប្រព្រឹត្តនៅភូមិកំពង់ចម្លង ឃុំកំពង់ចម្លង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០០៩ តាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។ តាមការគណនាលើថិរវេលា ដែលចាប់ផ្តើមគតិតពីកិច្ចនីតិវិធីចុងក្រោយរបស់តំណាងអយ្យការ ពោលគឺដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ លេខ ១៣៦៤ ដកសស.០៩ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៩ រហូតដល់មកត្រឹមថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ដែលចៅក្រមស៊ើបសួរជូនដំណឹងអំពីការបញ្ចប់ការស៊ើបសួរ គឺមានរយៈពេល១១ឆ្នាំ ០១ខែ និង២៥ថ្ងៃមកហើយ។ ចំពោះអង្គហេតុខាងលើនេះបានផុតអាជ្ញាយុកាលនៃបណ្តឹង ដោយអនុលោមតាមមាត្រា ៣០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដូច្នេះគប្បីតុលាការលើកលែងចោទប្រកាន់តាមមាត្រា ២៤៧ ថ្មីនៃច្បាប់ស្តីពីវិសោធនកម្មនៃក្រមនីតិវិធីព្រហ្មទណ្ឌ និងតាមការប្តឹងសុំរបស់តំណាងអយ្យការ។

<u>**ហេតុដូច្នេះសម្រេច**</u>

-លើកលែងចោទប្រកាន់លើឈ្មោះ                    ភេទប្រុស អាយុ ៤៧ឆ្នាំ ពីបទ៖ **បង្ករបួសដោយចេតនា** ប្រព្រឹត្តនៅភូមិកំពង់ចម្លង ឃុំកំពង់ចម្លង ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល តាមបញ្ញត្តិមាត្រា **៤១** នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

ថ្ងៃសុក្រ ១៥កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ខេត្តកណ្ដាល, ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១

**បានទទួលអនុវត្ត**

**ក្រឡាបញ្ជី**

**ចៅក្រមស៊ើបសួរ**

**បានទទួលដំណឹងរួចហើយ**

ខេត្តកណ្ដាល, ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១

**ព្រះរាជអាជ្ញារង**

# ឧបសម្ព័ន្ធទី១២

# លិខិតជូនដំណឹងអំពីដីកាដំណោះស្រាយ ឬលិខិតជូន ដំណឹងអំពីដីការបញ្ជូនទៅជំនុំជម្រះ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

ចៅក្រមស៊ើបសួរ "ម"

លេខ ៖ ...2169...ច.ស.ស.ម/២០

ពន្ធនាគារខេត្តកណ្តាល
ចូល លេខ...៦៣៩...
ថ្ងៃទី១៩ ខែ១០ ឆ្នាំ២០២០
ម៉ោង...៣...៣០នាទី

**លិខិតជូនដំណឹង**

**ស្តីពីដីកាដំណោះស្រាយ**

យើង ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល

- បានឃើញ មាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។
- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ **១៥០៤ អ.ក.** ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០ ។
- បានឃើញ សំណុំរឿងស៊ើបសួរលេខ **៧៥៤ ស.ស** ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០។
- បានឃើញ ដីកាដំណោះស្រាយលេខ ..1579...... **ដកដស** ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០។

**ប្រាប់មក**

ជនត្រូវចោទឈ្មោះ ហៅ ទីលំនៅ(ផ្ទះជួល) ភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល។

☐ ឃុំខ្លួនជាបណ្តោះអាសន្ន តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ **៣៥៥៦ ដក.ប.ឃខ** ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០។

☐ ក្រៅឃុំជាបណ្តោះអាសន្ន។

**ឱ្យជ្រាបថា** យើង តាមដីកាដំណោះស្រាយខាងលើ បានសម្រេចបញ្ជូនជនត្រូវចោទទៅជំនុំជម្រះពីបទ **អំពើលួច** ប្រព្រឹត្តនៅភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពី ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

ថ្ងៃ ចន្ទ ០៣ កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

ខេត្តកណ្តាល, ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០

**ចៅក្រមស៊ើបសួរ**

បានទទួលដំណឹង

**ជនត្រូវចោទ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងព្រហ្មទណ្ឌលេខ ១៥០៤ អ.ក.

ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០

លេខ ..៤១៧០....... ព.ស.ស.ថ/២០

## ដីកាបញ្ជូន

ផ្ញើជូន លោកប្រធានពន្ធនាគារខេត្តកណ្ដាល

ពន្ធនាគារខេត្តកណ្ដាល
ចូល
លេខ......៣១៧......
ថ្ងៃទី..១៩..ខែ..១០..ឆ្នាំ..២០២០
ម៉ោង......៤:០០ នាទី

| ល.រ | រាយឈ្មោះលិខិត | ចំនួន | ផ្សេងៗ |
|---|---|---|---|
| ១ | លិខិតជូនដំណឹងស្ដីពី ដីកាដំណោះស្រាយលេខ៤១៦៩. ព.ស.ស.ថ/២០ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០ លើជនត្រូវចោទឈ្មោះ ហៅ ភេទប្រុស អាយុ ១៧ ឆ្នាំ។ | ០២ ច្បាប់ | "ដើម្បីជូនដំណឹងអំពីដំណោះស្រាយ និងបង្វិលលិខិតជូនដំណឹងខាងលើមួយច្បាប់មកសាលាដំបូងខេត្តកណ្ដាលវិញ។" |
| ២ | ដីកាបង្គាប់រក្សាទុកជនត្រូវចោទឱ្យនៅជាប់ឃុំបណ្ដោះអាសន្នលេខ .៤១៦៨....ព.ស.ស.ថ/២០ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០ លើជនត្រូវចោទឈ្មោះ ហៅ ភេទប្រុស អាយុ ១៧ ឆ្នាំ។ | ០៥ ច្បាប់ | |
| | សរុប | ០៧ ច្បាប់ | |

ថ្ងៃ ចន្ទ ០៣ កើត ខែកត្ដិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

ខេត្តកណ្ដាល, ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០

**ចៅក្រមស៊ើបសួរ**

ក្រឡាបញ្ជីលោក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល
បន្ទប់ស៊ើបសួរ(ប )
លេខ:..1483..

**លិខិតជូនដំណឹង**
**អំពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ**

យើង ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល ។

សូមជូនដំណឹងដល់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ភេទប្រុស កើតឆ្នាំ១៩៨៣ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិស្ទួន ពេជ្រ សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ ។

ឲ្យបានជ្រាបថា៖ យើងបានសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះតាមដីកាបញ្ជូនរឿងជំនុំជម្រះ លេខ៖១៩៤៩ ដកជរ/២០.ចុះថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០២០។

ហេតុនេះសូមលោក ជ្រាបជាដំណឹង។

ថ្ងៃ ព្រហស្បតិ៍២រោច ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស២៥៦៤
ខេត្តកណ្ដាល, ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០២០
**ចៅក្រមស៊ើបសួរ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ  សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល
បន្ទប់ស៊ើបសួរ "ប"
លេខ:..១៣៧..អ-ប /២១

# ដីកាបញ្ជូន

**ផ្ញើជូន៖ លោកស្នងការនគរបាលខេត្តកណ្តាល**

| ល.រ | វាយឈ្មោះលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| | សំណុំរឿងព្រហ្មទណ្ឌលេខ៖២១៩៤ចុះថ្ងៃទី៣០ខែធ្នូ ឆ្នាំ២០២០ | | ដើម្បីចាត់បញ្ជូនតាមនីតិវិធី។ |
| | លិខិតជូនដំណឹងអំពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ | | |
| | -ឈ្មោះ (ជនរងគ្រោះ) | ០២ច្បាប់ | |
| | | | |
| | **សរុបចំនួន** | ០២ច្បាប់ | |

ថ្ងៃ សុក្រ ២ កើត ខែ មាឃ ឆ្នាំជូត ទោស័កព.ស ២៥៦៤
ខេត្តកណ្តាល,ថ្ងៃទី ១៥ ខែ មករា  ឆ្នាំ២០២១
**ចៅក្រមស៊ើបសួរ**

# ឧបសម្ព័ន្ធទី១៣

# លិខិតជូនដំណឹងអំពីដីកាដំណោះស្រាយ

# (លើកលែងចោទប្រកាន់)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

លេខ ៤៨៧៥

# លិខិតជូនដំណឹងពីដីកាដំណោះស្រាយ

យើង ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល

បានឃើញ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខៈ ០៩៣ អក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ ពីបទៈ **ធ្វើឲ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅភូមិទេពមន្ត្រី ឃុំព្រះប្រសប់ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្ដន្ទាទោសតាមមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ ។

សូមជូនដំណឹងដល់ជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ ៣៦ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ កម្មករឡឥដ្ឋ មានទីលំនៅបច្ចុប្បន្ននៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្ដាល ។

ត្បិតសំណុំរឿងខាងលើនេះយើងបានសម្រេច ៖

- លើកលែងចោទប្រកាន់លើជនត្រូវចោទៈ

១.ឈ្មោះ ភេទប្រុស អាយុ ២៧ ឆ្នាំ

២.ឈ្មោះ ភេទប្រុស អាយុ ២០ ឆ្នាំ

៣.ឈ្មោះ ភេទប្រុស អាយុ ៥០ ឆ្នាំ

៤.ឈ្មោះ ភេទប្រុស អាយុ ១៧ ឆ្នាំ

៥.ឈ្មោះ ភេទប្រុស អាយុ ៣៦ ឆ្នាំ

៦.ឈ្មោះ ភេទប្រុស អាយុ ៣៤ ឆ្នាំ

៧.ឈ្មោះ ភេទប្រុស

៧.ឈ្មោះ ភេទប្រុស

៩.ឈ្មោះ ភេទប្រុស

ពីបទៈ **ធ្វើឲ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅភូមិទេពមន្ត្រី ឃុំព្រះប្រសប់ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្ដន្ទាទោសតាមមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ ។

ថ្ងៃព្រហ.. ៦កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស២៥៦៤

កណ្ដាល ថ្ងៃទី ១៦..... ខែធ្នូ ឆ្នាំ២០២០

**ចៅក្រមស៊ើបសួរ**

យើង..............................បានប្រគល់លិខិត ជូន
ដំណឹងនេះដល់ឈ្មោះ..............................
ទីលំនៅភូមិ..........................ឃុំ.......................
ស្រុក..........................ខេត្ត..........................
នៅថ្ងៃទី.....ខែ..........ឆ្នាំ.........ផ្ទាល់ដៃរួចហើយ ។
ធ្វើនៅថ្ងៃទី...........ខែ................ឆ្នាំ២០០....
អ្នកទទួល អ្នកប្រគល់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

លេខ 3642 ស-ប/២០

## ដីកាបញ្ជូន
### ផ្ញើជូន ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ

| ល.រ | រាយឈ្មោះលិខិត | ចំនួន | ផ្សេងៗ |
|---|---|---|---|
| ១ | លិខិតជូនដំណឹងពីដីកាដំណោះស្រាយ លេខ 2370 ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០២០ | ០២ ច្បាប់ | ដើម្បីចាត់ការតាមនីតិវិធី ។ (០៩៣ អក/៣០.០១.១៥) |
| | | | |
| | | | |
| | | | |
| | | | |
| | សរុប | ០២ ច្បាប់ | |

ថ្ងៃព្រហស្បតិ៍ ៣កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស២៥៦៤

កណ្ដាល, ថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០២០

**ប្រធានសាលាដំបូង**

# របាយការណ៍អំពីការបញ្ជូន

*-ប្រអប់ខាងក្រោមត្រូវបំពេញដោយក្រឡាបញ្ជី:*

ក- កាលបរិច្ឆេទផ្ញើចេញ: ថ្ងៃទី....... ខែ .......... ឆ្នាំ២០២០

សំណុំរឿងព្រហ្មទណ្ឌ លេខ: ៣០៧ អក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៥

ឈ្មោះឯកសារផ្ញើចេញ: លិខិតជូនដំណឹងអំពីដីកាដំណោះស្រាយ

ឈ្មោះអ្នកទទួលបន្ទុកកិច្ចការបញ្ជូន: ក្រឡាបញ្ជី និង ដួងកែវ

អាសយដ្ឋានអ្នកទទួលបន្ទុកកិច្ចការបញ្ជូន: សាលាដំបូងខេត្តកណ្តាល

ឈ្មោះអ្នកដែលត្រូវទទួលឯកសារបញ្ជូនទៅ: ឯកឧត្តមប្រធានសាលាដំបូងខេត្តព្រៃវែង (សូមជួយបញ្ជូនដីកានេះ ដល់ដៃសាមីខ្លួនផង)

ខ- ហត្ថលេខាឬស្នាមម្រាមដៃអ្នកទទួលឯកសារផ្ទាល់ស្លេង ..........................................................

-ប្រអប់ខាងក្រោមត្រូវបំពេញដោយប្រតិបត្តិការបញ្ជូន (កត្តាប្រៃសណីយ៍ ឬអាជ្ញាសាលា ឬក្រឡាបញ្ជី)

គ ទីកន្លែងធ្វើការបញ្ជូនទៅ: **សាលាដំបូងខេត្តព្រៃវែង**

កាលបរិច្ឆេទនៃការបញ្ជូន: ថ្ងៃទី ........... ខែ ...........ឆ្នាំ ២០២០ វេលាម៉ោង .......................

***វិធីជាក់ស្តែងក្នុងការបញ្ជូន***

ឃ ☐ ១ បានប្រគល់ជូនជនដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃ។

☐ ខ្ញុំបានពន្យល់ជូនជនដែលត្រូវទទួលការបញ្ជូននូវខ្លឹមសារសង្ខេបនៃឯកសារដែលបានបញ្ជូន ពីព្រោះជននោះមិនចេះអានអក្សរ។

ង ☐ ២ បានប្រគល់ឯកសារទៅអ្នកដែលមានការយល់ដឹងសមរម្យ ចំពោះការទទួលឯកសារនេះ ពីព្រោះខ្ញុំមិនបានជួបអ្នកត្រូវទទួលការបញ្ជូនដោយផ្ទាល់នៅកន្លែងដែលត្រូវបញ្ជូននោះទេ

☐ អ្នកបំរើ ☐ អ្នកផ្សេងដែលនៅធ្វើការនៅទីនោះ ☐ អ្នកនៅជាមួយ

ឈ្មោះ:..........................................................................................................

ច ☐ ឯកសារត្រូវបានទុកនៅទីកន្លែងធ្វើការបញ្ជូន ដោយហេតុថា: បុគ្គលខាងក្រោមនេះ មិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផល។

☐ ជនដែលត្រូវទទួលការបញ្ជូន ☐ អ្នកបំរើ

☐ អ្នកនៅជាមួយ ☐ អ្នកផ្សេងដែលធ្វើការនៅទីនោះ

ឈ្មោះ: ..........................................................................................................

ឆ ☐ ខ្ញុំបានបញ្ជូនឯកសារតាមវិធីដូចខាងលើ

ជ ☐ ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើនេះបានសម្រេចទេ ពីព្រោះនៅកន្លែងដែលត្រូវទទួលការបញ្ជូន ខ្ញុំមិនបានជួបនឹងជនដែលត្រូវទទួលការបញ្ជូនឬជនដែលមានការយល់ដឹងសមរម្យ ក្នុងការទទួលឯកសារនេះទេ។

ឈ កាលបរិច្ឆេទធ្វើរបាយការណ៍: ..........................................................................................

ឈ្មោះ និង ហត្ថលេខាអ្នកធ្វើរបាយការណ៍: ..........................................................................

កណ្តាល 27 NOV 2020 080000 KANDAL CAMBODIA

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

បន្ទប់ស៊ើបសួរ (ប)

លេខ: ៣៤៩

## លិខិតជូនដំណឹងឬ ជូនព័ត៌មាន

យើង ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្តាល។

សូមប្រាប់មកជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ ៤៧ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិកំពង់ចម្លង ឃុំកំពង់ចម្លង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។

ឱ្យបានជ្រាបថា៖ សំណុំរឿងព្រហ្មទណ្ឌលេខ៖ ៥៩៣ អ.ក ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៩ ដែលបានចោទពីបទ៖ **បង្ករបួសដោយចេតនា** ប្រព្រឹត្តនៅភូមិកំពង់ចម្លង ឃុំកំពង់ចម្លង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល តាមបញ្ញត្តិមាត្រាផ្តន្ទាទោសតាមមាត្រា **៤១** នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល នោះយើងបានសម្រេច **លើកលែងការចោទប្រកាន់** តាមដីកាលេខ........ ចុះថ្ងៃទី....... ខែកុម្ភៈ ឆ្នាំ២០២១ ។

សូមលោក ជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ១៥កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ខេត្តកណ្តាល, ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១

**ចៅក្រមស៊ើបសួរ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្តាល**

លេខ: ៣៥១ ជ-ប/២១

# ដីកាបញ្ជូន

**ផ្ញើជូន៖ លោកស្នងការដ្ឋាននគរបាលខេត្តកណ្តាល**

| ល.រ | រាយឈ្មោះលិខិត | ចំនួន | សេចក្តីផ្សេងៗ |
| --- | --- | --- | --- |
| ០១ | សំណុំរឿងព្រហ្មទណ្ឌលេខ: ៥៩៣ អ.ក ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៩ ។ | ០១ រឿង | ដើម្បីចាត់ការតាមនីតិវិធី |
| ០២ | លិខិតជូនដំណឹងអំពីដីកាលើកលែងចោទប្រកាន់ | | |
| | -ឈ្មោះ : ភេទប្រុស អាយុ ៤៧ឆ្នាំ។<br>-ឈ្មោះ ភេទស្រី សញ្ជាតិខ្មែរ។ | | |
| | សរុបចំនួន | ០១ រឿង | |

ថ្ងៃសុក្រ ១៥កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ខេត្តកណ្តាល, ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១

**ចៅក្រមស៊ើបសួរ**